កាសែតចេញផ្សាយ
ប្រចាំខែ ឆ្នាំទី១២

# អ្នកនាំសារ
# the messenger

ខែ ឧសភា | ឆ្នាំ ២០២០ | លេខទី ១២៧

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ www.khmer.rvasia.org/ May, 2020 | #127



## លោកបូជាចារ្យ សួន ហង្សលី ៖
## «រួមជាមួយព្រះយេស៊ូ យើងនឹងបង្កើតផលបានបរិបូរណ៍»

ទំព័រ > ១០-១១

### គ្រប់និកាយគ្រីស្តសាសនានៅកម្ពុជា ប្តេជ្ញារួមគ្នាទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩

ទំព័រ > ១៨

### ក្រសួងបរិស្ថានបង្ក្រាប
## បទល្មើសព្រៃឈើជិត៥០០ករណី
ក្នុងរយៈពេល៤ខែ ឆ្នាំ២០២០

ទំព័រ > ១២-១៣

# តើយើងត្រូវប្តេជ្ញាប្រយុទ្ធនឹង គ្រឿងញៀន និង បទល្មើសព្រៃឈើគួរតែរឹតបន្តឹងបន្ថែមទេ?



*ដោយ ៖ លី សុវណ្ណា*

សព្វថ្ងៃនេះអាជ្ញាធរគ្រប់លំដាប់ថ្នាក់ កំពុងតែយកចិត្តទុកដាក់ប្រយុទ្ធប្រឆាំងនឹងបញ្ហាពីរ គឺការព្រួយបារម្ភ និងការរីករាលដាលកូវីដ១៩ និងការរឹតបន្តឹងនូវច្បាប់ចរាចរណ៍ផ្លូវគោក។ ចុះបញ្ហាគ្រឿងញៀន និងបទល្មើសព្រៃឈើវិញយ៉ាងណាដែរ? ទាក់ទងនឹងការប្រយុទ្ធប្រឆាំងនឹងកូវីដ១៩ យើងមិនដឹងថា តើយើងអាចនឹងបានជោគជ័យដល់កម្រិតណានៅឡើយទេ នៅពេលអនាគត ដោយសារការព្រួយបារម្ភអំពីការផ្ទុះនូវរលកទីពីរនៃការឆ្លងដូចដែលអង្គការសុខភាពពិភពលោកបានសំដែងការព្រួយបារម្ភជាបន្តបន្ទាប់ ប៉ុន្តែបើនិយាយអំពីបច្ចុប្បន្នភាព យើងខ្ញុំអាចចូលរួមវាយតម្លៃបានថា យើងបានធ្វើយ៉ាងល្អ ហើយអាចចាត់ទុកវាជាជោគជ័យដំណាក់កាលដំបូងមួយ ដែលយើងអាចរក្សាបាននូវការឆ្លងជាសហគមន៍ទូលំទូលាយ ដោយមានអ្នកឆ្លងត្រឹមតែ១២២នាក់។

បើនិយាយពីរឿងចរាចរណ៍វិញ ហាក់មានសភាពប្រសើរដែរ បើទោះបីជាវាប្រទាំងប្រទើសខ្លះៗ ក៏សមត្ថកិច្ច និងប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ បានបង្ហាញពីការចូលរួមលើកកម្ពស់ការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក ហើយក៏សង្ឃឹមថា ស្ថានភាពនេះកាន់តែប្រសើរថែមទៀត នៅពេលអនាគត ដោយសារតែពេលនេះ យើងទើបតែចាប់ផ្តើមបានប្រមាណជា១២ថ្ងៃ ប៉ុណ្ណោះ។ នៅក្នុងរយៈពេលនេះ យានយន្តជាច្រើនបានប្រញាប់រៀបចំសំណុំឯកសារស្របច្បាប់ ដើម្បីកុំឱ្យរងការផាកពិន័យ។

ទាំងនេះគឺជាស្ថានភាពវិជ្ជមាននៃការប្តេជ្ញាចិត្តទាំងអស់គ្នា ទាំងថ្នាក់ដឹកនាំ អាជ្ញាធរគ្រប់កម្រិត និងប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ប៉ុន្តែបញ្ហាគ្រឿងញៀន និងបទល្មើសព្រៃឈើវិញ តើពេលណាទើបមានការប្តេជ្ញាចិត្តឱ្យបានម៉ឺងម៉ាត់លើបញ្ហានេះនៅកម្ពុជាយើង។

កន្លងមកមានការប្តេជ្ញាចិត្តច្រើនលើកច្រើនសាររួចមកហើយ ទាក់ទងនឹងការអនុវត្តការ ប្រយុទ្ធប្រឆាំងនឹងបញ្ហាទាំងពីរនេះ ប៉ុន្តែវាដូចជាគ្មានប្រសិទ្ធភាពអ្វីជាដុំកំភួនគួរឱ្យកត់សម្គាល់ទាល់តែសោះ។

បទល្មើស និងបញ្ហាគ្រឿងញៀន និងព្រៃឈើ នៅតែដដែល។ តាមសេចក្តីរាយការណ៍ព័ត៌មានជាបន្តបន្ទាប់ ដែលយើងខ្ញុំបានអាន គ្រឿងញៀននៅពេលនេះ វាឈានដល់ចំណុចទិញលក់ដូចជារបរស្របច្បាប់ឬមុខជំនួញមួយទៅហើយ ដោយមានអ្នកដើរមកទិញយកទៅលក់ចែកចាយត្រង់ៗ រីឯបទល្មើសព្រៃឈើវិញ គឺមានក្រុមឈ្មួញបន្តលួចដឹកជញ្ជូន និងកាប់បំផ្លាញធនធានធម្មជាតិជាបន្តបន្ទាប់។

យើងខ្ញុំសង្កេតឃើញថា បទល្មើសទាំងពីរនេះមិនមែនសមត្ថកិច្ចមិនចាត់វិធានការនោះទេ ប៉ុន្តែការអនុវត្តការប្រយុទ្ធប្រឆាំងនេះ ហាក់គ្មានប្រសិទ្ធភាព ដូចជាការប្រយុទ្ធនឹងកូវីដ១៩ និងការអនុវត្តការរឹតបន្តឹងច្បាប់ចរាចរណ៍ផ្លូវគោកទាល់តែសោះ។ ដូច្នេះ! ដល់ពេលដែលយើងគួរតែដោះស្រាយហើយ ព្រោះវាក៏ជាបញ្ហាដែលមានគ្រោះថ្នាក់សម្រាប់ជាតិ និងប្រជាពលរដ្ឋនៅក្នុងប្រទេសយើងផងដែរ។

សរុបមកវិញសូមនាំគ្នាចូលរួមហើយរឹតបន្តឹងគ្រប់បញ្ហាមិនមែនដោះស្រាយមួយ បន្ទរមួយនោះទេ គឺត្រូវតែពង្រឹងយន្តការច្បាប់ និងអនុវត្តច្បាប់ឱ្យបានគត់មត់ ទើបសង្គមយើងអាចកាត់បន្ថយបញ្ហាសង្គមបានកាន់តែតិចទៅៗ។ យើងដឹងថា ផ្លូវនៃការកសាងនីតិរដ្ឋនៅស្រុកយើងមានការលំបាក តែយើងត្រូវតែជំនះទាំងអស់គ្នាឱ្យខានតែបាន។

គណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ កាលពីខែកុម្ភៈ ឆ្នាំ២០២០ កន្លងទៅនេះ បានចេញសេចក្តីប្រកាសឱ្យដឹងថា បានធ្វើការបង្ក្រាប និងរឹបអូសឈើចម្រុះជាង៩ពាន់ម៉ែត្រគូប រួមទាំងមធ្យោបាយដឹកជញ្ជូនឈើជិត៥០០គ្រឿងផងដែរ។

សេចក្តីប្រកាសបានឱ្យដឹងថា មធ្យោបាយដឹកជញ្ជូនចំនួន ៤៩១គ្រឿង ដែលមានដូចជា រថយន្តបាកុង និងមធ្យោបាយកែច្នៃចំនួន ២១២គ្រឿងទៀត ត្រូវបានយកទៅបំផ្ទុះដុត និងកាត់បំផ្លាញចោល៕




Formation, Dailouge, Cooperation

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

**ចាងហ្វាង : លោក លី សុវណ្ណា**

សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ

Tel/Fax : (855) 23 224 120

Email : csccambodia@gmail.com / Website : www.catholiccambodia.org

Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org

https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh




# ការប្រមាញ់សត្វព្រៃខុសច្បាប់លើពិភពលោកមានការកើនឡើង

*ដោយ ៖ អមរិទ្ធ ដានុត*



*សត្វត្រយ៉ងយក្សទាំង៣ក្បាលនេះ ត្រូវបានគេសម្លាប់ដោយខុសច្បាប់ ដើម្បីយកសាច់ធ្វើជាអាហារ ឬយកទៅលក់នៅទីផ្សារ។ **រូបភាព៖ អង្គការសមាគមអភិរក្សសត្វព្រៃ (WCS Cambodia)***



*សត្វត្រយ៉ងយក្សត្រូវបានចាត់ថ្នាក់ជាប្រភេទជិតផុតពូជបំផុតនៅលើពិភពលោក និងជាប្រភេទសត្វត្រូវការពារនៅក្នុងប្រទេសកម្ពុជា។ **រូបភាព៖ អង្គការសមាគមអភិរក្សសត្វព្រៃ***

អ្នកអភិរក្សសត្វត្រយ៉ងបានបង្ហាញពីក្តីបារម្ភជាសកល ខណៈដែលពួកគេកត់សម្គាល់ឃើញ នៅតែមានការកើនឡើងនៃការបរបាញ់ប្រភេទសត្វត្រូវការពារ ចាប់តាំងពីការរីករាលដាលនៃវីរុសកូរ៉ូណាបានចាប់ផ្តើម ដែលធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធសេដ្ឋកិច្ចលក្ខណៈប្រពៃណី និងសង្គមកិច្ចនៅតំបន់ជនបទ។

សេចក្តីប្រកាសព័ត៌មានចំនួន ៣ទំព័ររបស់អង្គការសមាគមអភិរក្សសត្វព្រៃ (WCS) ចេញផ្សាយនៅថ្ងៃព្រហស្បតិ៍ទី១៦ ខែមេសា ឆ្នាំ២០២០ បានឱ្យដឹងថា សត្វត្រយ៉ងយក្សចំនួន ៣ក្បាល ត្រូវបានពុលស្លាប់នាដើមខែក្នុងដែនជម្រកសត្វព្រៃឆែប ខេត្តព្រះវិហារ ដោយដាក់ការដាក់ថ្នាំបំពុល ដែលជាចេតនាមួយនាំឱ្យចំនួននេះស្មើនឹងការបាត់បង់ប្រហែលពី១ទៅ ២ភាគរយនៃចំនួនសត្វត្រយ៉ងយក្សសរុបនៅលើពិភពលោក។

សត្វត្រយ៉ងយក្សទាំង៣ក្បាលនេះ ត្រូវបានសម្លាប់ដោយខុសច្បាប់ ដើម្បីយកសាច់ធ្វើជាអាហារឬយកទៅលក់នៅទីផ្សារ។

អង្គការសមាគមអភិរក្សសត្វព្រៃ (WCS) បានបញ្ជាក់បន្ថែមថា ក្រៅពីការប្រមាញ់សត្វត្រយ៉ងយក្សដោយខុសច្បាប់ កូនរនាលពណ៌ ជាង១០០ ក្បាល ត្រូវបានលួចចាប់កាលពីចុងខែមីនា ឆ្នាំ២០២០ នៅឯតំបន់វាលសារព្រែកទាល់នៃប្រទេសកម្ពុជា ដែលជាបន្ទាយសត្វស្លាបទឹកធំជាងគេនៅតំបន់អាស៊ីអាគ្នេយ៍។

លោក ខូលីន ភូល (Colin Poole) នាយកអង្គការ WCS ប្រចាំមហាតំបន់មេគង្គ បានមានប្រសាសន៍ថា ដោយសារតម្រូវការចាំបាច់បន្ទាន់ប្រជាពលរដ្ឋនៅជនបទគ្មានជម្រើសអ្វីក្រៅតែពីពឹងផ្អែកលើធនធានធម្មជាតិនោះទេ ហើយលោកក៏បានកំពុងមើលឃើញការកើនឡើងអំពីបញ្ហាប្រមាញ់ខុសច្បាប់នេះ។

លោកបានថ្លែងបន្តថា៖ «ការបន្តប្តេជ្ញាចិត្តរបស់អ្នកអភិរក្សដើម្បីអប់រំប្រជាពលរដ្ឋនៅជនបទនៅទូទាំងតំបន់ក្នុងពេលនេះ មានសារៈសំខាន់ណាស់ ព្រោះពួកគាត់គ្មានបណ្តាញការពារសុវត្ថិភាពនិងស្ថិតក្នុងភាពឯកោនៅជួរមុខ ដែលជាអ្នកការពារព្រៃឈើនិងសត្វព្រៃ ស្ថិតនៅជួរមុខ និងក្រោយគេក្នុងនិងជុំវិញសហគមន៍របស់ពួកគាត់»។

ក្នុងរយៈពេលពីរសប្តាហ៍ចុងក្រោយនេះ ស្របពេលសេដ្ឋកិច្ចត្រូវបានបិទនិងប្រាក់ចំណូលថយចុះកាន់តែតិចទៅៗ អ្នកអភិរក្សបានមើលឃើញការកេងប្រវ័ញ្ចលើធនធានធម្មជាតិកំពុងមានការកើនឡើង រួមទាំងការប្រមាញ់ខុសច្បាប់លើសត្វព្រៃត្រូវការពារផងដែរ។ ការប្រមាញ់សត្វខ្លានៅក្នុងប្រទេសឥណ្ឌាមានការកើនឡើង រីឯនៅទ្វីបអាហ្វ្រិកអ្នកអភិរក្សក៏កត់សម្គាល់ឃើញដូចគ្នានេះដែរ លើការប្រមាញ់សត្វរមាស។

ចាប់តាំងពីដើមខែកុម្ភៈ ឆ្នាំ២០២០ មក ក្រុមល្បាតសហគមន៍តំបន់ការពារធម្មជាតិនិងមន្ត្រីឧទ្យានុរក្សនៃមន្ទីរបរិស្ថានខេត្តព្រះវិហារ បានចាត់វិធានការលើការប្រមាញ់សត្វស្លាប ដោយ ប្រើថ្នាំពុលគីមី ចំនួន ១២ករណី ក្នុងតំបន់ទំនាបភាគខាងជើង។

សត្វត្រយ៉ងយក្ស គឺជាបក្សីនិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា។ សត្វនេះត្រូវបានចាត់ថ្នាក់ជាប្រភេទជិតផុតពូជបំផុតនៅលើពិភពលោក និងជាប្រភេទសត្វត្រូវការពារនៅក្នុងប្រទេសកម្ពុជា។

ទោះបីជាក្នុងរយៈពេលកន្លងមក សត្វនេះមានវត្តមានច្រើនក្នុងតំបន់អាស៊ីអាគ្នេយ៍ក្តី ក៏ប៉ុន្តែបច្ចុប្បន្នសត្វនេះ មានវត្តមានតែក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ហើយត្រូវបានគេគិតថា ចំនួនរបស់វានៅសល់តិចជាង៣០០ក្បាល។ សត្វត្រយ៉ងយក្សរស់នៅតាមប្រភេទព្រៃរបោះដាច់ស្រយាលតាមតំបន់ទំនាបភាគខាងជើងនិងខាងកើត។

ដែនជម្រកសត្វព្រៃឆែបនិងដែនជម្រកសត្វព្រៃគូលេន-ព្រហ្មទេព ស្ថិតនៅតំបន់ទំនាបភាគខាងជើង នៃខេត្តព្រះវិហារ ស្ថិតក្រោមយុត្តាធិការរបស់ក្រសួងបរិស្ថាន បានផ្តល់ទីជម្រកដល់សត្វត្រយ៉ងយក្សយ៉ាងតិចមួយភាគបីនៃចំនួនសត្វប្រភេទនេះសរុបលើពិភពលោក៕

# គ្រឹះស្ថានសិក្សាជាង១០០ រងផលប៉ះពាល់

*ដោយ ៖ អមរិទ្ធ ដានុត*



សមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា បានឱ្យដឹងថា រហូតមកដល់ពេលនេះ មានគ្រឹះស្ថានសិក្សាចំនួន១១៣ គ្រឹះស្ថានដែលជាសមាជិករបស់សមាគមបានជួបប្រទះនូវការលំបាក និងរងផលប៉ះពាល់យ៉ាងខ្លាំង បន្ទាប់ពីគ្រប់គ្រឹះស្ថានសិក្សាអប់រំទាំងអស់ទូទាំងប្រទេសកម្ពុជា ត្រូវបានផ្អាកសេវាអប់រំដោយសារការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩។

កាលពីថ្ងៃសុក្រ ទី០៣ ខែមេសា ឆ្នាំ២០២០ សមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា បានបើកកិច្ចប្រជុំម្ចាស់គ្រឹះស្ថានសិក្សា ដែលជាសមាជិកនៃសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ដោយសមាគមនេះបានធ្វើការអំពាវនាវដល់ម្ចាស់ដែលបានជួលទីតាំងឱ្យគ្រឹះស្ថានសិក្សាអប់រំឯកជន ជួយសម្របសម្រួលបញ្ចុះតម្លៃឈ្នួល ឬពន្យារពេលបង់ថ្លៃឈ្នួល ឬវិធីដោះស្រាយផ្សេងពីនេះក្នុងភាពសមរម្យបំផុត។ គណៈគ្រប់គ្រង គ្រូបង្រៀន បុគ្គលិករបស់គ្រឹះស្ថានសិក្សាអប់រំឯកជន ជួយសម្របសម្រួលបញ្ចុះប្រាក់បៀវត្សរ៍ប្រចាំខែ ឬប្រាក់ឈ្នួល ឬវិធីដោះស្រាយផ្សេងៗពីនេះតាមការចរចារគ្នា។ ជាមួយនេះសមាគមក៏ស្នើសុំធនាគារឯកជនទាំងអស់ បន្ធូរបន្ថយអត្រាការប្រាក់ និងពន្យារការបង់ប្រាក់ដើម ដើម្បីឱ្យគ្រឹះស្ថានសិក្សាឯកជនបានធូរស្រាលការលំបាកបានខ្លះ។

សម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន ក៏បានមានប្រសាសន៍ទាក់ទងនឹងបញ្ហានេះ ក្នុងសន្និសីទសារព័ត៌មាន នាព្រឹកថ្ងៃអង្គារ ទី០៧ ខែមេសា ឆ្នាំ២០២០ ពាក់ព័ន្ធបច្ចុប្បន្នភាពនៃជំងឺកូវីដ១៩ នៅវិមានសន្តិភាពនាពេលកន្លងមក ដោយសម្តេចបាន និងនៅតែបន្តស្នើសុំឱ្យវិស័យឯកជន ត្រូវមានការយោគយល់គ្នាក្នុងអំឡុងពេលនៃវិបត្តិនៃជំងឺកូវីដ-១៩ តាមរយៈការអនុគ្រោះ ឬការពន្យារប្រាក់ឈ្នួលជួលអគារ, ឈ្នួលផ្ទះ, ការបង់រំលស់ផ្ទះ និងអាជីវកម្មផ្សេងជាដើម ដើម្បីរួមចំណែកកាត់បន្ថយការលំបាករបស់ប្រជាពលរដ្ឋ ដែលកំពុងមានវិបត្តិនៃជម្ងឺកូវីដ១៩នេះ៕

## «មហាវិថី សម្តេច ចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល» ជាឈ្មោះថ្មីរបស់ផ្លូវ២០០៤

*ដោយ ៖ អមរិទ្ធ ដានុត*

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែនបានសម្រេចប្រសិទ្ធនាមផ្លូវ២០០៤ដែលស្ថិតនៅខណ្ឌសែនសុខ និងខណ្ឌពោធិសែនជ័យ ទៅជាមហាវិថី សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល។

យោងតាមលិខិតឧបនាយករដ្ឋមន្ត្រីប្រចាំការរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីដែលចុះហត្ថលេខាដោយ លោក ឈួន សុធី រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលផ្ញើទៅអភិបាលរាជធានីភ្នំពេញ ឃួង ស្រេង បានឱ្យដឹងថាថា រាជរដ្ឋាភិបាលយល់ព្រមអនុញ្ញាតឱ្យប្រសិទ្ធនាមផ្លូវ២០០៤ចាប់ពីចំនុចមហាវិថីខេមរភូមិន្ទ (ផ្លូវលេខ២៧១) រហូតដល់ចំនុចមហាវិថីសហព័ន្ធរុស្ស៊ី ដែលមានប្រវែងប្រមាណជា៤,៤៥០ម៉ែត្រ និងទទឹងប្រវែងប្រហែល២០ម៉ែត្រ ស្ថិតនៅខណ្ឌសែនសុខ និងខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញទៅជា «មហាវិថី សម្តេច ចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល»៕

# មន្ត្រីក្រសួងសុខាភិបាលៈ សះស្បើយពីជំងឺកូវីដ១៩ តែយើងមិនអាចបន្ធូរដៃបានទេ



ប្រភព៖ ក្រសួងសុខាភិបាល

*ដោយ៖ អមរិន្ទ ដានុត*

បើទោះបីជាតួលេខអ្នកឆ្លងជំងឺកូវីដ១៩ក្នុងរយៈពេលប៉ុន្មានថ្ងៃចុងក្រោយនេះមិនមាន ឯអ្នកជាសះស្បើយពីវីរុសនេះក៏កាន់តែកើនឡើងក៏ដោយ ក៏មិនត្រូវមានការធ្វេសប្រហែស ឬបន្ធូរដៃឡើយ។

មន្ត្រីជាន់ខ្ពស់នៃក្រសួងសុខាភិបាលបានធ្វើការអំពាវនាវទៅដល់ប្រជាពលរដ្ឋទាំងអស់ និងស្ថាប័នពាក់ព័ន្ធទាំងអស់ចូលរួមក្នុងការទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ ពីបុគ្គលមួយទៅបុគ្គលម្នាក់ទៀតនេះ ជាពិសេសត្រូវនាំគ្នាកាត់ផ្តាច់នូវការចម្លងវីរុសនេះ ពីបុគ្គលទៅក្នុងសហគមន៍។

លោកស្រី ឱ វណ្ណឌីន អ្នកនាំពាក្យក្រសួងសុខាភិបាលបាននិយាយកាលពីថ្មីៗនេះថា ការដែលរកមិនឃើញករណីថ្មីក្នុងរយៈពេលជាច្រើនថ្ងៃនេះ គឺជាចំនុចល្អសម្រាប់ប្រទេសកម្ពុជា ប៉ុន្តែ [យើង]នៅតែមានការប្រុងប្រយ័ត្នជាប់ជានិច្ចនូវការចូលរួមទប់ស្កាត់ការចំលងពីបុគ្គលមួយទៅបុគ្គលមួយ នេះចំនុចសំខាន់ចាំបាច់ជាទីបំផុតដែលប្រជាពលរដ្ឋត្រូវចាំ និងធ្វើជារៀងរាល់ថ្ងៃ។


*លោកស្រី ឱ វណ្ណឌីន អ្នកនាំពាក្យក្រសួងសុខាភិបាល។*

លោកស្រីបានថ្លែងថា៖ «នេះជាចំនុចសំខាន់ណាស់។ មិនមែនយើងរកមិនឃើញក្នុងរយៈពេលនេះហើយ យើងគិតថា យើងមិនមានចម្លង។ ចឹងយើងនាំគ្នាបន្ធូរដៃ នោះគឺជាឱកាសមួយដែលធ្វើឱ្យវីរុសកូវីដ១៩នេះ អាចនឹងវិលមកយើងវិញជាយថាហេតុ»។

លោកស្រីបានបន្ថែមថា ក្រសួងមិនទាន់អាចវាយតម្លៃថាការចម្លងវីរុសកូវីដ១៩នៅក្នុងប្រទេសមានស្ថានភាពចប់នោះទេ ប៉ុន្តែការចូលរួមអនុវត្តពីគ្រប់ស្ថាប័ន គ្រប់ផ្នែកដែលពាក់ព័ន្ធ ជាពិសេសគឺបុគ្គល ប្រជាពលរដ្ឋមានការយល់ដឹង និងបានចូលរួមយ៉ាងសស្រាក់សស្រាំនៅក្នុងការអនុវត្តនូវការទប់ស្កាត់ការចម្លងពីបុគ្គលមួយទៅបុគ្គលមួយ។

អ្នកនាំពាក្យក្រសួងសុខាភិបាលដដែលរូបនេះបានថ្លែងថា៖ «ទាំងនេះជាចំនុចមួយល្អណាស់សម្រាប់ប្រទេសកម្ពុជាយើង ហើយយើងនឹងបន្តធ្វើការងារនេះជាមួយគ្នាបន្តទៀត ហើយការវាយតម្លៃ យើងនឹងធ្វើការវាយតម្លៃរួមគ្នាជាមួយនឹងអង្គការសុខភាពពិភពលោក ថាតើការចម្លងឬស្ថានភាពរបស់កូវីដ១៩ក្នុងប្រទេសយើង ស្ថិតនៅក្នុងស្ថានភាពបែបណា។ ខ្ញុំក៏សូមធ្វើការអំពាវនាវទៅដល់ប្រជាពលរដ្ឋទាំងអស់ អាជ្ញាធរដែនដី និងគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់សូមឱ្យចូលរួមជាបន្តទៀតនៅក្នុងការទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ ពីបុគ្គលមួយទៅបុគ្គលម្នាក់ទៀតនេះ។ ជាពិសេសយើងត្រូវកាត់ផ្តាច់នូវការចម្លងវីរុសនេះ ពីបុគ្គលទៅក្នុងសហគមន៍របស់យើង»។

លោកស្រីបញ្ជាក់ថា បើភ្លេចខ្លួន សត្រូវនេះនឹងវាយលុកមកយើងវិញ ក្នុងរយៈពេលដ៏ខ្លីបំផុត។ ពេលខ្លះ មានការស្ងប់ស្ងាត់បន្តិច តែក៏អាចមានការរាតត្បាតជាបន្តទៀតដែរ ដែលគេហៅថា second wave។ ដូច្នេះត្រូវបោះជំហានសកម្មទប់ស្កាត់ជាបន្តទៀត ទើបអាចសង្កត់សត្រូវវីរុសកូវីដ១៩នេះបាន។

ទន្ទឹមនឹងនេះដែរ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានត្រៀមបម្រុងសម្ភារៈ និងបរិក្ខារពេទ្យក្នុងស្តុករួចស្រេចហើយ ក្នុងការប្រយុទ្ធប្រឆាំងជំងឺឆ្លងកូវីដ១៩ (Covid-១៩)។ ក្នុងនាមជាប្រធានគណៈកម្មការជាតិប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩នេះដែរ សម្តេចតេជោក៏បានបង្ហាញនូវផែនការយុទ្ធសាស្ត្រថ្មីបន្ថែមក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងនេះ ដែលក្នុងនោះលោកបានបញ្ជាឱ្យបន្ថែមនូវ ស្តុកម៉ាសចំនួន១០លានម៉ាស, ខោអាវគ្រូពេទ្យចំនួន៥ពាន់កំប្លេរ, ម៉ាសគ្រូពេទ្យ៥០ម៉ឺន, ម៉ាសប្រភេទ N-៩៥ ចំនួន៥ពាន់ និងទឹកអាល់កុលចំនួន១លានលីត្រ។

សម្តេចនាយករដ្ឋមន្ត្រី បានបញ្ជាក់ថា៖ «នេះជាការចាំបាច់ ព្រោះយើងមិនអាចឱ្យ គ្រូពេទ្យណាម្នាក់ឆ្លងរោគព្រោះតែខ្វះការទទួលខុសត្រូវរបស់យើងនោះទេ។ ឥឡូវនេះ ខ្ញុំសូមចេញនូវបទបញ្ជាបន្ថែម គឺយើងត្រូវមានការស្តុកបម្រុងរបស់រាជរដ្ឋាភិបាលមួយកម្រិតថែមទៀត»។ លោកនាយករដ្ឋមន្ត្រីសុំឱ្យប្រជាពលរដ្ឋមានទំនុកចិត្តមកលើវិធានការរាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ជំងឺឆ្លងកូវីដ១៩។

ក្រសួងសុខាភិបាលកម្ពុជា បានប្រកាសកាលពីថ្ងៃទី១៦ ខែឧសភា នេះថា កម្ពុជាបានព្យាបាលអ្នកជំងឺកូវីដ១៩ឱ្យជាសះស្បើយទាំងស្រុង ដែលមានចំនួន១២២ករណី ដោយពុំមានករណីស្លាប់នោះទេ។ ទោះជាយ៉ាងនេះក្តី ក្រសួងបន្តជម្រុញឱ្យប្រជាជនទាំងអស់បន្តការប្រុងប្រយ័ត្នខ្ពស់ជាបន្តទៀត។

យោងតាមរបាយការណ៍របស់អង្គការសុខភាពពិភពលោក (World Health Organization) គិតត្រឹមថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០នេះបានបង្ហាញថា ប្រទេសនិងដែនដី២១៣ហើយ ដែលមានករណីឆ្លងជំងឺកូវីដ១៩ ហើយអ្នកឆ្លងបានកើនឡើងរហូតដល់ជាង ៤,៨០១,៨៧៥ លានករណី ក្នុងនោះអ្នកជំងឺ ៣១៦,៦៧១នាក់បានស្លាប់ និងប្រមាណជា ១,៨៥៨,១៧០ នាក់បានជាសះស្បើយ៕

# អ្នកជំងឺកូវីដ១៩ជាសះស្បើយ តែអាចលាប់ឡើងវិញ

*ដោយ៖ ផល សុផានិត*

បញ្ហានៃការលាប់ឡើងវិញ ឬក៏ការកើតមានករណីវិជ្ជមានកូវីដ១៩ឡើងវិញគឺមានលទ្ធភាពកើតមានជាក់ស្តែងនៅកម្ពុជាមានករណីលាប់ឡើងវិញមួយករណី ខណៈនៅប្រទេសផ្សេងទៀតក៏មានករណីលាប់ឡើងវិញផងដែរ។ នេះបើតាម លោកស្រី ឱ វណ្ណឌីន អ្នកនាំពាក្យក្រសួងសុខាភិបាលបានបញ្ជាក់ក្នុងសន្និសីទសារព័ត៌មានស្តីពីបច្ចុប្បន្នភាពជំងឺកូវីដ១៩ កាលពីពាក់កណ្តាលខែមេសាកន្លងមក។



*បុគ្គលិកពិនិត្យកំដៅកម្មករ កម្មការិនី មុនអនុញ្ញាតឱ្យពួកគេចូលបម្រើការងារ។*

លោកស្រី ឱ វណ្ណឌីន បានបញ្ជាក់បន្ថែមថា អ្នកជាហើយបែរជាមានវិជ្ជមានកូវីដ១៩ វិញ គឺអាចនឹងមានលក្ខណៈនៃការឆ្លងឡើងវិញផងដែរ ត្រង់នេះមានន័យថា លទ្ធភាពដែលគាត់ឆ្លងទៅអ្នកដទៃមានតែមានលក្ខណៈទាប។

លោកស្រីបានបន្តថា៖ «ចំពោះករណីលាប់ឡើងវិញនេះ យើងអត់ដឹងច្បាស់ទេ សូម្បីតែអង្គការសុខភាពពិភពលោកហៅកាត់ថា (WHO) អំពីអត្តចរិករបស់វីរុសនេះវាបែបនេះ ឬបែបណា អញ្ចឹងវីរុសនេះវាអាចបំបែកខ្លួនជាប្រភេទមួយ ហើយបំបែកជាប្រភេទមួយទៀត ដូចជាករណី ជំងឺគ្រុនឈាមកាលពីមុន បើសិនជាព្យាបាលជាហើយ គឺអត់ឈឺវិញទេ តែក្រោយមកវាឈឺវិញ។ ដូច្នេះករណីកូវីដ១៩ លាប់ឡើងវិញដូចគ្នា »។

តំណាងខាងអង្គការសុខភាពពិភពលោក (WHO) បានបញ្ជាក់ផងដែរថា លោកស្រីលើកទឹកចិត្តឱ្យអ្នកដែលទទួលបានការព្យាបាលជាសះស្បើយ ហើយត្រឡប់ទៅផ្ទះគួរបន្តតាមដានសុខភាពបន្តទៀត។

យ៉ាងណាមិញ លោកស្រីបានបញ្ជាក់ថា ករណីលាប់ជំងឺកូវីដ១៩ ឡើងវិញ លើបុរសខ្មែរ វ័យ ៤០ឆ្នាំ នៅសង្កាត់ច្រាំងចំរេះ ក្នុងខណ្ឌឫស្សីកែវ ក្រោយពីបានលាប់ជំងឺនេះម្តងទៀត ក៏បានទទួលការព្យាបាលបន្តបន្ទាប់ ក៏ធ្វើតេស្តឃើញ «អវិជ្ជមាន» វិញហើយដែរ៕





# កម្ពុជាបកស្រាយនឹងការព្រួយបារម្ភអំពីបញ្ហាសិទ្ធិមនុស្ស និងការបញ្ចេញមតិទាក់ទិននឹងការអនុម័តពង្រាងច្បាប់ «ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន»

*ដោយ៖ អរិយបុត្រ*

ស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជា ប្រចាំការិយាល័យអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិដទៃទៀត នៅទីក្រុងហ្សឺណែវ បានធ្វើការបកស្រាយទៅនឹងការរិះគន់របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ស្តីពី «ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន» នៅកម្ពុជា។





*សេចក្តីប្រកាសព័ត៌មានរបស់ស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជា ប្រចាំការិយាល័យអង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវ។*

តាមសេចក្តីប្រកាសដដែលបានស្រាយបំភ្លឺចំនួន ១១ចំណុច ឆ្លើយតបទៅនឹងការព្រួយបារម្ភអំពីសេចក្តីព្រាងច្បាប់ស្តីពី «ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន» នៅកម្ពុជានេះ។

ប្រភពដដែលបានបន្តថា៖ វាជាបញ្ហាធម្មតាទេ នៅពេលដែលមានការព្រួយបារម្ភកាន់តែខ្លាំងចំពោះការគម្រាមកំហែងដ៏គួរឱ្យភ័យខ្លាច និងហានិភ័យដល់អាយុជីវិតមនុស្ស ដែលបង្កឡើងដោយជំងឺឆ្លងកូរ៉ូណា (កូវីដ១៩) ប្រទេសជាច្រើនត្រូវបានបង្ខំចិត្តក្នុងការចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ដើម្បីការពារអាយុជីវិតប្រជាជន និងសុខភាពសាធារណៈ ដោយមានការដាក់កម្រិតទៅលើសេរីភាពនៃការបម្លាស់ទី ការជួបជុំ និងឯកជនភាព។

យ៉ាងហោចណាស់ មានប្រទេសចំនួន៧០ នៅទូទាំងពិភពលោក បានប្រកាសដាក់ប្រទេសឱ្យនៅក្នុងភាពអាសន្ន និងចាត់វិធានការបិទប្រទេស ដើម្បីទប់ស្កាត់ការរីករាលដាលនៃវីរុសនេះ។

ខណៈពេលដែលមាត្រា២២ថ្មី នៃរដ្ឋធម្មនុញ្ញអនុញ្ញាតឱ្យមានការប្រកាសដាក់ប្រទេសឱ្យនៅក្នុងភាពអាសន្ន ប៉ុន្តែច្បាប់ស្តីពីការប្រកាសភាពអាសន្ននេះនៅពុំទាន់មាននៅឡើយ ហើយនេះជាហេតុផលដែលនាំឱ្យមានសេចក្តីព្រាងច្បាប់បច្ចុប្បន្ននេះ។

ស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជាបានបន្ថែមទៀតថា ច្បាប់ស្តីពី «ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន» នឹងត្រូវយកមកអនុវត្តតែក្នុងស្ថានភាពចាំបាច់ដែលត្រូវការវិធានការបន្ថែម និងមានសេចក្តីត្រូវការចាំបាច់បំផុត សម្រាប់ការពារ និងថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដើម្បីការពារអាយុជីវិតប្រជាជន សុខភាពសាធារណៈ ផលប្រយោជន៍សាធារណៈ និងទ្រព្យសម្បត្តិរបស់ពលរដ្ឋ។ ម្យ៉ាងវិញទៀត ការដាក់ប្រទេសក្នុងភាពអាសន្នត្រូវប្រកាសនៅក្នុងរយៈពេលកំណត់ជាក់លាក់ នៅទូទាំងប្រទេស ឬក្នុងវិសាលភាពភូមិសាស្ត្រជាក់លាក់ណាមួយ ដែលមានស្ថានភាពធ្ងន់ធ្ងរ និងមិនអាចគ្រប់គ្រងបាន។

> ស្ថានភាពអាសន្ន គួរតែត្រូវបានណែនាំដោយគោលការណ៍សិទ្ធិមនុស្ស ហើយទោះជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ មិនគួរយកធ្វើជាលេស ឬជាការដោះសារណាមួយ ចំពោះការបង្ក្រាប ក្រុមអ្នកមានមតិប្រឆាំង ឬផលប៉ះពាល់មិនសមាមាត្រ និងអវិជ្ជមានដល់ក្រុមណាមួយផ្សេងទៀតឡើយ

ស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជាក៏បានបញ្ជាក់ជំហររបស់កម្ពុជាថា កម្ពុជាប្តេជ្ញាអនុវត្តកាតព្វកិច្ចរបស់ខ្លួន អនុលោមតាមមាត្រា៤នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ប្រសិនបើមានការប្រកាសដាក់ប្រទេសនៅក្នុងភាពអាសន្ន ហើយច្បាប់ស្តីពី »ការគ្រប់គ្រងប្រទេសជាតិក្នុងភាពអាសន្ន» ត្រូវបានយកមកអនុវត្ត ដើម្បីផលប្រយោជន៍សាធារណៈ។

ទោះយ៉ាងណាក្តី និងដោយមិននិយាយដល់ការព្រួយបារម្ភ ដែលសំដៅមកលើតែកម្ពុជា ប្រការនេះមិនត្រូវធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ចរបស់រដ្ឋាភិបាលក្នុងការគាំពារអាយុជីវិតប្រជាជន និងសុខភាពសាធារណៈ ការពារសន្តិសុខជាតិ និងរក្សាសណ្តាប់ធ្នាប់សាធារណៈនោះឡើយ។ ការអនុវត្តនេះវាស្ថិតនៅក្នុងសិទ្ធិអធិបតេយ្យរបស់រដ្ឋាភិបាល ដែលជាអ្នកបំពេញករណីកិច្ចក្នុងការការពារ និងធានាសន្តិសុខប្រជាជនរបស់ខ្លួនពីការគម្រាមកំហែង និងគ្រោះថ្នាក់នានាគ្រប់ប្រភេទ ដូចជាឧបទ្ទវហេតុនៃសង្គ្រាម ការឈ្លានពានរបស់បរទេស ស្ថានភាពអាសន្ននៃសុខភាពសាធារណៈ និងការរីករាលដាលនៃជំងឺ។


*លោកស្រី រ៉ូណា ស្មីត អ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។*

នៅមុនពេលមានការពន្យល់បកស្រាយនូវសេចក្តីព្រាងនៃច្បាប់នេះ អ្នកជំនាញ អ.ស.ប បានព្រមានកម្ពុជាថា ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្នរបស់ប្រទេសកម្ពុជា បង្កគ្រោះថ្នាក់ដល់សិទ្ធិមនុស្ស។

លោកស្រី រ៉ូណា ស្មីត អ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានមានប្រសាសន៍ថា វិធានការនានាដែលដាក់ចេញក្នុងស្ថានភាពមានអាសន្នត្រូវការចាំបាច់ និងសមាមាត្រទៅនឹងវិបត្តិនានាដែលត្រូវស្វែងរកដំណោះស្រាយ។

អ្នករាយការណ៍ពិសេសរូបនេះបានលើកឡើងថា៖ «ពាក្យក្នុងន័យទូលាយ អំពីការការពារសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ដែលទំនងជាមានគោលបំណងដោះស្រាយបញ្ហាជំងឺកូវីដ១៩ អាចត្រូវបានយកមកប្រើជាសត្តានុពលដើម្បីរំលោភលើសិទ្ធិឯកជន និងរឹតត្បិតដោយមិនចាំបាច់នូវសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិសេរីភាពខាងសមាគម និងសិទ្ធិជួបប្រជុំដោយសន្តិវិធី»។

ច្បាប់នេះបានផ្តល់អំណាចទូលំទូលាយ ដល់រដ្ឋាភិបាលក្នុងរយៈពេល៣ខែដំបូង រួមមានការរឹតត្បិត និងការហាមឃាត់លើការចែកចាយព័ត៌មាន និងវិធានការសម្រាប់ការតាមឃ្លាំមើល និងតាមដានតាមគ្រប់មធ្យោបាយ។

លោកស្រី ស្មីត មានប្រសាសន៍ថា៖ «ស្ថានភាពអាសន្ន គួរតែត្រូវបានណែនាំដោយគោលការណ៍សិទ្ធិមនុស្ស ហើយទោះជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ មិនគួរយកធ្វើជាលេស ឬជាការដោះសារណាមួយ ចំពោះការបង្ក្រាប ក្រុមអ្នកមានមតិប្រឆាំង ឬផលប៉ះពាល់មិនសមាមាត្រ និងអវិជ្ជមានដល់ក្រុមណាមួយផ្សេងទៀតឡើយ»។

អ្នករាយការណ៍ពិសេសបានបញ្ជាក់បន្ថែមថា នៅពេលដែលប្រទេសកម្ពុជា ចូលរួមជាមួយបណ្តារដ្ឋផ្សេងៗកាន់តែច្រើនឡើងៗ ដែលបានប្រកាសពីវិធានការពិសេស ដើម្បីដោះស្រាយការគំរាមកំហែងដល់សុខភាពសាធារណៈ ដែលបង្កឡើងដោយការរាតត្បាតនៃជំងឺកូវីដ១៩ វាជាការចាំបាច់ណាស់ដែលថា សិទ្ធិមនុស្សគឺជាចំណុចស្នូលនៃការឆ្លើយតបរបស់ខ្លួន៕

# កន្ទេលក្រហមឬកន្ទេលកក់ នៅតែពេញនិយម



កន្ទេលក្រហម ឬកន្ទេលកក់ នៅតែពេញនិយមសម្រាប់ប្រជាជន។ រូបភាព៖ វិទ្យុអាស៊ីសេរី

*ដោយ៖ ផល សុផានិត*

ប្រជាពលរដ្ឋខ្មែរនៅតាមទីជនបទ ជាពិសេសអ្នករស់នៅក្នុងខេត្តកំពង់ស្ពឺ តាកែវ និងខេត្តកណ្ដាល នៅតែពេញនិយមប្រើកន្ទេលក្រហម ឬជាសាមញ្ញថា កន្ទេលកក់ សម្រាប់ជាកម្រាលនៃការសម្រាក សម្រាន្ត ទទួលភ្ញៀវ និងក្រាលសម្រាប់ពិធីផ្សេងៗ។

កន្ទេលក្រហម ត្រូវតម្បាញឡើងពីសម្បកដើមកក់ ដែលពលរដ្ឋ ឬសិប្បករ សក និងចិតជាបន្ទះតូចៗ ចាប់ពីបណ្ដោយ១ម៉ែត្រឡើងទៅ។ អ្នកតម្បាញត្រូវហាលសរសៃនៃចំនិតកក់ ដោយជ្រលក់ពណ៌ក្រហម ស បៃតង និងលឿង ទៅតាមពណ៌នៃចំណូលចិត្ត។

ក្រុមអ្នកភូមិក៏បានធ្វើការអះអាងស្រដៀងគ្នាថា មុខរបរត្បាញកន្ទេលក្រហមបានជួយសម្រួលជីវភាព ពោលគឺចំណេញជាងការធ្វើស្រែចម្ការ ព្រោះមិនចំណាយដើមទុនច្រើន។

មានវ័យជាង ៦០ឆ្នាំ អ្នកស្រី ឯម ស្រី រស់នៅស្រុកកោះធំ ខេត្តកណ្ដាល កំពុងអង្គុយត្បាញកន្ទេលបណ្ដើរ រៀបរាប់ប្រាប់បណ្ដើរថា គាត់ប្រកបរបរនេះជាង៣០ឆ្នាំហើយ។ គាត់ និងសិប្បករជាច្រើនលក់កន្ទេលទាំងនោះបន្តទៅអ្នកភូមិដទៃ ឬឈ្មួញកណ្ដាលយកទៅលក់បន្ត។ អ្នកស្រីថា មុខរបរនេះជួយឱ្យជីវភាពគាត់ ប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ។

អ្នកស្រី ឯម ស្រី និយាយថា៖ «ការប្រកបមុខរបរនេះខ្ញុំយល់ថាចម្រើន អាចជួយប្រជាពលរដ្ឋបានឱ្យតែមានកម្លាំងធ្វើ និងមិនជំពាក់បំណុល ព្រោះធ្វើដោយកម្លាំងមនុស្សម្នាក់ៗ។ ពេលខ្ញុំធ្វើស្រែ ត្រូវចំណាយលើថ្លៃជី ថ្លៃសាំង និងថ្លៃថ្នាំកសិកម្មជាច្រើន»។

អ្នកភូមិម្នាក់ទៀត អ្នកស្រី ហ៊ុយ រតនា បាននិយាយថា មុខរបរត្បាញកន្ទេលនេះមិនពិបាកទេ។ មុខរបរនេះមិនសូវចំណាយដើមទុនច្រើនដូចជា ការធ្វើស្រែចម្ការ និងមុខរបរផ្សេងៗទៀតឡើយ។

«បើតាមមើលទៅ របរនេះល្អជាងការធ្វើស្រែចំការ ទោះបីជានឿយបន្តិចមែន ប៉ុន្តែវាមិនចំណាយថវិកាច្រើនទៅលើជី ថ្នាំ ដូចធ្វើស្រូវទេ »។ នេះបើតាមអ្នកស្រី ហ៊ុយ រតនា បានបញ្ជាក់។

បើទោះបីជាមុខរបរនេះជួយដល់ជីវភាពយ៉ាងណា តែសម្រាប់យុវជនជំនាន់ក្រោយមិនសូវចាប់អារម្មណ៍នោះទេ។ អ្នកស្រី ហ៊ុយ រតនា បានព្រួយថា កូនៗរបស់ពួកគាត់មិនចង់ប្រកបរបរនេះទេ។

អ្នកនាំពាក្យក្រសួងឧស្សាហកម្ម និងសិប្បកម្ម លោក អ៊ំ សុផា បានលើកទឹកចិត្តដល់ប្រជាពលរដ្ឋឱ្យចងក្រងគ្នាជាសហគមន៍ ដើម្បីស្ថាប័នពាក់ព័ន្ធជួយរកដំណោះស្រាយជូនពួកគេ នៅពេលជួបបញ្ហាប្រឈមនានា។

លោក អ៊ំ សុផា បាននិយាយថា «ចង់ឱ្យពួកគាត់ចងក្រងគ្នាជាសហគមន៍ បើសិនខ្វះបច្ចេកទេសអ្វីនោះ សហគមន៍នឹងធ្វើការជាដៃគូ ជាមួយមន្ទីរ និងអង្គភាពជំនាញថ្នាក់ខេត្តនោះ អាចជួយដោះស្រាយបញ្ហាជូនគាត់បានភ្លាមៗ»៕



# កម្ពុជានៅតែអាចទាក់ទាញអ្នកវិនិយោគទុនពីបរទេស នៅត្រីមាសទី១ដើមឆ្នាំ

*ដោយ៖ អរិយបុត្រ*

នៅក្នុងត្រីមាសទី១នៃឆ្នាំ២០២០ ទោះបីជាកម្ពុជានិងពិភពលោកកំពុងតែបង្ការនិងទប់ស្កាត់នូវការរីករាលដាលនៃមេរោគកូវីដ១៩ ប៉ុន្តែកម្ពុជានៅតែអាចទាក់ទាញវិនិយោគទុនមកដំណើរការប្រតិបត្តិការអាជីវកម្មនិងផលិតកម្ម ព្រមទាំងបង្កើតការងារថ្មីជូនពលរដ្ឋ ។ នេះបើតាមមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍។

រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លោក ហេង សុខគង់ បានថ្លែងថា នៅក្នុងរង្វង់ត្រីមាសទីមួយដើមឆ្នាំនេះ ក្រសួងបានកត់ត្រាថា មានរោងចក្រថ្មី សរុបចំនួន ៧៧ រោងចក្របានបើកដំណើរការនៅកម្ពុជា។

អ្នកនាំពាក្យបានថ្លែងបញ្ជាក់នៅឯសន្និសីទសារព័ត៌មានកាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ ២០២០ កន្លងទៅថ្មីៗនេះថា៖ «យើងប្រឈមនឹងបញ្ហាពីរនៅឆ្នាំនេះ គឺការរីករាលដាលនូវមេរោគកូវីដ១៩និងការព្យួរផ្នែកខ្លះនៃទំនិញនាំចេញទៅអឺរ៉ុបតាមអ៊ីប៊ីអេ (EBA) ប៉ុន្តែយើងនៅតែអាចទទួលរោងចក្រថ្មីៗ»។

លោកបានអះអាងថា រោងចក្រទាំងអស់នោះគឺកម្ពុជាអាចនឹងផ្ដល់ការងារថ្មីជូនពលរដ្ឋប្រមាណជា ២៧,៩០៩ នាក់ ។

លោកហេង សុខគង់បានបន្តទៀតថា រោងចក្រទាំងអស់នោះ គឺមានភាគច្រើន ជារោងចក្រដែលផលិតស្បែកជើង កាបូប កាត់ដេរ រោងចក្រកែច្នៃអាហារ ភេសជ្ជៈ និង ថ្នាំជក់ រោងចក្រផលិតប្លាស្ទិក រោងចក្រស្លដែក រោងចក្រកែច្នៃកៅស៊ូ និងរោងចក្រផ្សេងៗទៀត ។

លោក ហេង សុខគង់ ក៏បានឱ្យដឹងផងដែរថា ក្រៅពីរោងចក្របើកថ្មី ក៏មានរោងចក្របិទផងដែរ ហើយរោងចក្រដែលបិទនៅក្នុងអំឡុងពេលត្រីមាសទីមួយដើមឆ្នាំ២០២០ នេះ គឺមាន ចំនួន៦ រោងចក្រ ដោយធ្វើឱ្យកម្មករនិងកម្មការិនីបាត់បង់ការងារធ្វើមានសរុបចំនួនប្រមាណជា ៦០៥០ នាក់។ រោងចក្រដែលបិទទាំងនេះគឺជារោងចក្រផ្សេងៗ ប៉ុន្តែភាគច្រើន គឺរោងចក្រកាត់ដេរនិងវាយនភណ្ឌប៉ុន្តែនោះក៏មិនមែនជាការបិទរហូតដែរ គឺដោយសារតែផលិតកម្មរបស់រោងចក្រទាំងនោះត្រូវបានរំខានដោយសារផលប៉ះពាល់ដល់នៃការរីករាលដាលមេរោគកូវីដ១៩។

តាមការកត់ត្រារបស់ក្រសួងនេះបានឱ្យដឹងថាផលិតកម្មវិស័យឧស្សាហកម្មកម្ពុជាជាពិសេសគឺឧស្សាហកម្មកាត់ដេរនេះគឺមានតម្លៃសរុបប្រមាណជា៩.៣២៥លានដុល្លារ។ នេះបើតាមតួលេខកត់ត្រាកាលពីឆ្នាំ២០១៩ដោយឡែកមកដល់ត្រីមាសទី១នៃឆ្នាំ២០២០នេះ វិស័យឧស្សាហកម្មបានបង្កើតការងារធ្វើជូនពលរដ្ឋសរុបចំនួន១.០៦៣.០៣១ នាក់។

រហូតមកដល់ពេលនេះ វិស័យឧស្សាហកម្មនៅក្នុងប្រទេសកម្ពុជានៅតែជាឧស្សាហកម្មធុនស្រាលប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាកំពុងតែជំរុញវាឱ្យទៅជាឧស្សាហកម្មធុនមធ្យម ហើយមកដល់ពេលនេះកម្ពុជាក៏បាននាំចេញផលិតផលមួយចំនួនលើផ្នែកឧស្សាហកម្មធុនមធ្យមនេះទៅកាន់ទីផ្សារអន្តរជាតិដែរដែលមានដូចជាកង់ និង គ្រឿង អេឡិចត្រូនិចខ្លះៗជាដើម៕

> យើងប្រឈមនឹងបញ្ហាពីរនៅឆ្នាំនេះ គឺការរីករាលដាលនូវមេរោគកូវីដ១៩និងការព្យួរផ្នែកខ្លះនៃទំនិញនាំចេញទៅអឺរ៉ុបតាមអ៊ីប៊ីអេ ( EBA ) ប៉ុន្តែយើងនៅតែអាចទទួលរោងចក្រថ្មីៗ



លោក ហេង សុខគង់ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ រូបភាព៖ អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល





# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កត់ត្រាការនាំចេញទំនិញកសិកម្ម

*ដោយ៖ អរិយបុត្រ*

បញ្ជីកត់ត្រានៃការនាំចេញផលិតផលកសិកម្មដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានរាយការណ៍ជាសាធារណៈបានឱ្យដឹងថា នាខែមេសាកន្លងមកនេះថា កម្ពុជាអាចនាំចេញផលិតផលបីមុខប្លែក គឺផ្លែក្រូចថ្លុង ម្ទេសស្រស់ និងគល់ស្លឹកគ្រៃ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រកាសថា នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ ក្រសួងបានកត់ត្រាការនាំចេញផលិតផលផ្លែក្រូចថ្លុងម្ដងនិងម្ទេសស្រស់ម្ដង ហើយនៅថ្ងៃទី២៤ ខែឆ្នាំដដែលក៏បានកត់ត្រាពីការនាំចេញផលិតផលទាំងពីរនេះម្ដងទៀត ហើយនៅថ្ងៃដដែលនេះ ក៏មានការលេចចេញនូវផលិតផលគួរឱ្យកត់សំគាល់មួយទៀត គឺការនាំចេញផលិតផលគល់ស្លឹកគ្រៃ។

ប្រភពដដែលបានបន្តថា សម្រាប់ផលិតផលកសិកម្មជាផ្លែក្រូចថ្លុងគឺកម្ពុជាបាននាំចេញទៅកាន់ប្រទេសមីយ៉ាន់ម៉ា និងប្រទេសថៃ ហើយម្ទេសស្រស់បាននាំចេញទៅកាន់ប្រទេសថៃផងដែរ ដោយឡែកសម្រាប់ផលិតផលគល់ស្លឹកគ្រៃគឺកម្ពុជាបាននាំចេញទៅកាន់ប្រទេសកូរ៉េខាងត្បូង។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានកត់ត្រាថា ការនាំចេញនូវផ្លែក្រូចថ្លុងទៅកាន់ប្រទេសមីយ៉ាន់ម៉ានោះគឺនៅក្នុងបរិមាណប្រមាណជា៣០០តោនហើយទៅកាន់ប្រទេសថៃគឺមានចំនួនប្រមាណជា៧៥០តោន។

ក្រសួងដដែលបានបន្តទៀតថាសម្រាប់ការនាំចេញផលិតផលម្ទេសស្រស់វិញគឺទៅកាន់ប្រទេសថៃដោយមានបរិមាណសរុប១.៤២០តោន។ សម្រាប់ទំនិញកសិកម្មដែលគួរឱ្យកត់សំគាល់មួយទៀតគឺគល់ស្លឹកគ្រៃនេះគឺមានបរិមាណមិនច្រើននោះទេ គឺនៅក្នុងកម្រិតត្រឹមតែ០,០២តោនតែប៉ុណ្ណោះ។



កម្ពុជាបាននាំចេញផលិតផលកសិកម្មជាផ្លែក្រូចថ្លុងទៅកាន់ប្រទេសមីយ៉ាន់ម៉ា និងប្រទេសថៃ។ រូបភាព៖ កែវ ចន្ទបូរណ៍



រហូតមកដល់ពេលនេះក្រូចថ្លុងគឺមានដាំនៅកន្លែងជាច្រើននៅទូទាំងប្រទេសប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក្រូចថ្លុងដែលគេគិតថាមានគុណភាពល្អដែលមានរសជាតិ ហើយកំពុងតែត្រូវបានយកចិត្តទុកដាក់នោះគឺនៅទឹកដីកោះទ្រង់ នៅខេត្តក្រចេះ។ផលិតផលកសិកម្មនៅលើកោះទ្រង់នេះត្រូវបានគេទទួលស្គាល់ទាំងរសជាតិ និងសោភ័ណភាពរបស់វា។

សម្រាប់ម្ទេសត្រូវបានគេដឹងថាជាដំណាំដែលគេអាចដាំបានគ្រប់កន្លែងនៅទូទាំងប្រទេសជាពិសេសនៅតាមដងទន្លេនិងតំបន់ដែលនៅជិតនឹងប្រភពទឹក។កន្លងមក ការនាំចេញផលិតផលកសិកម្មប្រភេទនេះគឺមានជាបន្តបន្ទាប់មិនជាថ្មីនោះទេប៉ុន្តែការនាំចេញនេះគឺគ្មានការកត់ត្រាឡើយ គឺជាសកម្មភាពនៃការដោះដូរទំនិញរវាងប្រជាជននិងប្រជាជននៅតាមព្រំដែននៃប្រទេសជិតខាងដូចជាថៃ ឡាវ និងវៀតណាមជាដើមប៉ុន្តែពេលនេះ គឺមានការកត់ត្រា។

ដោយឡែកគល់ស្លឹកគ្រៃ គឺជាផលិតផលនាំចេញថ្មីបំផុត ដោយសារតែកន្លងមកកម្ពុជាធ្លាប់ទទួលការរិះគន់រឿងនាំស្លឹកគ្រៃនេះពីប្រទេសជិតខាងខណៈដែលប្រភេទដំណាំនេះត្រូវបានគេដឹងថាគឺជាប្រភេទដំណាំដែលងាយស្រួលដាំបំផុត ដែលសូម្បីតែផើងផ្កាតាមរបងផ្ទះក៏ដាំបានផងដែរ។ស្លឹកគ្រៃនេះពលរដ្ឋខ្មែរនរណាក៏ស្គាល់ដែរ ដោយសារតែវាគឺជាគ្រឿងផ្សំនៃសម្លនិងអាហារខ្មែរជាច្រើនមុខហើយក៏ជាថ្នាំបុរាណ ប្រភពសម្រាប់ ក្លិន។ល។

យោងទៅតាមការកត់ត្រារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរហូតមកដល់ពេលនេះទំនិញកសិកម្មកម្ពុជាដែលបាននាំចេញគឺកាន់តែមានច្រើនមុខ ដោយរួមមានបន្លែម្រេច ពោតដំឡូងមី ចេក ស្វាយ ថ្នាំជក់ ដូងប្រេង ស្ករត្នោតជាដើម៕

# សេដ្ឋកិច្ចសកលនឹងធ្លាក់ចុះខ្លាំងក្នុងឆ្នាំ២០២០ដោយសារកូវីដ១៩

*ដោយ៖ អរិយបុត្រ*

របាយការណ៍ចក្ខុវិស័យសេដ្ឋកិច្ចពិភពលោក ចេញផ្សាយដោយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ បានឱ្យដឹងថា សេដ្ឋកិច្ចពិភពលោកនឹងឆ្ពោះទៅរកការធ្លាក់ចុះយ៉ាងខ្លាំងនៅក្នុងឆ្នាំ ២០២០ ដោយសារលទ្ធផលនៃការរីករាលដាលជំងឺកូវីដ១៩ ដែលអាក្រក់ជាងអំឡុងវិបត្តិហិរញ្ញវត្ថុឆ្នាំ ២០០៨ -២០០៩ទៅទៀត។

លោកស្រី ហ្គីតា ហ្គោពីណាត ប្រធានសេដ្ឋវិទូមូលនិធិរូបិយវត្ថុអន្តរជាតិ និយាយនៅក្នុងសន្និសីទសារព័ត៌មានថា៖ «ពិភពលោកបានប្រែប្រួលយ៉ាងខ្លាំងក្នុងរយៈពេលបីខែចាប់តាំងពីការធ្វើបច្ចុប្បន្នភាពចុងក្រោយនៃចក្ខុវិស័យសេដ្ឋកិច្ចពិភពលោកនៅក្នុងខែមករា» ដោយកត់សម្គាល់ថា ការព្យាករណ៍ចុងក្រោយបំផុតគឺទាបជាងការព្យាករណ៍គ្រាមុន ៦,៣ ភាគរយ។




ផ្សារភាគហ៊ុនធ្លាក់ចុះយ៉ាងខ្លាំងគិតត្រឹមថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ នៅក្រោយការផ្ទុះឡើងនៃវីរុសកូវីដ១៩។ ប្រភព៖ Bloomberg

លោកស្រីហ្គោពីណាតបាននិយាយថា ខណៈប្រទេសនានាអនុវត្តនូវវិធានការទប់ស្កាត់ចាំបាច់ដើម្បីគ្រប់គ្រងជំងឺរាតត្បាតនេះ ពិភពលោកបានជាប់គាំងយ៉ាងខ្លាំង។ ទំហំ និងល្បឿននៃការដួលរលំសកម្មភាពដែលបានកើតឡើងមិនដូចអ្វីដែលធ្លាប់ជួបពីមុននៅក្នុងជីវិតរបស់យើងនោះឡើយ។

លើសពីនេះទៀត ប្រទេសជាច្រើនកំពុងប្រឈមមុខនឹងបញ្ហាជាច្រើនរួមមានវិបត្តិសុខភាព វិបត្តិហិរញ្ញវត្ថុនិងការដួលរលំនៃតម្លៃទំនិញដែលទាំងអស់នេះ ធ្វើអន្តរកម្មតាមរបៀបដ៏ស្មុគស្មាញ។

នេះជា វិបត្តិសេដ្ឋកិច្ចដ៏អាក្រក់ចាប់តាំងពីមហាវិបត្តិសេដ្ឋកិច្ចទសវត្សរ៍ឆ្នាំ១៩៣០ ហើយការខាតបង់ទិន្នផលសកលនៅទូទាំងឆ្នាំ ២០២០និង២០២១ ត្រូវបានរំពឹងថានឹងកើនឡើងដល់ប្រមាណ៩លានលានដុល្លារ ដែលធំជាងសេដ្ឋកិច្ចរបស់ជប៉ុននិងអាល្លឺម៉ង់រួមបញ្ចូលគ្នាទៅទៀត។

លោកស្រីនិយាយថា៖ «ការរីករាលដាលនៃជំងឺកូវីដ១៩នឹងថមថយនៅឆមាសទីពីរនៃឆ្នាំ២០២០ ហើយសកម្មភាពគោលនយោបាយដែលបានអនុវត្តនៅជុំវិញពិភពលោកគឺមានប្រសិទ្ធភាពក្នុងការការពារការក្ស័យធនរបស់ក្រុមហ៊ុននានា ការបាត់បង់ការងារនិងកម្លាំងហិរញ្ញវត្ថុទូទាំងប្រព័ន្ធទាំងអស់។ យើងព្យាករណ៍ថា កំណើនសកលនៅឆ្នាំ ២០២១ នឹងស្ទុះឡើងដល់ ៥,៨ ភាគរយ ដោយសង្កត់ធ្ងន់ថា ការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោកគឺមានដោយអន្ទើតែប៉ុណ្ណោះ»៕



លោកស្រី ហ្គីតា ហ្គោពីណាត ប្រធានសេដ្ឋវិទូមូលនិធិរូបិយវត្ថុអន្តរជាតិ




ពង្រូលជាថនិកសត្វដ៏ស្លូត ហើយពូកែអៀន។ វាមានត្រចៀកតូច មានស្បែក និងស្រកាក្រាស់ ដោយស្រកានេះគ្របដណ្ដប់ពេញផងខ្លួនទាំងមូល។ **រូបភាព៖ WWF Cambodia**




សត្វកន្ធាយក្បាលកង្កែប ត្រូវបានគេរកឃើញរស់នៅតាមបណ្ដោយទន្លេមេគង្គក្នុងប្រទេសកម្ពុជា ហើយរស់នៅក្នុងអន្លង់ទឹកជ្រៅៗជាង៤០ម៉ែត្រឡើង។ **រូបភាព៖ WWF Cambodia**



សាច់ និងស្រការរបស់សត្វពង្រូលគឺពេញនិយមក្នុងទីផ្សារសាច់សត្វព្រៃដែលបណ្ដាលឱ្យមានការបរបាញ់ និងជួញដូរខុសច្បាប់យ៉ាងខ្លាំង។ **រូបភាព៖ WWF Cambodia**

# ការស្ទង់មតិ៖ មហាជនចំនួនជាង៩០ភាគរយ គាំទ្រឱ្យមាន ចំណាត់ការបិទទីផ្សារជួញដូរសត្វព្រៃខុសច្បាប់ និងគ្មានការអនុញ្ញាត

*ដោយ៖ អមរិន្ទ ដានុត*

នៅក្នុងការសិក្សាស្ទង់មតិមួយដែលបានធ្វើឡើងក្នុងអំឡុងខែមីនាកន្លងមកនេះដោយអង្គការធ្វើការលើការការពារសត្វព្រៃ បានចេញលទ្ធផលថា មហាជនចំនួនជាង៩០ភាគរយមកពីប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ និងហុងកុងបានគាំទ្រឱ្យមានចំណាត់ការមួយឡើងដោយរដ្ឋាភិបាលក្នុងការបិទទីផ្សារជួញដូរសត្វព្រៃខុសច្បាប់ និងគ្មានការអនុញ្ញាតនានា។

យោងតាមលទ្ធផលនៃការស្ទង់មតិរបស់អង្គការមូលនិធិសកលសំរាប់អភិរក្សធនធានធម្មជាតិ (WWF)ដែលចេញផ្សាយនាពេលថ្មីៗបានបង្ហាញថា សាធារណជនអំពាវនាវឱ្យរដ្ឋាភិបាលបិទទីផ្សារជួញដូរសត្វព្រៃនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ សម្រាប់ជាវិធានការឆ្លើយតបនឹងកូវីដ១៩ ខណៈដែលពិភពលោកកំពុងតែប្រឈមនឹងគ្រោះអាសន្នសុខភាពសាធារណៈដ៏ធ្ងន់ធ្ងរបំផុត ដែលមិនធ្លាប់មានពីមុនមក។

ការផ្ទុះឡើងនូវវីរុសកូវីដ១៩នាពេលថ្មីៗនេះ ធ្វើឱ្យមានការពិនិត្យយ៉ាងមុតមាំទៅលើទំនាក់ទំនងរវាងប្រភេទជំងឺឆ្លងតាមរយៈសត្វដែលជាប្រភេទវីរុសឆ្លងពីសត្វទៅមនុស្សជាមួយនឹងទីផ្សារជួញដូរសត្វព្រៃ។

របាយការណ៍របស់អង្គការដដែលនេះបានបញ្ជាក់បន្ថែមយ៉ាងលំអិតថា៖ «ការសិក្សាស្ទង់មតិមួយដែលមានអ្នកចូលរួមចំនួន៥,០០០នាក់មកពីហុងកុង ជប៉ុន ភូមា ថៃ និងវៀតណាម បានបង្ហាញថា មនុស្សចំនួន៨២ភាគរយនៃចំនួនមនុស្សសរុបដែលបានចូលរួមក្នុងការស្ទង់មតិមានការព្រួយបារម្ភយ៉ាងខ្លាំង និងយ៉ាងខ្លាំងបំផុតចំពោះការផ្ទុះឡើងនូវវីរុសកូវីដ១៩នេះ ហើយក្នុងចំណោមចំនួនសរុបនៃអ្នកចូលរួមក្នុងការស្ទង់មតិនោះ មានមនុស្សចំនួន៩៣ភាគរយបានបញ្ចេញមតិគាំទ្រឱ្យរដ្ឋាភិបាលរបស់ពួកគេដាក់ចេញ នូវចំណាត់ការដើម្បីលុបបំបាត់ទីផ្សារជួញដូរសត្វព្រៃខុសត្រូវ និងគ្មានការអនុញ្ញាត»។



*លោក សេង ទៀក នាយកអង្គការ WWF ប្រចាំកម្ពុជា។ **រូបភាព៖ WWF Cambodia***

> ចាំបាច់ត្រូវបញ្ឈប់ការជួញដូរសត្វព្រៃគ្រប់ប្រភេទ ជាពិសេសប្រភេទ ថនិកសត្វពពួកបក្សី និងប្រភេទសត្វល្មូននានា ដែលសុទ្ធសឹងជាប្រភេទសត្វដែលអាចមានហានិភ័យខ្ពស់ក្នុងការចម្លងវីរុសដល់មនុស្ស

នេះជាការសិក្សាស្ទង់មតិជាសាធារណៈដំបូងគេបង្អស់ហើយដែលបានធ្វើឡើងស្ដីអំពីទំនាក់ទំនងរវាងវីរុសកូវីដ១៩ និងការជួញដូរសត្វព្រៃនៅក្នុងតំបន់អាស៊ី។

អ្វីដែលនៅតែជាមន្ទិលសង្ស័យនោះគឺប្រភពនៃការផ្ទុះឡើងរបស់វីរុសកូវីដ១៩ ប៉ុន្តែអង្គការសុខភាពពិភពលោក (WHO) បានបញ្ជាក់ហើយថា វាជាប្រភេទជំងឺដែលឆ្លងពីសត្វពោលគឺវាជាប្រភេទវីរុសដែលចម្លងពីសត្វព្រៃទៅមនុស្ស។

កាលពីថ្ងៃទី២៤ ខែកុម្ភៈកន្លងទៅ រដ្ឋាភិបាលចិនបានប្រកាសអំពីការហាមឃាត់ដាច់ខាតចំពោះការប្រើប្រាស់ និងបរិភោគសត្វព្រៃ។ លទ្ធផលនៃការស្ទង់មតិរបស់អង្គការ WWF បង្ហាញថា ប្រជាពលរដ្ឋគាំទ្រ ឱ្យមានវិធានការប្រហាក់ប្រហែលគ្នានេះពីសំណាក់រដ្ឋាភិបាលនៅក្នុងប្រទេសដទៃផ្សេងៗទៀតនៅក្នុងតំបន់។

លោក សេង ទៀក នាយកអង្គការ WWF ប្រចាំកម្ពុជា បានមានប្រសាសន៍ថា នៅក្នុងប្រទេសកម្ពុជាកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងការអនុវត្តច្បាប់ដោយក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបង្ហាញឱ្យឃើញនូវការយកចិត្តទុកដាក់ពិតប្រាកដមួយហើយទន្ទឹមនឹងនេះដែរសេចក្ដីណែនាំ លេខ៥ ដាក់ចេញក្នុងឆ្នាំ២០១៩ របស់គណៈអភិបាលខេត្តមណ្ឌលគិរីបានចូលរួមកាត់បន្ថយវត្តមាននៃផលិតផលសត្វព្រៃ និងសាច់សត្វព្រៃនៅលើទីផ្សារក៏ដូចជានៅតាមបណ្ដាតំបន់រមណីយដ្ឋានទេសចរណ៍សំខាន់ៗក្នុងខេត្ត។

លោកបានបន្ថែមទៀតថា៖ «គេចាំបាច់ត្រូវបញ្ឈប់ការជួញដូរសត្វព្រៃគ្រប់ប្រភេទ ជាពិសេសប្រភេទ ថនិកសត្វពពួកបក្សី និងប្រភេទសត្វល្មូននានា ដែលសុទ្ធសឹងជាប្រភេទសត្វដែលអាចមានហានិភ័យខ្ពស់ក្នុងការចម្លងវីរុសដល់មនុស្សដើម្បីធានាឱ្យបាននូវសុវត្ថិភាព និងសុខភាពសាធារណៈល្អជូនដល់ប្រជាជនកម្ពុជាទាំងអស់ ក៏ដូចជាដើម្បីបញ្ចៀសកុំឱ្យមានការផ្ទុះឡើងនូវវីរុសឆ្លងចេញពីប្រទេសយើង»។

ចំណែកនាយកប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកនៃអង្គការ WWF លោកគ្រីស្ទី វីលលៀមស៍ (Christy Williams) បានឱ្យដឹងថា ប្រទេសចិនបានចាត់វិធានការសំខាន់ៗមួយចំនួនដើម្បីហាមឃាត់ការបរបាញ់ ជួញដូរ ចរាចរណ៍ និងការបរិភោគសត្វព្រៃ ហើយប្រទេសវៀតណាមក៏កំពុងតែរៀបចំវិធានការស្រដៀងគ្នានេះដែរ។

លោក គ្រីស្ទី វីលលៀមស៍ បានថ្លែងថា៖ «រដ្ឋាភិបាលនៃបណ្ដាប្រទេសក្នុងតំបន់អាស៊ីដទៃទៀតគួរធ្វើតាមគំរូនេះ ដោយបិទទីផ្សារសត្វព្រៃនានាក្នុងប្រទេសរបស់ខ្លួន និងបញ្ឈប់ការជួញដូរសត្វព្រៃទាំងអស់ដើម្បីការពារជីវិតមនុស្ស និងបង្ការ វិបត្តិសង្គមនិងសេដ្ឋកិច្ច ដែលមនុស្ស






អន្ទាក់និង ឧបករណ៍នេសាទខុសច្បាប់មួយចំនួន ដែលត្រូវបានបង្ក្រាបបាននាពេលកន្លងមកដោយ ក្រុមល្បាតរបស់សហគមន៍រូមមាន ប្រជាសហគមន៍ បុគ្គលិកអង្គការ WWF Cambodia។ **រូបភាព៖ WWF Cambodia**



ក្រុមល្បាតសហគមន៍ បង្ក្រាប និងដកហូតបានសាច់សត្វហាលងៀតរបស់ឈ្លូសចំនួនពីរក្បាល ជ្រូកព្រៃ១ និងស្បែក-សាច់សត្វស្វា សាច់ជ្រូកព្រៃ និងប្រភេទសត្វផ្លាបា នាពេលកន្លងមក។ **រូបភាព៖ WWF Cambodia**

ទូទាំងសកលលោកកំពុងទទួលរងគ្រោះនេះ កុំឱ្យកើតឡើងជាថ្មីម្ដងទៀត»។

មនុស្សចំនួន៩ភាគរយនៃចំនួនមនុស្សសរុបដែលបានចូលរួមក្នុងការសិក្សាស្ទង់មតិធ្វើឡើងដោយស្ថាប័នឈ្មោះហ្គ្លូបស្កេន(GlobeScan) បានបញ្ជាក់ថា ខ្លួនគេផ្ទាល់ ឬអ្នកដទៃផ្សេងទៀតដែលគេបានស្គាល់ និងធ្លាប់បានទិញសត្វព្រៃក្នុងរយៈពេល១២ខែចុងក្រោយនេះ ពីទីផ្សារសត្វព្រៃដែលដាក់លក់ជាចំហរ ខណៈដែលមនុស្សចំនួន៨៤ភាគរយ នៃអ្នកដែលត្រូវបានគេស្ទង់មតិ បានប្រាប់ថាពួកគេនឹងមិនទិញសត្វព្រៃទេចាប់ពីពេលនេះតទៅ។

អគ្គនាយកនៃអង្គការ WWF អន្តរជាតិ លោក ម៉ាកូ ឡាមប៊ឺតធីនី (Marco Lambertini) បានឱ្យដឹងផងដែរថា ដល់ពេលហើយដែលមនុស្សត្រូវស្វែងយល់ពីទំនាក់ទំនងរវាងការជួញដូរសត្វព្រៃ ការសឹករិចរិលនៃបរិស្ថាន និងគ្រោះមហន្តរាយចំពោះសុខភាពមនុស្ស។ ការចាត់វិធានការក្នុងពេលឥឡូវនេះគឺពិតជាមានភាពចាំបាច់ណាស់ដើម្បីជាប្រយោជន៍ នៃមនុស្សជាតិ ក៏ដូចជាការរស់រានមានជីវិតរបស់ប្រភេទសត្វព្រៃជាច្រើនដែលរងគ្រោះដោយសារការប្រើប្រាស់ បរិភោគ និងការជួញដូរ។

អង្គការសុខភាពពិភពលោក (WHO) បានចេញរបាយការណ៍ថាជំងឺកូវីដ១៩ ដែលរាលដាលជាសកលនាពេលបច្ចុប្បន្ននេះ បូករួមទាំងធាតុបង្កជំងឺទាំងអស់នៅលើខ្លួនមនុស្ស ចំនួន ៦១ភាគរយផង គឺមានប្រភពឆ្លងមកពីសត្វ ដែលការជួញដូរសត្វព្រៃជាកត្តាបង្កគ្រោះថ្នាក់ខ្លាំងជាងគេមួយក្នុងការធ្វើឱ្យរីករាលដាលនៃជំងឺឆ្លងតាមរយៈសត្វ។ ជំងឺឆ្លងរាលដាលផ្សេងៗទៀតដូចជា ជំងឺហ្សារស៍ (SARS) មើស៍ (MERS) និងអេបូឡា (Ebola) ក៏ត្រូវបានគេរកឃើញថាបណ្ដាលមកពីវីរុសដែលឆ្លងពីសត្វមកមនុស្សផងដែរ។

ការជួញដូរសត្វព្រៃដែលគ្មាននិរន្តរភាពជាកត្តាគំរាមកំហែងដោយផ្ទាល់ធំបំផុតលំដាប់ទី២ចំពោះធនធានជីវៈចម្រុះ នៅលើសកលលោកបន្ទាប់ពីការបំផ្លិចបំផ្លាញទីជម្រកធម្មជាតិរបស់សត្វព្រៃ។ ចំនួនប្រភេទសត្វឆ្អឹងកងទាំងអស់លើភពផែនដីបានធ្លាក់ចុះចំនួនប្រមាណ ៦០ភាគរយជាមធ្យមចាប់តាំងពីឆ្នាំ១៩៧០

ហើយរបាយការណ៍ឆ្នាំ២០១៩ របស់វេទិកាគោលនយោបាយ-វិទ្យាសាស្ត្រ អន្តររដ្ឋាភិបាលស្ដីអំពីជីវៈចម្រុះ និងសេវាកម្មអេកូឡូស៊ី(IPBES) បានសន្និដ្ឋានថាជាមធ្យម ប្រភេទសត្វនានាលើសកលលោកចំនួនប្រមាណ២៥ភាគរយកំពុងទទួលរងគ្រោះថ្នាក់ជិតផុតពូជ៕

# មន្ត្រីឧទ្យានុរក្សនៃក្រសួងបរិស្ថានបង្ក្រាប
# បទល្មើសព្រៃឈើ
# ជិត៤០០ករណី
# ក្នុងរយៈពេល៤ខែ ឆ្នាំ២០២០

*ដោយ៖ អមរិន្ទ ដានុត*

បទល្មើសធនធានធម្មជាតិជិត ៤០០ករណីនៅក្នុងដែនជម្រកសត្វព្រៃ «ព្រៃឡង់»ត្រូវបានបង្ក្រាបក្នុងរយៈពេល ៤ខែកន្លងមកនេះ។ នេះបើតាមការលើកឡើងរបស់អ្នកនាំពាក្យក្រសួងបរិស្ថាន លោក នេត្រ ភក្ត្រា ដោយយោងលើរបាយការណ៍ស្តីពីការគ្រប់គ្រងនិងអភិរក្សតំបន់ដែនជម្រកសត្វព្រៃ «ព្រៃឡង់» របស់ក្រសួងបរិស្ថាន។

លោក នេត្រ ភក្ត្រាបានឱ្យដឹងបន្ថែមទៀតថា មន្ត្រីឧទ្យានុរក្សនៃក្រសួងបរិស្ថាន ដោយមានការចូលរួមពីសមាជិកនៃសហគមន៍តំបន់ការពារធម្មជាតិ និងអាជ្ញាធរពាក់ព័ន្ធបានចុះល្បាតដើម្បីការពារនិងអភិរក្សធនធានធម្មជាតិនៅក្នុងខេត្តទាំង៤នៃភូមិសាស្ត្រតំបន់ដែនជម្រកសត្វព្រៃ«ព្រៃឡង់» បានចំនួន៥១១លើក និងបានបង្ក្រាបបទល្មើសធនធានធម្មជាតិរួមមានការលួចកាប់ឈើខុសច្បាប់ ទន្ទ្រានកាន់កាប់ដីព្រៃ និងការបរបាញ់សត្វខុសច្បាប់បានចំនួន៣៩៩ករណីចាប់ពីខែមករាដល់ខែមេសា ឆ្នាំ២០២០នេះ។

លោក នេត្រ ភក្ត្រា បានថ្លែងថា៖ «បទល្មើសកាប់ឈើនិងទន្ទ្រានដីព្រៃខុសច្បាប់ចំនួន៣២ ករណីត្រូវបានកសាងសំណុំរឿងនិងបញ្ជូនទៅតុលាការដើម្បីដំណើរការនីតិវិធីនិងបានធ្វើកិច្ចសន្យា អប់រំណែនាំចំនួន ៤២ករណីដែលមានមនុស្សពាក់ព័ន្ធជិត១០០នាក់»។

នៅក្នុងការចុះទប់ស្កាត់និងបង្ក្រាបបទល្មើសក្នុងដែនជម្រកសត្វព្រៃ «ព្រៃឡង់»ក្នុងទំហំដីជាង ៤៣ម៉ឺនហិកតាស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ លោក នេត្រ ភក្ត្រា បានឱ្យដឹងថា មន្ត្រីឧទ្យានុរក្សនិងប្រជាសហគមន៍តំបន់ការពារធម្មជាតិបានរឹបអូសវត្ថុតាងជាច្រើនក្នុងនោះរួមមាន រណារយន្តចំនួន១៩៣គ្រឿង រថយន្តចំនួន២គ្រឿង គោយន្តចំនួន ៣៤គ្រឿង ម៉ូតូចំនួន២៥គ្រឿង និងរឹបអូសឈើដែលបានកាប់បំផ្លាញចំនួន ១៧៩ម៉ែត្រគូប និងឈើហ៊ុបនិងឈើដុំចំនួន១៦៥កំណាត់។

ប្រភពដដែលបានបញ្ជាក់ថា នៅក្នុងអំឡុងនៃការទប់ស្កាត់និងបង្ក្រាបបទល្មើសរយៈពេល៤ ខែដើមឆ្នាំ ២០២០នេះ កម្លាំងមន្ត្រីឧទ្យានុរក្សក៏បានបំផ្លាញ រុះរើរោងអនាធិបតេយ្យក្នុងតំបន់ដែនជម្រកសត្វព្រៃ«ព្រៃឡង់» ចំនួន៣៤រោងនិងបានដកហូតកាំភ្លើងកែច្នៃដែលប្រើប្រាស់សម្រាប់បរបាញ់សត្វខុសច្បាប់បានចំនួន២៩ដើមនិងបានដោះអន្ទាក់បានចំនួន៧២៨អន្ទាក់។

លោកបានលើកឡើងថា នេះគឺជាកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីឧទ្យានុរក្សនិងសហគមន៍នៃតំបន់ការពារធម្មជាតិក្នុងការការពារនិងអភិរក្សធនធានធម្មជាតិក្នុងតំបន់ព្រៃឡង់ឱ្យបានគង់វង្សសម្រាប់មនុស្សរាប់ជំនាន់ទៅមុខទៀត។

ទោះបីជាមានការចុះទប់ស្កាត់និងបង្ក្រាបទាំងយប់ទាំងថ្ងៃពីសំណាក់មន្ត្រីឧទ្យានុរក្សនិងសមាជិកនៃសហគមន៍តំបន់ការពារធម្មជាតិ ក៏បទល្មើសធនធានធម្មជាតិទ្រង់ទ្រាយតូចដូចជាការលបលួចកាប់ឈើ ការទន្ទ្រានរានយកដីធ្វើជាកម្មសិទ្ធិការបរបាញ់និងការដាក់អន្ទាក់សត្វព្រៃនៅតែបន្តកើតមាននៅក្នុងតំបន់ព្រៃឡង់ដែលចាំបាច់ត្រូវចាត់វិធានការទប់ស្កាត់និងបង្ក្រាបបន្តទៀត។

លោក នេត្រ ភក្ត្រា បានគូសបញ្ជាក់ថា ៖ «មានកត្តាផ្សេងៗដែលជំរុញឱ្យមានបទល្មើសទាំងនេះក្នុងនោះរួមមានកត្តាជីវភាពរបស់ប្រជាសហគមន៍ដែលធ្លាប់តែពឹងអាស្រ័យទៅលើផលអនុផលព្រៃឈើនិងការទាក់ទាញ និងញុះញង់ពីសំណាក់ក្រុមឈ្មួញទុច្ចរិតគួបផ្សំនឹងចំនួនមន្ត្រីឧទ្យានុរក្សដែលបានឈរជើងនៅក្នុងតំបន់នោះនៅមានកម្រិតនៅឡើយ»។

លោកថា កម្លាំងមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាលកម្ពុជា មានការតាំងចិត្តខ្ពស់ក្នុងការទប់ស្កាត់និងបង្ក្រាបយ៉ាងហ្មឺងម៉ាត់ប្រឆាំងនឹងបទល្មើសធនធានធម្មជាតិដែលកើតឡើងស្របតាមច្បាប់នានា។

រាជរដ្ឋាភិបាលកម្ពុជា ក្រសួងបរិស្ថាន និងដៃគូអភិវឌ្ឍបានយកចិត្តទុកដាក់ខ្ពស់លើការរៀបចំនិងពង្រឹងយន្តការគ្រប់គ្រង ការផ្តល់មធ្យោបាយឧបករណ៍-សម្ភារ ក៏ដូចជាការជួយលើកស្ទួយជីវភាពរបស់ប្រជាសហគមន៍មូលដ្ឋានបន្ថែមទៀតតាមរយៈការបង្កើតមុខរបរថ្មី បង្កើតសេដ្ឋកិច្ចនៅមូលដ្ឋានបង្កើនចំណូល ការជំរុញទេសចរណ៍ធម្មជាតិជាដើម ដើម្បីធានា ប្រសិទ្ធភាពនៃការងារគ្រប់គ្រង ការពារ និងអភិរក្សតំបន់ព្រៃឡង់។



ឯកឧត្តម នេត្រ ភក្ត្រា រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងបរិស្ថាន។ ទេសភាពព្រៃទឹកភ្លៀងជួរភ្នំក្រវាញ។ **រូបភាព៖ ក្រសួងបរិស្ថាន**



ភាពស្រស់ស្អាតនៃតំបន់ទេសភាពព្រៃទឹកភ្លៀងជួរភ្នំក្រវាញ។ **រូបភាព៖ ក្រសួងបរិស្ថាន**



មន្ត្រីឧទ្យានុរក្ស ក្នុងពេលចេញបំពេញការងារល្បាតនៅតាមគោលដៅ។ **រូបភាព៖ ក្រសួងបរិស្ថាន**



ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ទទួលស្វាគមន៍ដោយមន្ត្រីឧទ្យានុរក្ស និងប្រជាសហគមន៍តំបន់ការពារធម្មជាតិនាពេលកន្លងមក។ **ក្រសួងបរិស្ថាន**





វត្ថុតាងមួយចំនួនដែលត្រូវបានបង្ក្រាបនាពេលកន្លងមក ក្នុងការចូលរួមទប់ស្កាត់ និងរក្សាធនធានធម្មជាតិ។ **រូបភាព៖ ក្រសួងបរិស្ថាន**

បច្ចុប្បន្ននេះ ក្រសួងបរិស្ថានបាន និងកំពុងសហការអនុវត្តគម្រោងការពារ និងអភិរក្សតំបន់ដែនជម្រកសត្វព្រៃ«ព្រៃឡង់»ជាមួយគម្រោងព្រៃឡង់បៃតងគាំទ្រថវិកាដោយUS-AID របស់សហរដ្ឋអាមេរិកសម្រាប់រយៈពេល៥ឆ្នាំ (២០១៨-២០២៣) ក្នុងទំហំទឹកប្រាក់២១លានដុល្លារ។

គម្រោងព្រៃឡង់បៃតងមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការអភិរក្សជីវៈចម្រុះនិងស្ថានភាពប្រព័ន្ធអេកូឡូស៊ី ព្រមទាំងបង្កើតឱ្យមាននិរន្តរភាពនិងសមធម៌នៃកាលានុវត្តភាពផ្នែកសេដ្ឋកិច្ច ជីវភាពសហគមន៍ និងទុនធម្មជាតិសម្រាប់ការវិនិយោគឡើងវិញ នៅក្នុងដែនជម្រកសត្វព្រៃ«ព្រៃឡង់»និងតំបន់ការពារធម្មជាតិជុំវិញតំបន់ព្រៃឡង់។

គម្រោងនេះមានកិច្ចសហការជាមួយក្រសួងបរិស្ថាន ក្រសួងស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធដើម្បីពង្រឹងការការពារ អភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះផ្តោតលើការងារកំណត់និងបែងចែកតំបន់គ្រប់គ្រងការបោះបង្គោលព្រំប្រទល់ ការរៀបចំផែនការគ្រប់គ្រង និងការចុះបញ្ជីដីរដ្ឋនៅដែនជម្រកសត្វព្រៃ«ព្រៃឡង់»និងតំបន់ការពារធម្មជាតិមួយចំនួនជុំវិញតំបន់ព្រៃឡង់ បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រីឧទ្យានុរក្សក៏ដូចជាលើកកម្ពស់ជីវភាពប្រជាសហគមន៍អភិរក្សប្រពៃណីជនជាតិដើមភាគតិច។

ជាមួយគ្នានេះដែរ ក្រសួងបរិស្ថានគ្រោងសង់ស្នាក់ការសំខាន់ៗមួយចំនួននៅជុំវិញដែនជម្រកសត្វព្រៃ«ព្រៃឡង់»ដើម្បីពង្រឹងការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងតំបន់នេះ។

ជាក់ស្តែងនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២០ ក្រុមការងារក្រសួងបរិស្ថានបានចុះពិនិត្យទីតាំងជុំវិញព្រៃឡង់ភូមិសាស្ត្រខេត្តកំពង់ធំ និងខេត្តព្រះវិហារក្នុងគោលដៅស្វែងរកទីតាំងសមស្របសម្រាប់សាងសង់ស្នាក់ការរួមមួយ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការការពារ និងអភិរក្សធនធានធម្មជាតិនៅក្នុងដែនជម្រកសត្វព្រៃ«ព្រៃឡង់»។

លោក សៅ សុភាព រដ្ឋលេខាធិការក្រសួងបរិស្ថានដែលបានដឹកនាំក្រុមការងារចុះពិនិត្យរកទីតាំងនេះបានបញ្ជាក់ថា ស្នាក់ការនេះក៏នឹងប្រើប្រាស់ជាកន្លែងប្រមូលផ្តុំនូវធនធានបច្ចេកទេស ការអនុវត្តច្បាប់ ការគ្រប់គ្រងកម្លាំងការពារល្បាតប្រចាំការ និងការអន្តរាគមន៍លើបទល្មើសធនធានធម្មជាតិដែលអាចកើតឡើងនៅក្នុងតំបន់ការពារធម្មជាតិនេះហើយដែលផ្តល់លទ្ធភាពឱ្យមានការចូលរួមពីក្រសួងស្ថាប័ន និងដៃគូសហការផ្សេងទៀត។

ដែនជម្រកសត្វព្រៃ«ព្រៃឡង់» ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តចំនួន៤ គឺខេត្តកំពង់ធំ ព្រះវិហារ ក្រចេះ និងខេត្តស្ទឹងត្រែង ដែលមានផ្ទៃដីសរុប ៤៣១៦៨៣ហិកតា។

កាលពីចុងខែមេសាកន្លងមកនេះ រដ្ឋមន្ត្រីក្រសួងបរិស្ថាន លោក សាយ សំអាល់ដែលបានចុះពិនិត្យការងារគ្រប់គ្រង និងអភិរក្សតំបន់ដែនជម្រកសត្វព្រៃកែវសីម៉ា ក្នុងខេត្តមណ្ឌលគិរី បានថ្លែងអំណរគុណមន្ត្រីឧទ្យានុរក្ស និងអង្គការអភិរក្សសត្វព្រៃ (WCS) ដែលបានលះបង់កម្លាំងកាយកម្លាំងចិត្ត ខិតខំប្រឹងប្រែងចុះល្បាតការពារធនធានធម្មជាតិ ក៏ដូចជាទប់ស្កាត់និងបង្ក្រាបបទល្មើសលួចកាប់បំផ្លាញព្រៃឈើ ការរុករានទន្ទ្រានកាន់កាប់ដីព្រៃរដ្ឋខុសច្បាប់ និងការបរបាញ់សត្វព្រៃខុសច្បាប់។

លោកក៏បានជំរុញគ្រប់ភាគីពាក់ព័ន្ធទាំងអស់ចូលរួមការពារ និងអភិរក្សធនធានធម្មជាតិឱ្យបានគង់វង្ស ដើម្បីកម្ពុជាអាចលក់តួនាទីព្រៃឈើដែលដើរតួនាទីសំខាន់ក្នុងការការពារប្រព័ន្ធអេកូឡូស៊ីនៃភពផែនដីតាមរយៈការលក់ឥណទានកាបូនក្នុងទីផ្សារកាបូនស្ម័គ្រចិត្ត ហើយថវិកាដែលបានមកពីការលក់ឥណទានកាបូនត្រូវបានយកទៅគាំពារលើការងារអភិរក្ស និងការបង្កើតសេដ្ឋកិច្ចសម្រាប់ប្រជាសហគមន៍តំបន់ការពារធម្មជាតិនៅក្នុងតំបន់នោះ។

អាស្រ័យដោយសារកិច្ចខិតខំប្រឹងប្រែងក្នុងការគ្រប់គ្រង និងអភិរក្សតំបន់ការពារធម្មជាតិបានល្អប្រសើរ កម្ពុជាបានលក់ឥណទានកាបូននៅក្នុងដែនជម្រកសត្វព្រៃកែវសីម៉ា ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង និងដែនជម្រកសត្វព្រៃតាតៃក្នុងក្របខណ្ឌទីផ្សារស្ម័គ្រចិត្តដោយទទួលបានថវិកាសរុបប្រមាណ១១,៦លានដុល្លារអាមេរិកសម្រាប់ទ្រទ្រង់ដល់ការការពារ និងអភិរក្សក៏ដូចជាជួយលើកកម្ពស់ជីវភាពរបស់ប្រជាសហគមន៍មូលដ្ឋានដែលឆ្លើយតបទៅនឹងគោលការណ៍ហិរញ្ញប្បទាននិរន្តរភាព។



ការរឹបអូសឈើដែលបានកាប់បំផ្លាញ។ **រូបភាព៖ ក្រសួងបរិស្ថាន**

ជាមួយគ្នានេះ ក្រុមមន្ត្រីជំនាញកំពុងសិក្សាបន្ថែមដើម្បីលក់កាបូនក្នុងដែនជម្រកសត្វព្រៃព្រៃឡង់(ក្នុងភូមិសាស្ត្រខេត្តស្ទឹងត្រែង)ផងដែរ។ រហូតមកដល់ពេលនេះមានតែប្រទេសកម្ពុជានិងប្រទេសឥណ្ឌូនេស៊ីប៉ុណ្ណោះក្នុងចំណោមប្រទេសអាស៊ានដែលបានលក់ឥណទានកាបូនក្នុងទីផ្សារកាបូនស្ម័គ្រចិត្ត។

ប្រទេសកម្ពុជាត្រូវបានគេទទួលស្គាល់ថា មានធនធានធម្មជាតិ និងជីវៈចម្រុះដ៏សំបូរបែប។ ព្រៃឈើគ្របដណ្តប់ប្រមាណ៥០%នៃផ្ទៃប្រទេសដែលជាអត្រាខ្ពស់បំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ មកទល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលបានបង្កើនផ្ទៃដីតំបន់ការពារធម្មជាតិដែលស្ថិតនៅក្រោមយុត្តាធិការរបស់ក្រសួងបរិស្ថានរហូតដល់ប្រមាណ៤១%នៃផ្ទៃដីប្រទេសកម្ពុជាគឺស្មើនឹងប្រមាណ៧,២ លានហិកតា។ រហូតមកទល់នឹងឆ្នាំ ២០១៩នេះសហគមន៍ការពារធម្មជាតិទាំងអស់ដែលស្ថិតនៅតំបន់អភិរក្សក្រសួងបរិស្ថានមានចំនួនប្រមាណ ១៦៩សហគមន៍ ហើយបាននិងកំពុងចូលរួមជាមួយមន្ត្រីឧទ្យានុរក្សអភិរក្សធនធានធម្មជាតិនៅតាមតំបន់ការពារធម្មជាតិនានា៕

# «ច្បាប់គ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន» ត្រូវបានដាក់ដំណើរការ

*ដោយ៖ អមរិន្ទ ដានុត*

ប្រមុខរដ្ឋស្តីទី សម្តេចវិបុលសេនាភក្តី សាយ ឈុំ ចុះហត្ថលេខាដាក់ឱ្យប្រើប្រាស់នូវ «ច្បាប់គ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន» នាថ្ងៃពុធទី២៩ ខែមេសា ឆ្នាំ២០២០នេះ។ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្នដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១០ ខែមេសា នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់ទាំងស្រុងកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០។

ច្បាប់នេះមានចំនួន៥ជំពូក និង១២មាត្រា ត្រូវបានរដ្ឋសភា ព្រឹទ្ធសភា និងក្រុមប្រឹក្សាធម្មនុញ្ញអនុម័តជាបន្តបន្ទាប់ត្រឹមរយៈពេលតែមួយខែ។

នៅក្នុងមាត្រា៣បានចែងថា ការប្រកាសដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្នត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ។ ការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្នអាចធ្វើឡើងសម្រាប់ថិរវេលាមិនឱ្យលើសពី៣ខែ។ ថិរវេលានេះអាចត្រូវប្រកាសបន្តបានក្នុងលក្ខខណ្ឌដូចគ្នា។ កាលៈទេសៈដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្នអាចត្រូវបញ្ចប់ទៅវិញដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយប្រធានរដ្ឋសភានិងព្រឹទ្ធសភា កាលបើកាលៈទេសៈពិសេសនេះបានចប់ទៅវិញមុនកាលកំណត់នៃថិរវេលាដែលមានចែងនៅក្នុងព្រះរាជក្រឹត្យទាក់ទងនឹងការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន។

> មន្ត្រីមានសមត្ថកិច្ចដែលប្រើប្រាស់សិទ្ធិអំណាចតាមទំនើងចិត្តដោយរំលោភបំពានខុសពីគោលបំណងនៃច្បាប់នេះ ហើយបង្កការប៉ះពាល់ដល់រូបរាងកាយឬការខូចខាតដល់ទ្រព្យសម្បត្តិរបស់បុគ្គលដទៃត្រូវទទួលខុសត្រូវចំពោះអំពើ ដែលខ្លួនបានប្រព្រឹត្តស្របតាមច្បាប់របស់កម្ពុជា

ច្បាប់នេះក៏បានចែងនូវទោសប្បញ្ញត្តិផងដែរ ដោយយោងមាត្រា៧បានចែងពីបទរាំងដល់កិច្ចប្រតិបត្តិការពេលប្រទេសជាតិស្ថិតក្នុងភាពមានអាសន្នថា អំពើដោយចេតនារាំងឬបង្កឧបសគ្គដល់កិច្ចប្រតិបត្តិការឆ្លើយតបចំពោះភាពអាសន្នត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំដល់ទៅ៥ឆ្នាំ និងពិន័យជាប្រាក់២លានរៀលដល់១០លានរៀល។ ចំពោះអំពើរាំងដល់កិច្ចប្រតិបត្តិការពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ឆ្នាំទៅ ១០ឆ្នាំ កាលបើអំពើនេះនាំឱ្យមានចលាចលជាសាធារណៈឬប៉ះពាល់ដល់សន្តិសុខជាតិ។

ចំពោះមាត្រា៨ដែលចែងពីបទមិនគោរពវិធានការពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្នថា អំពើដោយចេតនាមិនគោរពវិធានការដាក់ចេញដោយរាជរដ្ឋាភិបាលដែលមានចែងក្នុងមាត្រា៥ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែ ទៅ១ឆ្នាំ និងពិន័យជាប្រាក់ពី ១សែនរៀលដល់២លានរៀល។ ដោយឡែកអំពើមិនគោរពតាមវិធានការពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្នត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី២លានរៀលទៅ១០លានរៀល កាលបើអំពើនេះនាំឱ្យមានចលាចលជាសាធារណៈ។

ចំណែកមាត្រា៩ បានចែងពីនីតិបុគ្គលដែលមានចេតនារាំង ឬបង្កឧបសគ្គដល់កិច្ចប្រតិបត្តិការឆ្លើយតបចំពោះភាពអាសន្នត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ដោយត្រូវផន្ទាទោសពិន័យជាប្រាក់ពី ១០០លានរៀល ដល់ ១,០០០លានរៀល ព្រមទាំងទោសបន្ថែមមួយឬច្រើនដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

នីតិបុគ្គលដែលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ដោយត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០លានរៀល ដល់ ៥០០លានរៀល ព្រមទាំងទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

ច្បាប់នេះ ត្រង់មាត្រា១០ ក៏បានចែងពីការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ចថា មន្ត្រីមានសមត្ថកិច្ចដែលប្រើប្រាស់សិទ្ធិអំណាចតាមទំនើងចិត្តដោយរំលោភបំពានខុសពីគោលបំណងនៃច្បាប់នេះ ហើយបង្កការប៉ះពាល់ដល់រូបរាងកាយឬការខូចខាតដល់ទ្រព្យសម្បត្តិរបស់បុគ្គលដទៃត្រូវទទួលខុសត្រូវចំពោះអំពើ ដែលខ្លួនបានប្រព្រឹត្តស្របតាមច្បាប់របស់កម្ពុជា។

ការដាក់ប្រទេសជាតិក្នុងភាពអាសន្ន អាចធ្វើឡើងនៅពេលប្រជាជាតិប្រឈមមុខ នឹងគ្រោះថ្នាក់ជាអាទិ៍, គ្រោះថ្នាក់ដែលបង្កឡើងដោយសង្គ្រាម ឬការឈ្លានពានពីកម្លាំងបរទេស, គ្រោះអាសន្នបន្ទាន់ចំពោះសុខភាពសាធារណៈបណ្តាលមកពីការឆ្លងរាលដាលនៃជំងឺ, ភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងគ្រោះមហន្តរាយធ្ងន់ធ្ងរ ដែលគំរាមកំហែង ឬអាចបង្កគ្រោះថ្នាក់រីករាលដាលដល់កម្រិតទូទាំងប្រទេស៕

# ប្រមុខរាជរដ្ឋាភិបាលកម្ពុជារំលឹកពលរដ្ឋកុំឲ្យភ្លេចខ្លួនរឿងកូវីដ១៩

*ដោយ៖ អមរិន្ទ ដានុត*

សម្តេចតេជោ ហ៊ុន សែន ប្រមុខរាជរដ្ឋាភិបាលកម្ពុជា នៅតែបន្តអំពាវនាវនិងបានផ្ញើសាររំលឹកពលរដ្ឋកុំឱ្យភ្លេចខ្លួននឹងការឆ្លងរីករាលដាលនៃមេរោគកូវីដ១៩ ខណៈដែលក្រសួងសុខាភិបាលបានរាយការណ៍ពីករណីមិនមានការឆ្លងថ្មីនៅក្នុងប្រទេសជាច្រើនថ្ងៃជាប់ៗគ្នាមក។

«ក្នុងប៉ុន្មានថ្ងៃកន្លងមកនេះ នៅក្នុងប្រទេសយើង ទោះបីអត្រាឆ្លងរោគកូវីដ-១៩ មិនបានកើនឡើងខ្លាំងដូចប្រទេសដទៃ ហើយចំនួនអ្នកព្យាបាលដែលបានជាសះស្បើយក៏កាន់តែមានច្រើនពិតមែន ប៉ុន្តែយើងត្រូវមានការប្រុងប្រយ័ត្នជាប់ខ្លួនជានិច្ច ជាពិសេស ត្រូវបង្កើនការប្រុងប្រយ័ត្នទ្វេដង។ ព្រោះមេរោគកូរ៉ូណា២០១៩ (Coronavirus ២០១៩) ដែលយើងហៅថាកូវីដ-១៩ (covid-១៩) ដែលជាជំងឺឆ្លងដ៏កាចសាហាវនេះ គឺពុំទាន់មានថ្នាំព្យាបាលនៅឡើយទេ»។ នេះបើយោងទៅតាមសារដែលសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបង្ហោះនៅលើបណ្តាញសង្គមផ្លូវការរបស់លោក។

សម្តេចតេជោ ហ៊ុន សែន បានបន្តថា ក្នុងប៉ុន្មានថ្ងៃនេះ នៅតាមដងផ្លូវក៏មានការធ្វើដំណើរណែនរកកល់ស្ទះចរាចរណ៍ទៀតផង។ សូមក្រើនរំឭកដល់បងប្អូនប្រជាពលរដ្ឋត្រូវចងចាំនឹងបង្កើនការប្រុងប្រយ័ត្នជាប់ខ្លួនជានិច្ច គឺត្រូវពាក់ម៉ាសការពារ មានទឹកអាល់កុល និងជែលសម្លាប់មេរោគ និងបាក់តេរីផ្សេងៗ ចៀសវាងការចម្លងរោគពីម្នាក់ទៅម្នាក់ដោយសារខ្វះការប្រុងប្រយ័ត្នឬគិតស្រាលៗថាស្រុកយើងមិនអីនោះទេ។

សម្តេចនាយករដ្ឋមន្ត្រីបានសង្កត់ធ្ងន់ថា៖ «បើគ្មានការចាំបាច់ទៅខាងក្រៅផ្ទះទេ សូមកុំទៅ ឬទៅក្នុងចំណោមក្រុមមនុស្សច្រើន គឺអោយតែមេគ្រួសារឬអ្នកដែលចាំបាច់ត្រូវទៅបានហើយ។ សូមបងប្អូនយកការព្រួយបារម្ភ និងភ័យខ្លាចនេះទៅជាការប្រុងប្រយ័ត្នខ្ពស់ជាប្រចាំរាល់ថ្ងៃ ដោយមានអនាម័យរស់នៅល្អ ដើម្បីសុខភាព និងអាយុជីវិតរស់នៅបានយូរអង្វែង»៕

# រដ្ឋមន្ត្រី ម៉ម ប៊ុនហេង៖ «ស្ត្រីមានផ្ទៃពោះត្រូវប្រុងប្រយ័ត្ន និងការពារខ្លួនជានិច្ចពីការឆ្លងជំងឺកូវីដ១៩»

*ដោយ៖ អមរិន្ទ ដានុត*

**ទោះជាអង្គការសុខភាព**ពិភពលោក នៅមិនទាន់រកឃើញនូវភស្តុតាងណាមួយដែលបញ្ជាក់ថា វីរុសកូវីដ១៩ អាចឆ្លងពីម្តាយទៅកូនក្នុងផ្ទៃឬក៏អត់នោះ ប៉ុន្តែក្រសួងសុខាភិបាលនៃប្រទេសកម្ពុជា បានអំពាវនាវដល់ស្ត្រីមានផ្ទៃពោះ ត្រូវប្រុងប្រយ័ត្ន និងការពារខ្លួនជានិច្ចពីការឆ្លងជំងឺកូវីដ១៩។

រដ្ឋមន្ត្រីក្រសួងសុខាភិបាល លោក ម៉ម ប៊ុនហេង បានមានប្រសាសន៍នៅក្នុងសន្និសីទសារព័ត៌មាននៅទីស្តីការក្រសួងកាលពីមុនចូលឆ្នាំខ្មែរថា មកដល់ពេលនេះ នៅមិនទាន់មានករណីស្ត្រីមានផ្ទៃពោះឆ្លងវីរុស កូវីដ១៩នៅឡើយទេក្នុងប្រទេសកម្ពុជា ប៉ុន្តែលោកបានអំពាវនាវឱ្យស្ត្រីមានផ្ទៃពោះទាំងអស់ត្រូវប្រយ័ត្នចំពោះការឆ្លងជំងឺកូវីដ១៩។

លោករដ្ឋមន្ត្រីបានថ្លែងថា៖ «ស្ត្រីមានផ្ទៃពោះជាក្រុមមនុស្សដែលអាចរងគ្រោះដែរ ដូច្នេះត្រូវតែប្រុងប្រយ័ត្នពីបញ្ហានេះ។ ធ្វើម៉េចឱ្យពួកគាត់នៅឆ្ងាយពីគេ ហើយស្វាមីនិងគ្រួសារក៏ត្រូវប្រុងប្រយ័ត្នដែរ ធ្វើយ៉ាងណាកុំឱ្យឆ្លងជំងឺនេះពីអ្នកដទៃ ហើយឆ្លងទៅអ្នកនៅផ្ទះ ព្រោះបើឆ្លងមានអ្នកដែលប្រឈម គឺប្រពន្ធផង កូនដែលនៅក្នុងផ្ទៃផង»។

លោកស្រី Li Ailan តំណាងអង្គការសុខភាពពិភពលោក (WHO) បានឱ្យដឹងថា WHO បាន និងកំពុងផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការប្រមូលទិន្នន័យជុំវិញផលប៉ះពាល់របស់ជំងឺកូវីដ១៩ទៅលើស្ត្រីមានផ្ទៃពោះ ថាតើវាអាចឆ្លងពីម្តាយទៅកូនឬក៏អត់ ប៉ុន្តែបច្ចុប្បន្ន នៅមិនទាន់មានភស្តុតាងណាមួយបញ្ជាក់ពីបញ្ហានេះបាននៅឡើយ។

លោកស្រី Li Ailan ក៏បានមានប្រសាសន៍នៅក្នុងសន្និសីទកាសែតនោះដែរថា៖ «ការការពារខ្លួនពីវីរុសកូវីដ១៩ ជាគន្លឹះដ៏សំខាន់សម្រាប់ស្ត្រីមានផ្ទៃពោះ ដោយពួកគេត្រូវមានវិធានការការពារខ្លួនឯង និងត្រូវរក្សាអនាម័យដូចមនុស្សដទៃទៀត»។

លោកស្រីបានបន្តថា WHO នៅតែបន្តលើកទឹកចិត្តឱ្យមានការបំបៅដោះកូនដោយទឹកដោះ ដោយសារតែមិនទាន់មានភស្តុតាងណាមួយបញ្ជាក់នៅឡើយ ព្រោះវាជាជំងឺថ្មីមួយ ហើយយើងនឹងបន្តស្រាវជ្រាវប្រមូលព័ត៌មាន ឬទិន្នន័យជុំវិញបញ្ហានេះបន្តទៀត»។

ប្រជាពលរដ្ឋទាំងអស់ ត្រូវប្រកាន់ខ្ជាប់នូវការរក្សាអនាម័យល្អ ដូចជាឧស្សាហ៍លាងដៃជាមួយសាប៊ូ និងទឹកស្អាត ឬអាល់កុល ឬទឹកជែលលាងដៃឱ្យបានញឹកញាប់ ប្រើប្រាស់ម៉ាសខ្ទប់មាត់ និងច្រមុះពេលក្អក និងកណ្តាស់ ជៀសវាងការប្រមូលផ្តុំគ្នាច្រើន និងត្រូវអនុវត្តនូវគម្លាតសុវត្ថិភាពនៅរួម និងវិធានការមួយចំនួនទៀត ដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ១៩ ពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតជាចាំបាច់៕



*រដ្ឋមន្ត្រីក្រសួងសុខាភិបាល លោក ម៉ម ប៊ុនហេង និងមន្ត្រីជំនាញ ក្នុងសន្និសីទកាសែតកាពីចុងខែមេសាកន្លងទៅនេះ។ រូបភាព៖ Freshnews*





# អ្នកល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក នឹងត្រូវរងពិន័យប្រាក់កាន់តែច្រើន

*ដោយ៖ អមរិន្ទ ដានុត*




គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកនៃក្រសួងមហាផ្ទៃ បានធ្វើការដាក់ពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចាប់កាលពីដើមខែឧសភា ឆ្នាំ២០២០ កន្លងមកនេះ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្តេចក្រឡាហោម ស ខេង ឱ្យដឹងថា កងកម្លាំងនគរបាលចរាចរណ៍ផ្លូវគោកនឹងអនុវត្តការពិន័យអន្តរការណ៍ចំពោះអំពើល្មើសច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលបានតម្លើងកម្រិតទឹកប្រាក់ពិន័យក្នុងចំនួនពី៣ទៅ៥ដង។

សម្តេចក៏បានលើកឡើងឱ្យដឹងថា៖ «ប្រជាពលរដ្ឋបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ប៉ុន្តែទោះបីជាយើងកត់សម្គាល់ឃើញគ្រោះថ្នាក់ចរាចរណ៍នៅតែមានចំនួនច្រើនគួរឱ្យព្រួយបារម្ភ ធ្វើឱ្យប៉ះពាល់ដល់ជីវភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈ»។

រាជរដ្ឋាភិបាលបានកំណត់យកឆ្នាំ២០២០ជាឆ្នាំនៃការរឹងបន្តឹងការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ដែលមានកំណើនយ៉ាងគំហុកនាឆ្នាំ២០១៩កន្លងមក គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក បានជម្រុញការរឹតបន្តឹងការអនុវត្តច្បាប់យ៉ាងសកម្មនៅទូទាំងប្រទេស បានធ្វើឱ្យគ្រោះថ្នាក់ចរាចរណ៍ថយចុះចំនួន១៥០លើកស្មើ១៤ភាគរយ ចំនួនអ្នកស្លាប់ថយចុះ២០នាក់ ស្មើ៤ភាគរយ និងចំនួនអ្នករបួសថយចុះ២៧៧នាក់ស្មើ១៧ភាគរយ បើប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០១៩។

គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកអំពាវនាវទៅដល់ប្រជាពលរដ្ឋប្រើប្រាស់ផ្លូវត្រូវចូលរួមគោរពច្បាប់ចរាចរណ៍ផ្លូវគោក ដើម្បីការពារអាយុជីវិតខ្លួនឯង និងអ្នកដទៃប្រកបដោយឆន្ទៈភ្ញាក់រលឹកខ្ពស់សំដៅលើកស្ទួយកិត្តិយស សេចក្តីថ្លៃថ្នូរ និងសណ្តាប់ធ្នាប់សង្គមនៅប្រទេសកម្ពុជា៕

# ការអនុវត្តមិនផ្តល់ទិដ្ឋាការបន្តរយៈពេលស្នាក់នៅដល់ជនបរទេស នឹងចាប់អនុវត្តន៍នៅដើមខែកក្កដា

*ដោយ៖ អមរិន្ទ ដានុត*

អគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃនឹងមិនផ្តល់ទិដ្ឋាការបន្តសម្រាប់រយៈពេលនៃការស្នាក់នៅក្នុងប្រទេសកម្ពុជាចំពោះជនបរទេសណាដែលគ្មានឈ្មោះក្នុងប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេសក្នុងប្រទេសកម្ពុជា (FPCS)។

នាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ អគ្គនាយកអន្តោប្រវេសន៍បានបញ្ជាក់ឱ្យដឹងថា ក្នុងគោលដៅជម្រុញអនុវត្តន៍ឱ្យមានប្រសិទ្ធភាពសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ស្តីពីការគ្រប់គ្រងវត្តមានជនបរទេសក្នុងប្រទេសកម្ពុជា (FPCS) អគ្គនាយកដ្ឋានអន្តោប្រវេសន៍នឹងអនុវត្តន៍វិធានការមិនផ្តល់ទិដ្ឋាការបន្តរយៈពេលស្នាក់នៅក្នុងប្រទេសនេះចំពោះជនបរទេសណាដែលគ្មានឈ្មោះក្នុងប្រព័ន្ធ FPCS។



*សកម្មភាពមន្ត្រីអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃចុះ ផ្សព្វផ្សាយការប្រើប្រាស់ ប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេស (FPCS)។ រូបភាព៖ អគ្គនាយកដ្ឋានអន្តោប្រវេសន៍*

លោកបានលើកឡើងឱ្យដឹងដែរថា៖ «ការអនុវត្តមិនផ្តល់ទិដ្ឋាការបន្តរយៈពេលនៃការស្នាក់នៅនេះ នឹងចាប់ផ្តើមអនុវត្តនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០តទៅ»។

អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានស្នើដល់ស្នងការ និងស្នងការរងនគរបាលរាជធានិ-ខេត្តទាំងអស់ធ្វើការផ្សព្វផ្សាយគោលការណ៍ណែនាំដល់ម្ចាស់ឬអ្នកកាន់កាប់លំនៅគ្រប់ប្រភេទឱ្យធ្វើសេចក្តីរាយការណ៍អំពីវត្តមានជនបរទេសដែលបានមកស្នាក់នៅក្នុងលំនៅដ្ឋានគ្រប់ប្រភេទឱ្យធ្វើសេចក្តីរាយការណ៍អំពីវត្តមានជនបរទេសដែលបានមកស្នាក់នៅក្នុងលំនៅដ្ឋានរបស់ខ្លួន ទៅក្នុងប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេសក្នុងប្រទេសកម្ពុជា (FPCS) ដើម្បីទទួលបានការអនុញ្ញាតឱ្យបន្តរយៈពេលស្នាក់នៅ៕



# កម្លាំងនគរបាលចំនួន៣.៩១៩នាក់ និងតាម៥៦៨គោលដៅសម្រាប់អនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក

*ដោយ៖ អមរិន្ទ ដានុត*



*នាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ។ អគ្គស្នងការនគរបាលជាតិ*

កម្លាំងនគរបាលបានចុះអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក នាដើមខែឧសភា ឆ្នាំ២០២០ នៅទូទាំងប្រទេសដែលមានកម្លាំងនគរបាលចំនួន៣.៩១៩នាក់ និងតាម៥៦៨គោលដៅ។

អគ្គស្នងការនគរបាលជាតិ នាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន បានឱ្យដឹងថា អគ្គស្នងការដ្ឋាននគរបាលជាតិបានទទួលបង្កាន់ដៃបង់ប្រាក់ពិន័យចំនួន២៥.០០០ក្បាល ធ្វើការបែងចែកដល់គ្រប់អង្គភាពនគរបាលចរាចរណ៍ផ្លូវគោកទូទាំងប្រទេសរួចរាល់ផងដែរ។

លោកបន្តថា គ្រប់ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត និងនាយកដ្ឋានជំនាញបានកសាងផែនការសកម្មភាពលើការរឹតបន្តឹងអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ២០២០ ដោយបានកំណត់គោលដៅត្រួតពិនិត្យរឹតបន្តឹងច្បាប់ សរុបចំនួន៥៦៨ គោលដៅ ប្រើប្រាស់កម្លាំងសរុប ចំនួន៣.៩១៩នាក់ ក្នុងនោះកម្លាំងនគរបាលចរាចរណ៍មានចំនួន៣.៥០៧នាក់ និងកម្លាំងសហការចំនួន៤១២នាក់ ប្រើប្រាស់មធ្យោបាយចំនួន៣៦៤គ្រឿង (រថយន្ត៦៦គ្រឿង និងម៉ូតូ២៩៨គ្រឿង) បានត្រៀមរួចជាស្រេច រៀបចំទីតាំងរក្សាទុកយានយន្តល្មើសដែលត្រូវឃាត់ទុក និងកែតម្រូវ។

អគ្គស្នងការជាតិបានបើកវគ្គបណ្តុះបណ្តាល បង្កើនសមត្ថភាពជំនាញត្រួតពិនិត្យ និងអន្តរាគមន៍ សីលធម៌ វិន័យ និងផ្សព្វផ្សាយអនុក្រឹត្យលេខ៣៦ អន ក្រ.បក. ដល់មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក ទូទាំងប្រទេសសរុបចំនួន៣.៩៧៨នាក់។ ជាមួយគ្នានេះដែរ អគ្គស្នងការនគរបាលជាតិក៏បានត្រៀមមន្ត្រីគ្រប់អង្គភាពតាមដាន បំភ្លឺ និងឆ្លើយតបនឹងចម្ងល់ ឬប្រតិកម្មនានារបស់ប្រជាពលរដ្ឋដែលពាក់ព័ន្ធដល់ការរឹតបន្តឹងអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក៕





រូបភាព៖ ព្រះសហគមន៍កាតូលិក



រូបភាព៖ ព្រះសហគមន៍កាតូលិក

# កាតូលិក យកចិត្តទុកដាក់ចំពោះអ្នកក្រីក្រខ្វះខាត ពេលកូវីដ១៩ផ្ទុះខ្លាំង

*ដោយ៖លី សុវណ្ណា*

ព្រះសហគមន៍កាតូលិកសន្តីម៉ារីញញឹម ចំការទៀង បានសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋាន នៃឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ បានជ្រើសរើសពលរដ្ឋចំនួន១១០គ្រួសារ ពី១០ភូមិក្នុងឃុំនេះ មួយភូមិ ១១ គ្រួសារ ផ្តល់ជូននូវគ្រឿងឧបភោគបរិភោគ ម៉ាស សាប៊ូ និងថវិកាចំនួន ១០០,០០០ រៀលក្នុងមួយគ្រួសារ ដើម្បីជួយសម្រួលការលំបាករបស់ពួកគាត់ក្នុងគ្រាលំបាកនៃការផ្ទុះឡើងនូវជំងឺឆ្លង កូវីដ១៩។

លោកអភិបាល អូលីវីយេ ជ្មឹតអឺស្លែរ ជាអ្នកផ្តួចផ្តើមសកម្មភាពមេត្តាករុណានេះបានមានប្រសាសន៍ថា នេះជាពេលព្រះសហគមន៍កាតូលិក ចូលរួមលើកទឹកចិត្ត និងធ្វើដំណើររួមជាមួយប្រជាជនយើង ដែលកំពុងមានទុក្ខលំបាក ដោយសារឥទ្ធិពលនៃកូវីដ១៩។ លោកបន្តថា នៅកម្ពុជាមានករណីតិចនៃកូវីដ១៩ តែមានឥទ្ធិពលខ្លាំងលើជីវិតរបស់យើង គ្រួសារខ្លះបាត់ប្រាក់ចំណូល នាំឱ្យមានការលំបាក។

ហេតុនេះ ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ សូមសម្តែងនូវសេចក្តីស្រឡាញ់ សេចក្តីមេត្តាករុណា លើកទឹកចិត្តចំពោះបងប្អូនក្នុងភូមិភាគទាំងមូល។ ថ្ងៃនេះ យើងចាប់ផ្តើមនៅក្នុងភូមិចំការទៀង ព្រះវិហារសន្តីម៉ារីញញឹម។

លោកអភិបាលបញ្ជាក់នៅថ្ងៃទី១៥ ខែមេសានេះថា កម្មវិធីនេះ ចាប់ផ្តើមពីថ្ងៃទី ១៥-១៧ ខែមេសា ឆ្នាំ២០២០ ដោយចែកជូនក្នុងមួយថ្ងៃចំនួនប្រមាណជាង ៣០គ្រួសារ ដើម្បីកុំឱ្យមានការជួបជុំចំនួនមនុស្សច្រើនពេក។

ក្នុងពេលជួបជុំនោះ លោកអភិបាលក៏បានចាត់ចែង រៀបចំដោយយកចិត្តទុកដាក់ខ្ពស់បំផុត ក្នុងការការពារការឆ្លង នៃកូវីដ១៩ ដោយអនុវត្តគម្លាតសុវត្ថិភាពពី ១.៥ម៉ែត្រ ទៅ២ម៉ែត្រ ឱ្យបងប្អូនចូលរួមពាក់ម៉ាស និងលាងទឹកអាកុល តាមការណែនាំរបស់ក្រសួងសុខាភិបាល។

ក្នុងនោះលោកអភិបាលអូលីវីយេក៏បានរំលឹកឱ្យគ្រួសារទាំងនោះយកចិត្តទុកដាក់ អំពីរបៀបទំនាក់ទំនង និងធ្វើជាគំរូក្នុងការអនុវត្តយ៉ាងត្រឹមត្រូវ តាមការណែនាំនានារបស់ក្រសួងសុខាភិបាល ក្នុងការការពារ និងប្រយុទ្ធនឹងមេរោគឆ្លង កូវីដ១៩ កុំឱ្យរីករាលដាលក្នុងសហគមន៍ និងធ្វើឆ្ពោះទៅរកសេចក្តីសុខ និងសេចក្តីសង្ឃឹមក្នុងពេលខាងមុខ។

ក្នុងពិធីនេះដែរ លោកមេភូមិពងទឹកខាងត្បូង តំណាងបងប្អូនទាំងបីភូមិ បានថ្លែងអំណរគុណដល់លោកអភិបាល អូលីវីយេ និងព្រះសហគមន៍កាតូលិកចំការទៀង ដែលបានយកចិត្តទុកដាក់ និង ជួយដល់បងប្អូនខ្វះខាតក្នុងគ្រាលំបាកនេះ។ ក្នុងនោះលោកក៏ផ្តាំឱ្យពលរដ្ឋទាំងអស់ថែរក្សាសុខភាពឱ្យបានល្អគ្រប់ពេលវេលា។

ព្រះសហគមន៍កាតូលិក បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការប្រយុទ្ធ នឹងជំងឺឆ្លង នៃមេរោគកូវីដ១៩ ដោយចូលរួមអប់រំប្រជាជនក្នុងសហគមន៍ បានលុបចោលកិច្ចប្រជុំជាច្រើន បិទសាលារៀន និងពិធីជួបជុំលក្ខណៈប្រមូលផ្តុំ ដែលមានមនុស្សច្រើនតាមការណែនាំរបស់ក្រសួងសុខាភិបាល។ រួមទាំងបុណ្យ ធំសំខាន់បំផុត ដែលរំឭកអំពីទុក្ខលំបាក និងបុណ្យចម្លង ជាបុណ្យរំឭកអំពីព្រះយេស៊ូគ្រីស្ត មានព្រះជន្មរស់ឡើងវិញផងដែរ។ ដោយណែនាំឱ្យបងប្អូនចូលរួមពិធីបុណ្យនានាតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម៕







រូបភាព៖ ព្រះសហគមន៍កាតូលិក





# លោកអភិបាលភូមិភាគភ្នំពេញដាក់ចេញសកម្មភាពថ្មីៗត្រូវអនុវត្តក្នុងអំឡុងពេលនេះ

នាពេលថ្មីៗនេះលោកអភិបាល អូលីវីយេ ជ្មឹតអឺស្លែរ នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបានចេញលិខិតមួយ ដែលជាសេចក្តីណែនាំដល់មណ្ឌលសកម្មភាពនីមួយៗ ការិយាល័យ និងអង្គភាពមួយចំនួនរបស់ព្រះសហគមន៍កាតូលិកនៅក្នុងភូមិភាគនេះ ធ្វើការងារបន្ថែមទៀតលើកិច្ចការមេត្តាករុណា និងពង្រឹងបន្ថែមលើកិច្ចការងារប្រចាំថ្ងៃរបស់ខ្លួន។

ក្នុងលិខិតចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២០ ត្រូវនឹងពិធីបុណ្យគោរពព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ដែលវិទ្យុវើរីតាស់អាស៊ីបានទទួលនៅថ្ងៃនេះ បានឱ្យដឹងថា លោកអភិបាលស្នើសុំឱ្យមានការអធិដ្ឋានប្រចាំថ្ងៃបន្ថែមទៀត ដោយនឹងត្រូវផ្សព្វផ្សាយតាមបណ្តាញសង្គម Youtube, Facebook។

ចំពោះវិស័យអប់រំកាតូលិក ត្រូវពង្រឹងការយកចិត្តទុកដាក់បន្ថែមចំពោះសិស្ស និងនិស្សិតនៃតាមសាលានីមួយៗរបស់ខ្លួន តាមរយៈការសិក្សាពីចម្ងាយ។

រីឯការិយាល័យអប់រំជំនឿ និងគម្ពីរ ភូមិភាគភ្នំពេញជាបន្ទាន់ត្រូវរកមធ្យោបាយដើម្បីមានទំនាក់ទំនង ជួយបងប្អូនដែលកំពុងរៀន ជាពិសេសកំពុងអប់រំជំនឿជំហានទី១ ជំហានទី២ ឬអ្នកដែលកំពុងឈ្វេងយល់ទាំងអស់ ត្រូវរៀបចំឯកសារអប់រំជំនឿខ្លីៗ តាមរយៈ Telegram, Messenger ឬវិធីណាមួយ ដើម្បីឱ្យពួកគាត់អាចចូលរួមជាមួយព្រះសហគមន៍ និងមានអារម្មណ៍ជិតស្និទ្ធ។

ចំណែកការិយាល័យយុវជន និងកុមាររបស់ព្រះសហគមន៍ ត្រូវរៀបចំការបណ្តុះបណ្តាល ការផ្លាស់ប្តូរការជជែកវែកញែក ការចែករំលែកព័ត៌មាន និងឯកសារផ្សេងៗរបស់ព្រះសហគមន៍។

ការិយាល័យផ្សព្វផ្សាយពត៌មានត្រូវបង្កើតជាក្រុមតាមបណ្តាញសង្គមដើម្បីឱ្យព្រះសហគមន៍និងគ្រីស្តបរិស័ទអាចចែករំលែកបទពិសោធនិងសកម្មភាពមេត្តាករុណាដល់គ្នាទៅវិញទៅមក។

ក្នុងនោះដែរ លោកអភិបាលបានស្នើសុំឱ្យ មណ្ឌលសកម្មភាពរបស់ព្រះសហគមន៍នីមួយៗ យកចិត្តទុកដាក់ធ្វើទានចំពោះអ្នកក្រីក្រតាមលទ្ធភាពដែលអាចធ្វើទៅបាន៕



*លោកអភិបាល អូលីវីយេ ជ្មឹតអឺស្លែរ នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។*
*រូបភាព៖ ព្រះសហគមន៍កាតូលិក*

# ព្រះសហគមន៍កំពង់ចាមក្រុងចែកអំណោយប្រជាជនខ្វះខាត

ខណៈពេលនេះ គ្រួសារមួយចំនួនបានបាត់បង់ចំណូលប្រចាំថ្ងៃរបស់ខ្លួន ពិបាករកអាហារទទួលទាន ដោយសារតែកន្លែងការងារខ្លះត្រូវផ្អាកបណ្តោះអាសន្ន ក្នុងអំឡុងពេលកូវីដ១៩នេះ។

ព្រះសហគមន៍កំពង់ចាមក្រុង បានរៀបចំជាអង្ករនិងគ្រឿងហូបចុកខ្លះៗ ដើម្បីចែកជូនដល់គ្រួសារក្រីក្រមួយចំនួន ចាប់ផ្តើមពីដើមខែមេសាមកដល់ពេលនេះមានជាង៣០គ្រួសារ ហើយបានទទួលការឧបត្ថម្ភនេះ៕











## សាសនាធំៗអធិដ្ឋានបួងសួងរួមគ្នាប្រឆាំងមេរោគកូវីដ១៩

មេដឹកនាំសាសនាធំៗទាំងបី នៅខេត្តបាត់ដំបង មានព្រះពុទ្ធសាសនា ព្រះសហគមន៍កាតូលិក និងឥស្លាមសាសនា ជួបជុំគ្នា អធិដ្ឋាន បួងសួងកុំឲ្យមានកូវីដ១៩ រីករាលដាលថែមទៀត និងដើម្បីផ្សព្វផ្សាយការយល់ដឹងអំពីការប្រយុទ្ធប្រឆាំង នឹងមេរោគដ៏កាចសាហាវនេះផងដែរ។ ពិធីជួបជុំនេះប្រារព្ធកាលពីថ្ងៃទី១៤ ខែឧសភា កន្លងទៅ៕

*រូបភាព៖ ស៊ីអេសស៊ី*

# គ្រប់និកាយគ្រីស្តសាសនានៅកម្ពុជា ប្ដេជ្ញារួមគ្នា ទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩

*ដោយ៖ ផល សុផានិត*

ខណៈពេលប្រទេសកម្ពុជាប្រឈមនឹងភាពលំបាកព្រោះវិបត្តិកូវីដ១៩ (COVID-១៩) ស្ថាប័នសាធារណៈរបស់រដ្ឋនិងឯកជន ជាពិសេសគ្រីស្តសាសនាក្នុងប្រទេសកម្ពុជាកំពុងតែរួមដៃគ្នាយ៉ាងជិតស្និត ដើម្បីការពារ ទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺ COVID-១៩។ គ្រីស្តសាសនា ក៏កំពុងតែចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការផ្សព្វផ្សាយខ្លឹមសារអប់រំណែនាំសាសនិករបស់ខ្លួន ដើម្បីអនុវត្តតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល។

ក្នុងសន្និសីទសារព័ត៌មាន ស្ដីពី «បច្ចុប្បន្នភាព នៃការប្រយុទ្ធប្រឆាំងជំងឺ COVID-១៩ របស់សហគមន៍គ្រីស្តសាសនា» ដែលរៀបចំដោយ អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល នៅរសៀលថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០នេះ លោក ដួង សាវង្ស ប្រធានការិយាល័យអប់រំជំនឿនិងជាតំណាងព្រះសហគមន៍កាតូលិកនៅកម្ពុជា បានថ្លែងថា ព្រះសហគមន៍កាតូលិកនៅកម្ពុជា ដែលមានលោកអភិបាលទាំងបីភូមិភាគ បានគោរពតាមការណែនាំនិងវិធានការរបស់រាជរដ្ឋាភិបាលកម្ពុជាពិសេសក្រសួងសុខាភិបាលលើវិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩នៅក្នុងសហគមន៍នៃប្រទេសកម្ពុជា។



*លោក ដួង សាវង្ស ប្រធានការិយាល័យអប់រំជំនឿ និងជាតំណាងព្រះសហគមន៍កាតូលិកនៅកម្ពុជា ថ្លែងនៅក្នុងសន្និសីទសារព័ត៌មាន។ រូបភាព៖ ព្រះសហគមន៍កាតូលិក*

លោក ដួង សាវង្ស បានបន្តថា ៖«ដោយគោរពតាមការណែនាំ របស់រាជរដ្ឋាភិបាលកម្ពុជា ព្រះសហគមន៍កាតូលិកនៅកម្ពុជាបានបិទការជួបជុំនានា នៅតាមព្រះសហគមន៍នៅទូទាំងប្រទេសការិយាល័យកុមារនិងសិក្ខាសាលាជាច្រើនទៀតដើម្បីទប់ស្កាត់ជំងឺកូវីដ១៩នេះ»។

តំណាងព្រះសហគមន៍កាតូលិកកម្ពុជា លោក ដួង សាវង្ស បានបន្តបញ្ជាក់ទៀតថា ដោយមានការណែនាំពីលោកអភិបាលព្រះសហគមន៍កាតូលិកបានចូលរួមផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយរបស់ខ្លួនទាំងព័ត៌មានដំណឹងនិងការបង្រៀនមុខវិជ្ជាផ្សេងៗដល់កុមារយុវសិស្សនិស្សិតគ្រីស្តបរិស័ទនិងប្រជាពលរដ្ឋ។

ស្របគ្នានេះលោកហេង ចេងព្រឹទ្ធបូជាចារ្យជាន់ខ្ពស់នៃគ្រីស្តបរិស័ទបានអះអាងថា គ្រីស្តសាសនិកនៅក្នុងប្រទេសកម្ពុជាបានចូលរួមអនុវត្តវិធានការនិងប្ដេជ្ញាចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩។

លោក ហេង ចេង បានលើកឡើងថា ក្រោយក្រសួងធម្មការនិងសាសនា កោះប្រជុំជាមួយតំណាងសាសនានីមួយៗ គ្រីស្តបរិស័ទដំណឹងល្អបានរៀបចំតាមអ្វីដែលក្រសួងបានកំណត់និងណែនាំដើម្បីផ្សព្វផ្សាយអប់រំបន្តនៅតាមគ្រប់ព្រះវិហារនីមួយៗជាពិសេសគ្រូគង្វាលបូជាចារ្យទាំងអស់ពិសេសការណែនាំរបស់ក្រសួងសុខាភិបាល។

ព្រឹទ្ធបូជាចារ្យជាន់ខ្ពស់ ហេង ចេង បានថ្លែងយ៉ាងដូច្នេះថា៖«គ្រីស្តបរិស័ទយើងស្តាប់នូវអ្វីដែលជាវិធានការរបស់ក្រសួងសុខាភិបាល ហើយយើងស្តាប់វិធានការរបស់ក្រសួងធម្មការនិងសាសនាតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។យើងផ្អាកការថ្វាយបង្គំច្រើនហើយជាពិសេសចាប់ផ្ដើមឱ្យក្រុមជំនុំនីមួយៗយកចិត្តទុកដាក់អំពីការអប់រំដល់សហគមន៍ជុំវិញខ្លួននិងចាប់ផ្ដើមយកចិត្តទុកដាក់ជាមួយប្រជាជនដែលងាយរងគ្រោះពិសេសអ្នករកប្រាក់ចំណូលមិនបានច្រើន»។

ព្រឹទ្ធបូជាចារ្យជាន់ខ្ពស់នៃគ្រីស្តបរិស័ទក៏បានឱ្យដឹងទៀតថាក្នុងខែមេសានេះគ្រីស្តបរិស័ទតែងតែរំលឹកនូវបុណ្យចំនួន២ប៉ុន្តែពិធីបុណ្យនេះមិនត្រូវបានធ្វើឡើងដោយការជួបជុំគ្នាទ្រង់ទ្រាយធំនិងការថ្វាយបង្គំនោះទេគឺដើម្បីគោរពទៅតាមវិធានការណ៍ទប់ស្កាត់របស់រាជរដ្ឋាភិបាលការពារជំងឺCOVID-១៩នៅក្នុងប្រទេសកម្ពុជា។លោកថាពួកគាត់បានបង្វែរមកថ្វាយបង្គំនៅតាមផ្ទះរៀងៗខ្លួនវិញ។

លោកបានអះអាងទៀតថាថ្នាក់ដឹកនាំគ្រីស្តបរិស័ទបានបោះពុម្ពនូវផ្ទាំងផ្សព្វផ្សាយ (Poster)និងផលិតវីដេអូជាច្រើនដើម្បីចែកចាយនិងផ្សព្វផ្សាយទៅតាមព្រះវិហារអំពីអ្វីដែលជាការណែនាំនិងវិធានការអនាម័យប្រចាំថ្ងៃ។ ក្នុងនោះក៏មានការផ្សព្វផ្សាយនៅតាមបណ្ដាញសង្គមនិងវិទ្យុរបស់គ្រីស្តបរិស័ទផងដែរ។



បច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាគិតត្រឹមឆ្នាំ២០១៨មានគ្រីស្តបរិស័ទចំនួន១១៤,៤០២នាក់ក្នុងនោះព្រះសហគមន៍កាតូលិកនៅកម្ពុជាមានព្រះវិហារចំនួន៦៧កន្លែង ស្នាក់ការថ្វាយបង្គំចំនួន៥០កន្លែង សាលារៀនចំនួន៥៩កន្លែង។ ដោយឡែកគ្រីស្តបរិស័ទដំណឹងល្អមានវិហារចំនួន៨២កន្លែង ស្នាក់ការថ្វាយបង្គំចំនួន១,១៣២កន្លែងនិងសាលារៀន៦៦៩កន្លែង៕

ទស្សនាវីដេអូទីនេះ

# ខេម បន្លឺសំលេង ច្រៀងសរសើរតម្កើងព្រះយេស៊ូគ្រីស្ត

*ដោយ៖ អមរិទ្ធ ដានុត*

តារាចំរៀងសម្លេងស្អកវ័យក្មេងដែលអ្នកស្ដាប់ជាយុវវ័យភាគច្រើនស្គាល់ និងចេះច្រៀងបទរបស់គាត់នោះ គឺលោកខេម បានប្រកាសជាសាធារណៈថាគាត់គោរពសាសនាគ្រីស្តដោយលោកបានបន្លឺសម្លេងតាមបទចម្រៀង មួយបទបែបលើកទឹកចិត្តដែលមានចំណងជើងថា(ក្នុងព្រះហស្តទ្រង់) ដែល និពន្ធបទភ្លេងនិងទំនុកច្រៀង ដោយលោកគ្រូ ម៉ម បាណាបាស និងសម្រួលតន្ត្រីដោយលោកគ្រូ ស៊ីវ សុខឿន។

លោកខេមបានសរសេរនៅលើបណ្ដាញសង្គមផ្លូវការរបស់លោក ដោយភ្ជាប់ជាមួយនឹងបទចម្រៀងរបស់លោកថា ពុកម៉ែបងប្អូនធ្លាប់តែស្ដាប់បទចម្រៀងបែបស្នេហាខូចចិត្តពិបាកចិត្តប្រុសក្បត់ស្រី ស្រីក្បត់ប្រុស ប៉ុន្តែពេលនេះលោកចង់បបួលបងប្អូនមកស្ដាប់បទចម្រៀងគ្រីស្ទានមួយបទបែបលើកទឹកចិត្តដែលមានចំណងជើងថាក្នុងព្រះហស្តទ្រង់។

លោកបានបន្តដោយបញ្ជាក់ថា៖«ខ្ញុំបង្ហោះបទចម្រៀងនេះឡើងគឺមានគោលបំណង ចង់លើកទឹកចិត្តទៅដល់ពុកម៉ែបងប្អូនដែលរួមជំនឿក្នុងព្រះជាម្ចាស់ ឱ្យគាត់មានជំនឿរឹងមាំលើព្រះអង្គ នៅក្នុងកាលៈទេសៈដែលកំពុងតែលំបាករាតត្បាតដោយជំងឺដ៏អាក្រក់ហើយត្រូវដឹងថាព្រះនឹងមិនរត់ចោលអ្នកឡើយទោះក្នុងគ្រាណាក៏ដោយ»។

តារាសម្លេងស្អករូបនេះបានលើកឡើងទៀតថា លោកមានបំណងចង់ឱ្យពុកម៉ែបងប្អូនដែលមិនបានស្គាល់ព្រះយេស៊ូគ្រីស្ទបានស្ដាប់នូវបទចម្រៀងលើកទឹកចិត្តនិងស្គាល់ពីការសរសើរតម្កើងព្រះទោះបងប្អូនយល់យ៉ាងណានោះជាសិទ្ធិរបស់បងប្អូន ប៉ុន្តែពុកម៉ែបងប្អូនត្រូវចាំថាអ្នកណាដែលទទួលជឿព្រះជាម្ចាស់ និងបានសេចក្ដីសង្គ្រោះយ៉ាងពិតប្រាកដ។ «សូមព្រះប្រទានពរដល់ពុកម៉ែបងប្អូនទាំងអស់គ្នាទាំងអ្នកជឿ និងអ្នកមិនជឿ» នេះជាការថ្លែងឡើងរបស់លោក ខេម ដែលជាតារាចម្រៀងល្បីក្នុងផលិតកម្មថោន (Town)៕






*បងស្រីកូល្លែត សូសុភីន (ខាងឆ្វេង) វ័យ៧២ឆ្នាំ ដែលបានថ្វាយខ្លួនទៅព្រះជាម្ចាស់ ដោយស្ម័គ្រចិត្ត។ រូបភាព៖ ព្រះសហគមន៍កាតូលិក*

# បងស្រីកូឡេត សូ សូភិន៖ «ជីវិតរបស់ខ្ញុំកុំតែមានព្រះបន្ទូលជួយបំភ្លឺកុំអី មិនដឹងថាត្រូវរស់នៅបែបណានោះទេ»

*ដោយ៖ ឆាក លាំង*

ជាកូនស្រីច្បងក្នុងគ្រួសារគ្រីស្តបរិស័ទ ដែលមានបងប្អូនប្រុសស្រី៦នាក់ រស់នៅក្នុងទី ក្រុង ភ្នំពេញ បងស្រីកូល្លែត សូសុភីន វ័យ៧២ឆ្នាំ ដែលបានថ្វាយខ្លួនទៅព្រះជាម្ចាស់ ដោយស្ម័គ្រ ចិត្តរស់នៅជាដូនជីអស់មួយជីវិតក្នុងក្រុមគ្រួសារបងស្រីឧបការគុណនៅព័រស្ស៊ី។

បងស្រីកូល្លែត សូ សុភីន បានរៀបរាប់ថា ថ្វីត្បិតតែខ្លួនកើតក្នុងគ្រួសារគ្រីស្តបរិស័ទក៏ពិតមែន តែឪពុកម្ដាយមិនសូវចាប់អារម្មណ៍ និងព្រះសហគមន៍នោះឡើយ។ តែបងស្រីតែងតែ ទៅព្រះវិហារជាមួយលោកយាយជារៀងរាល់ថ្ងៃ តែមិនយល់ពីអ្វីទៅថាជំនឿនោះទេ។

បងស្រី ប្រាប់ថា៖ «ទោះជាឪពុកម្ដាយមិនសូវចាប់អារម្មណ៍ និងព្រះវិហារ តែលោកយាយជាគ្រីស្តវិស័ទ និងលោកបូជាចារ្យទទួលខុសត្រូវនៅព្រះសហគមន៍ បានណែនាំឱ្យបងស្រីចាប់អារម្មណ៍ហើយទទួលអគ្គសញ្ញាជ្រមុជទឹកតាំងពីក្មេង»។

ជាបងស្រីជនជាតិខ្មែរមួយរូបដែលទទួលសច្ចានិរន្តរ៍ ហើយបានរស់នៅជាដូនជី ក្នុងក្រុមបងស្រីឧបការគុណក្នុងឆ្នាំ១៩៦៨ បើគិតមកដល់ពេលនេះមានរយៈពេលជាង៥០ឆ្នាំមកហើយនោះបានបន្តឱ្យដឹងថារូបគាត់មិនដែលមានគំនិត ចង់បួសនោះឡើយ គឺចង់រៀបការដូចគ្រួសារគេផ្សេងៗ។ បងស្រីបានចំអន់ឱ្យខ្លួនឯងថា តាំងពីតូច គេថាគាត់មានរូបរាងមិនស្អាត ហើយមានរូបរាងដូចមនុស្សប្រុស ដែលនាំឱ្យគាត់តែងមានអារម្មណ៍មិនសប្បាយចិត្ត។

បងស្រី កូល្លែតបញ្ជាក់ថា៖ «ការចូលរៀនក្នុងសាលាឈ្វេងយល់ជីវិតជាអ្នកបួស គឺធ្វើឡើងដើម្បីតាមចិត្តលោកយាយ ជាមនុស្សម្នាក់ដែល(ខ្ញុំ) បងស្រីស្រលាញ់ខ្លាំង»។

នៅក្នុងរបបប្រល័យពូជសាសន៍ បងស្រីខ្មែររូបនេះ បានភៀសខ្លួនទៅប្រទេសបារាំងដើម្បីសិក្សាបន្តក្នុងក្រុមអ្នកបួស ហើយបានថ្វាយពាក្យសច្ចាលើកដំបូងក្នុងឆ្នាំ១៩៧៨នៅប្រទេសបារាំង។ នៅទីនោះបងស្រី បានសិក្សាអំពីវិជ្ជាពេទ្យ ដោយបម្រើការងារជាគិលានុបដ្ឋាកយិកានៅក្នុងមន្ទីរពេទ្យមួយជាមួយក្រុមបងស្រីឯទៀតៗ។

អង្គុយនៅលើកៅអី ក្នុងផ្ទះមួយដែលមានបងស្រីជាង១០នាក់ នៅក្បែរព្រះវិហារព្រះកុមារយេស៊ូ ស្ថិតក្នុងសង្កាត់បឹងទំពុន រាជធានីភ្នំពេញ បងស្រីជនជាតិខ្មែរ សូ សូភិន បានប្រាប់វិទ្យុ វើរីតាស អាស៊ីភាសាខ្មែរ (RVA Khmer) ថា៖ «បងស្រីពិតជាសប្បាយរីករាយជាមួយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលបានផ្សាភ្ជាប់ជីវិតរបស់បងស្រីផ្ទាល់ជាមួយនឹងព្រះជាម្ចាស់។ ការអធិដ្ឋាននៅជាមួយព្រះជាម្ចាស់ផ្ទាល់ និងអធិដ្ឋានតាមរយៈព្រះនាងម៉ារី បានជួយឱ្យកិច្ចការការងារប្រចាំរបស់ខ្លួន (បងស្រី) ទទួលបានផ្លែផ្កាជាច្រើន និងមានអំណរសប្បាយ»។

បងស្រី កូល្លែត សូ សុភីន បានរៀបរាប់បន្ថែមទៀតថា បទពិសោធក្នុងជីវិតកន្លងមកមានទាំងសប្បាយនិងទុក្ខលំបាកជាច្រើនរាប់មិនអស់ ទាំងជំងឺប្រចាំកាយជាច្រើនមុខ ហើយព្យាបាលស្ទើរមិនជា និងបញ្ហាក្នុងក្រុមគ្រួសារបងប្អូនមិនត្រូវគ្នាជាដើម។ ក្នុងនាមជាបងស្រីធំក្នុងគ្រួសារដែលមានបងប្អូនប្រុសស្រី៦នាក់ ពិតជាពិបាកទទួលយកស្ថានភាពបែបនេះណាស់។

បងស្រីបញ្ជាក់ថា៖ «ជីវិតរបស់ខ្ញុំកុំតែមានព្រះបន្ទូលជួយបំភ្លឺកុំអី មិនដឹងថាត្រូវរស់នៅបែបណានោះទេ ណាមួយខ្លួនមានជំងឺពិបាកក្នុងការព្យាបាល និងបញ្ហាគ្រួសារដែលមិនអាចដោះស្រាយបាន»។

ដល់ពេលវ័យកាន់តែចាស់ បងស្រីបានចូលនិវត្តន៍ពីការងារគិលានុបដ្ឋាកយិការនៅប្រទេសបារាំង ហើយបានវិលត្រឡប់មកប្រទេសកំណើតវិញនៅក្នុងឆ្នាំ២០១០ ក្រោមការជួយជ្រោមជ្រែងរបស់លោកបូជាចារ្យ អ៊ុន សុន។ បងស្រីរំលឹកថាជីវិតរបស់គ្រីស្តបរិស័ទសំខាន់បំផុតគឺ «ការអធិដ្ឋាន»។

គ្រប់ពេលបងស្រីតែងតែជួយរំលឹក និងជំរុញឱ្យយុវជនយុវនារីទាំងអស់ ព្យាយាមអធិដ្ឋាន ជាពិសេសគឺការអធិដ្ឋានតាមរយៈព្រះនាងម៉ារី ព្រោះថាព្រះនាងម៉ារី ជាស្ត្រីទី១ ដែលបានជឿលើព្រះជាម្ចាស់។ ដោយសារជំនឿនេះហើយ ដែលធ្វើឱ្យការអស្ចារ្យផ្សេងៗកើតជារូបរាងនៅលើផែនដីនេះ៕

# ជា សុវណ្ណច័ន្ទបុប្ផា៖ «ខ្ញុំមិនដែលលាក់បាំងអំពីជំនឿរបស់ខ្លួនទៅអ្នកដទៃនោះឡើយ»

*ដោយ៖ ឆាក លាំង*

ព្រះសហគមន៍របស់ព្រះជាម្ចាស់បានធ្វើឱ្យមនុស្សផ្លាស់ប្តូរការប្រតិបត្តិជំនឿ ផ្លាស់ប្ដូរការរស់នៅឬផ្លាស់ប្ដូរការទំនាក់ទំនងគ្នាជាដើម។

កញ្ញា ជា សុវណ្ណច័ន្ទបុប្ផា ជាកូនស្រីច្បងក្នុងគ្រួសារពុទ្ធបរិស័ទមួយដែលមានបងប្អូនប្រុសស្រីចំនួន៥នាក់ រស់នៅទីក្រុងភ្នំពេញ។ កញ្ញាបានស្គាល់សាសនាកាតូលិក ស្គាល់ព្រះសហគមន៍កាតូលិកក្នុងឆ្នាំ២០០០ តាមរយៈអ្នកមីង យូធ្លាប្រកដ ដែលជាគ្រីស្តបរិស័ទ ហើយកញ្ញាបានចូលស្វែងយល់រហូត១២ឆ្នាំ ទើបបានទទួលអគ្គសញ្ញាជ្រមុជទឹក។

គ្រីស្តបរិស័ទវ័យ៣៧ឆ្នាំរូបនេះ បានប្រាប់ថា៖ «សកម្មភាពកិច្ចការមនុស្សរបស់ព្រះសហគមន៍កាតូលិក បានដក់ជាប់ក្នុងចិត្តរបស់ខ្ញុំយ៉ាងជ្រៅ»។

កញ្ញា ជា សុវណ្ណច័ន្ទបុប្ផា ជាកូនស្រីដែលកើតក្នុងគ្រួសារពុទ្ធបរិស័ទដែលបានផ្លាស់ប្ដូរជំនឿខ្លួនឯងខុសពីឪពុកម្ដាយ បងប្អូនរបស់គាត់មកជឿលើសាសនាកាតូលិកពិតជាមិនងាយស្រួលនោះទេ។ មុននឹងក្លាយជាគ្រីស្តបរិស័ទពេញលក្ខណៈតាមអ្វីដែលគាត់បានជ្រើសរើសសម្រាប់ជីវិត គ្រីស្តបរិស័ទរូបនេះបានជួបរឿងរ៉ាវនិងបញ្ហាជាច្រើនរាប់មិនអស់ ជាពិសេសជាមួយក្រុមគ្រួសា។

កញ្ញា សុវណ្ណច័ន្ទបុប្ផា បានប្រាប់ទៀតថា៖ «គេជេរខ្ញុំថាក្បត់ជាតិ ក្បត់សាសនាដែលនាំឱ្យខ្លួនមិនសប្បាយចិត្ត ការមិនសប្បាយចិត្តនេះហើយបានជំរុញឱ្យមានការអធិដ្ឋានជាខ្លាំងសម្រាប់ខ្លួនឯងផ្ទាល់ ដើម្បីឱ្យអ្វីៗដែលខ្លួនកំពង់តែជួបប្រទះបានធូរស្រាល»។

អង្គុយផ្ដល់បទសម្ភាសន៍ជាមួយក្រុមការងារវិទ្យុ វើរីតាស អាស៊ី ជាភាសាខ្មែរ (RVA Khmer ) នៅក្នុងទីតាំងព្រះវិហារសន្តយ៉ូសែប (ផ្សារតូច) កញ្ញា ជា សុវណ្ណច័ន្ទបុប្ផា បានរៀបរាប់ទាំងទឹកមុខរីករាយថា ជីវិតជាគ្រីស្តបរិស័ទរយៈពេលជាង៩ឆ្នាំកន្លងមកនេះ គ្រប់សកម្មភាពទាំងអស់ដែលខ្លួនបានធ្វើជាកំលាំងមួយ ដែលបានមកពីព្រះជាម្ចាស់ ហើយគ្រប់ពេលវេលាព្រះជាម្ចាស់តែងតែជួយការពារកញ្ញាជានិច្ច។

គ្រីស្តបរិស័ទដដែលរូបនេះ ដែលមានឪពុកម្ដាយ បងប្អូនជាពុទ្ធបរិស័ទ ហើយសព្វថ្ងៃកំពុងតែបំពេញការងារនៅក្នុងស្ថាប័នរដ្ឋក្នុងរាជធានីភ្នំពេញ បានលើកឡើងបន្ថែមថា កញ្ញាមិនដែលលាក់បាំងអំពីជំនឿរបស់ខ្លួនទៅអ្នកដទៃនោះឡើយ ទាំងសកម្មភាពក្នុងសង្គម និងការទំនាក់ទំនងផ្សេងៗក្នុងក្រុមគ្រួសារនិងការងារ មានសភាពល្អជាមួយគ្នាទៅវិញទៅមក ទោះបីម្នាក់ៗមានសាសនាខុសគ្នាក៏ដោយ។

កញ្ញាសុវណ្ណច័ន្ទបុប្ផាបានប្រាប់ថា៖ «សព្វថ្ងៃនេះ ក្រៅពីបំពេញការងារក្នុងស្ថាប័នរដ្ឋហើយខ្ញុំតែងតែជួយការងាររបស់ព្រះសហគមន៍ ដោយជួយអប់រំជំនឿក្រុមមនុស្សពេញវ័យជារៀងរាល់ថ្ងៃអាទិត្យឬថ្ងៃផ្សេងទៀត ដែលព្រះសហគមន៍ត្រូវការខ្ញុំ»។



# ជនក្រីក្រ២២០គ្រួសារទទួលអំណោយក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ១៩

*ដោយ៖ ដាលីស*

ក្រុមគ្រួសារជនក្រីក្រ មកពីតំបន់នានាជុំវិញសង្កាត់ភ្នំពេញថ្មី ដែលរងផលប៉ះពាល់ដោយសារជំងឺកូវីត១៩ ចំនួន២២០គ្រួសារ បានទទួលគ្រឿងបរិភោគ ពីក្រុមគ្រួសារព្រះនាងម៉ារីជាទីពំនឹងពំនាក់ (សាលេស៊ាន) នៅភូមិច្រេស សង្កាត់ភ្នំពេញថ្មី រាជធានីភ្នំពេញ។ កម្មវិធីនេះត្រូវបានចែកជាបីថ្ងៃជាប់គ្នា គឺពីថ្ងៃទី៧ ដល់៩ ខែឧសភា ឆ្នាំ២០២០ នេះ។



*រូបភាព៖ ព្រះសហគមន៍កាតូលិក*



*រូបភាព៖ ព្រះសហគមន៍កាតូលិក*

អ្នកគ្រូ មួន អេង ជាអ្នកស្ម័គ្រចិត្តជួយស្វែងរកជនក្រីក្រមកទទួលអំណោយសប្បុរសធម៌នេះ បានឱ្យដឹងថា មុននឹងចែកអំណោយនេះ ពួកយើងបានចុះទៅតាមភូមិ ទៅដល់ផ្ទះរបស់ពួកគាត់ មើលពីស្ថានភាពរបស់ពួកគាត់ដែលពិតជាខ្វះខាតនិងលំបាកពិតមែន។

អ្នកស្រី សោ សារ៉ាន់ ក្នុងវ័យ ៤៤ឆ្នាំ ជាកម្មកររោងចក្រទឹកក្រូចនៅទីក្រុងភ្នំពេញបានឱ្យដឹង ដោយបញ្ហាជំងឺកូរ៉ូណា រោងចក្របានរំសាយកម្មករចោល ហេតុនេះ ហើយគាត់និងស្វាមីគ្មានការងារធ្វើទាំងពីរនាក់ គឺនៅតែផ្ទះមើលកូន និងចូនកាលដើររើសអេតចាយ។



*រូបភាព៖ ព្រះសហគមន៍កាតូលិក*

អ្នកស្រី សារ៉ាន់ បញ្ជាក់ទៀតថា៖ «នៅពេលនេះ ក្រុមគ្រួសារខ្ញុំកំពុងតែទាល់ ហើយរំភើបដែលទទួលបានអំណោយនេះជាលើកទីមួយ និងសូមអរគុណដល់សប្បុរសជនទាំងអស់ ហើយក៏សំណូមពរ សូមឱ្យមានសប្បុរសជន ជួយផ្តល់ឈាមដល់កូនស្រីខ្ញុំដែលកំពុងឈឺ និងត្រូវការឈាមជារៀងរាល់ខែ»។

រីឯលោកស្រី ហាត សាអឹម មានជន្មាយុ៨០ឆ្នាំ បានមានប្រសាសន៍ថា៖ «ពិតជាសប្បាយរីករាយអស់ពីដួងចិត្តតែម្តង ដែលបានអំណោយពីនេះ។ ព្រះជាម្ចាស់ជួយខ្ញុំហើយ បានខ្ញុំបាន»។ លោកស្រីបន្ថែមថា៖ «ខ្ញុំមិនខ្លាចអីទេ ទោះបីមកមួយជំហានស្លាប់ក៏សុខចិត្តមកដែរ ព្រោះខ្ញុំអត់ និងអរគុណរកអ្វីប្រៀបមិនបាន»។

អំណោយទាំងនោះបានមកពីសប្បុរសជននៅប្រទេសសិង្ហបុរី មកជួយជនក្រីក្រនៅប្រទេសកម្ពុជា ប្រមាណជាងមួយពាន់គ្រួសារតាមរយៈក្រុមគ្រួសារព្រះនាងម៉ារីជាទីពំនឹងពំនាក់ ដែលមានវត្តមាននៅកម្ពុជា ក្នុងឱកាសនៃការរីករាលដាលជំងឺកូវីដ១៩ នេះ។ អំណោយទាំងនោះមានដូចជា អង្ករ ទឹកស៊ីអ៊ីវ មី ប្រេងឆា និងត្រីខ។

កម្មវិធីចែកអំណោយនេះ នឹងបន្តធ្វើនៅតាមក្រុមគ្រួសារព្រះនាងម៉ារីជាទីពំនឹងពំនាក់ ក្នុងតំបន់ផ្សេងៗទៀត៕

# អង្គការការីតាសឧបត្ថម្ភគ្រឿងឧបក្ខារពេទ្យដើម្បីបង្ការកូវីដ១៩

*ដោយ៖ ដាលីស*

នៅក្នុងអំឡុងពេលដែលកម្ពុជាកំពុងរកឃើញអ្នកឆ្លងមេរោគកូវីដ១៩ ជាច្រើននាក់ អង្គការការីតាសកម្ពុជា ដែលជាអង្គការរបស់ព្រះសហគមន៍កាតូលិក បានចែកចាយនូវសម្ភារៈពេទ្យនិងខិតបណ្ណផ្សព្វផ្សាយមួយចំនួននៅតាមខេត្ត ដើម្បីឆ្លើយតបបន្ទាន់ចំពោះកិច្ចការបង្ការនិងទប់ស្កាត់នូវជំងឺរាតត្បាតដ៏អាក្រក់មួយនេះ។

តាមរបាយការណ៍របស់អង្គការការីតាស់បានឱ្យដឹងថា អង្គការនេះបានចែកចាយខិតបណ្ណចំនួន៧៥.៣២០ សន្លឹក ផ្តល់ម៉ាស់ចំនួន ៨២០កេស សាប៊ូចំនួន៦៨.៩៧៦ដុំ និងទែរម៉ូម៉ែត្រសម្រាប់វាស់កំដៅចំនួន៣០ ត្រូវបានចែកចាយទៅដល់ប្រជាជនដែលរស់នៅក្នុងតំបន់ក្រីក្រ ជនមានពិការភាព ប្រជាជនតាមជនបទ និងពលករចំណាកស្រុក តាមពន្ធនាគារ តាមមន្ទីរពេទ្យ និងតាមស្ថាប័នរដ្ឋមួយចំនួន។





*រូបភាព៖ ព្រះសហគមន៍កាតូលិក*



*រូបភាព៖ ព្រះសហគមន៍កាតូលិក*

ដោយសារតែវិបត្តិនៃកូវីដ១៩នេះ ប្រជាជនជាច្រើនអត់ការងារធ្វើ ប្រាក់ចំណូលធ្លាក់ចុះ ដែលធ្វើឱ្យសេដ្ឋកិច្ចទាំងក្នុងប្រទេស និងគ្រួសារជាច្រើនរងផលប៉ះពាល់ធ្ងន់ធ្ងរ។ អង្គការការីតាសនឹងមានគម្រោងឆ្លើយតបបន្ថែមទៀតក្នុងគ្រាអាសន្ននេះ ចំពោះជនក្រីក្រនិងគ្រួសាររបស់ពួកគេ ដោយផ្តល់នូវអង្ករ ត្រីខ និងមី សម្រាប់ដោះទ័លរយៈពេលខ្លី។

ជាមួយគ្នានេះ អង្គការការីតាសកម្ពុជាក៏មានគម្រោងនឹងផ្តល់អណ្តូងទឹកស្អាត ផ្តល់ពូជបន្លែ និងសត្វចិញ្ចឹម ដើម្បីជួយបង្កើនជីវភាពកសិករ និងសម្រាប់សន្តិសុខស្បៀងអាហារក្នុងគ្រួសារនិងសហគមន៍៕





# លោកបូជាចារ្យ សួន ហង្សលី៖ «រួមជាមួយព្រះយេស៊ូ នៅជាប់នឹងព្រះអង្គ យើងនឹងបង្កើតផលបានបរិបូរណ៍»





*ដោយ៖ ដាលីស*

នៅក្នុងពិធីបុណ្យគោរពព្រះនាងម៉ារីបង្ហាញខ្លួននៅហ្វាទីម៉ា នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ លោក អូលីវីយេ ស្មិតហស្លេរ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងលោកបូជាចារ្យ សួន ហង្សលី ជាតំណាងពេញសិទ្ធិរបស់លោក បានរួមគ្នាថ្វាយអភិបូជានៅទឹកដីមរណសាក្សីនៅភូមិតាំងគោក ឃុំស្រយ៉ូវ ស្រុកតាំងគោក ខេត្តកំពង់ធំ ដែលមានគ្រីស្តបរិស័ទចូលរួមចំនួន ១០នាក់ និងផ្សាយតាមបណ្តាញសង្គម។



ជារៀងរាល់ឆ្នាំ ព្រះសហគមន៍កាតូលិកតែងតែធ្វើពិធីបុណ្យធំនៅក្នុងខែឧសភា ដើម្បីរំលឹកដល់មរណបុគ្គលដែលបានបូជាជីវិតដោយសារជំនឿនៅក្នុងរបបប្រល័យពូជសាសន៍ប៉ុលពត ដោយមានការចូលរួមពីព្រះសហគមន៍គ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ក្រោមអធិបតីរបស់លោកអភិបាលនៃព្រះសហគមន៍ទាំងបីអង្គ។ ប៉ុន្តែដោយសារ កលយុគនៃកូវីដ១៩ ព្រះសហគមន៍ត្រូវផ្អាកការជួបជុំនេះ តាមការណែនាំរបស់ក្រសួងសុខាភិបាល ដើម្បីការពារនិងបង្ការការឆ្លងនៃមេរោគនេះ។

មុនពេលអភិបូជា លោកអភិបាលអូលីវីយេបានណែនាំឱ្យគ្រីស្តបរិស័ទចាប់អារម្មណ៍អំពីមរណសាក្សី ដូច្នេះថា យើងថ្វាយអភិបូជា នៅលើអាសនៈពិសេស គឺគ្រែ ដែលសាឡាស់ សាឡឹម និងសំរើន ដែលធ្លាប់ថ្វាយអភិបូជាចុងក្រោយលើគ្រែនេះនៅក្នុងសម័យខ្មែរក្រហម ក្នុងឆ្នាំ១៩៧៧។

លោកបន្ថែមថា នេះជាឱកាសមួយដើម្បីនឹករលឹកដល់មរណសាក្សីរបស់យើង ដោយទូលអង្វរព្រះជាម្ចាស់ប្រទានពរដល់ព្រះសហគមន៍របស់យើងទាំងមូល តាមរយៈមរណសាក្សីរួមជាមួយព្រះនាងម៉ារី នៅទីក្រុងហ្វាទីម៉ា ដើម្បីនៅក្នុងរដូវកូវីដ១៩នេះ យើងទទួលអំណោយទានមួយយ៉ាងពិសេស «គឺជំនឿ សេចក្តីស្រឡាញ់ និងសេចក្តីសង្ឃឹម»។

ក្នុងធម្មទេសនា លោកបូជាចារ្យ សួន ហង្សលី បានលើកឡើងពី៣ចំណុចសំខាន់ៗ ដែលមានតាំងពីការសង្គ្រោះរបស់ព្រះបិតា ការរស់នៅរបស់គ្រីស្តបរិស័ទជាប់នឹងព្រះយេស៊ូ និងភាពជាធ្លុងតែមួយក្នុងជំនឿជាគ្រីស្តបរិស័ទ។

## ១. ការសង្គ្រោះរបស់ព្រះបិតា ចំពោះមនុស្សលោកតាមរយៈព្រះយេស៊ូ៖

លោកបូជាចារ្យមានប្រសាសន៍ថា យើងនឹកដល់ព្រះបិតាដែលជាម្ចាស់ចម្ការទំពាំងបាយជូរ ដែលក្នុងគម្ពីរជាតិយូដា គេបានប្រៀបធៀបចម្ការទំពាំងបាយជូរទៅនឹងប្រជារាស្ត្ររបស់ព្រះជាម្ចាស់ គឺប្រជារាស្ត្រអ៊ីស្រាអែលដែលព្រះអង្គបានជ្រើសរើស។

លោកបន្ថែមថា «មានព្យាការីផ្សេងៗណែនាំឱ្យគេស្គាល់ព្រះជាម្ចាស់ និងរៀបចំគម្រោងការណ៍ផ្សេងៗដើម្បីសង្គ្រោះមនុស្សលោក។ ក្រោយមកព្រះបិតាបានចាត់ព្រះបុត្រាឱ្យមកសង្គ្រោះ។ តាមរយៈព្រះយេស៊ូ ព្រះអង្គបានជ្រើសរើសយើងទាំងអស់គ្នាទៅជាប្រជារាស្ត្រថ្មីរបស់ព្រះជាម្ចាស់»។

លោកបូជាចារ្យបញ្ជាក់ថា ព្រះបិតាបានបង្កើតគម្រោងការណ៍នេះសម្រាប់មនុស្សលោក ជាពិសេសសម្រាប់គ្រីស្តបរិស័ទ ឱ្យស្ថិតនៅជាប់ជាមួយព្រះអង្គ ដើម្បីបង្កើតផលផ្លែ។

## ២. របៀបរបស់គ្រីស្តបរិស័ទនៅជាប់ជាមួយព្រះយេស៊ូ៖

លោកតំណាងពេញសិទ្ធិរបស់អភិបាលភូមិភាគភ្នំពេញបន្តថា ក្នុងនាមជាគ្រីស្តបរិស័ទ ដែលព្រះយេស៊ូ បានជ្រើសរើស ត្រូវរិះគិតពិចារណា ដើម្បីឱ្យជីវិតរបស់ខ្លួនជាប់ជាមួយព្រះអង្គដែលជាដើមទំពាំងបាយជូរ។ លោកបន្ថែមថា យើងដឹងថា ក្នុងពេលដែលយើងរស់នៅក្នុងសម័យកូវីដ១៩ យើងអត់មានឱកាសជួបជុំគ្នាបានទេ ប៉ុន្តែ ព្រះសហគមន៍បានទូន្មានយើងឱ្យចូលរួមអភិបូជាពីចម្ងាយបាន «ដោយចិត្តគំនិតរបស់យើង ដោយវិញ្ញាណរបស់យើងដែលចូលរួមក្នុងម៉ោងជាមួយគ្នា ដែលផ្សាយតាមរយៈបណ្តាញឌីជីថលទំនើប [...] ធ្វើឱ្យយើងទាំងអស់គ្នាស្ថិតនៅជាប់ជាមួយព្រះជាម្ចាស់»។

លោកបូជាចារ្យ ហង្សលី បានឱ្យដឹងអំពីលទ្ធផលនៃជំនួបក្រុមលោកអភិបាលទាំងបីកាលពីម្សិលមិញថា «លោកអភិបាលអូលីវីយេបានរំលឹកថា ព្រះសហគមន៍គួររកមធ្យោបាយ ដើម្បីឱ្យគ្រីស្តបរិស័ទរបស់យើង អាចទទួលព្រះកាយដោយផ្ទាល់បាន មិនគ្រាន់តែទទួលតាមផ្លូវវិញ្ញាណប៉ុណ្ណោះ។ នេះមានន័យថា ប្រហែលយើងអាចចែកជាក្រុមតូចៗ ចូលរួមអភិបូជាតាមច្បាប់របស់រដ្ឋាភិបាល ប៉ុន្តែយើងមានមិនលើសពី១០នាក់ អាចចែកមួយថ្ងៃៗ»។

ជាមួយគ្នានេះ លោកបានសង្កត់ធ្ងន់ថា «ព្រះកាយព្រះគ្រីស្តនៅក្នុងអគ្គសញ្ញាអរព្រះគុណនេះ ដែលជាអាហារម្យ៉ាង ដែលធ្វើឱ្យយើងមានជីវិតជាប់ជាមួយព្រះយេស៊ូដែលជាដើមទំពាំងបាយជូរ ដើម្បីឱ្យយើងបង្កើតផលផ្លែបានច្រើន»។

## ៣. ការរួបរួមគ្នារបស់គ្រីស្តបរិស័ទ៖

លោកបូជាចារ្យបន្ថែមត្រង់ចំណុចនេះថា ពេលណាយើងនិយាយអំពីការជាប់ជាមួយដើម យើងនិយាយអំពីការរួបរួមគ្នារបស់ព្រះសហគមន៍ ការឯកភាពជាអង្គតែមួយរបស់យើងទាំងអស់គ្នា។ យើងជាគ្រីស្តបរិស័ទដែលមានសម្តេចប៉ាប មានលោកអភិបាល លោកបូជាចារ្យ ព្រមទាំងអស់អ្នកដែលបំពេញមុខងារសំខាន់ៗ ក្នុងព្រះសហគមន៍ និងគ្រីស្តបរិស័ទទាំងអស់។ ដោយព្រះសហគមន៍មានរចនាសម្ព័ន្ធច្បាស់លាស់ នាំឱ្យយើងមានការរួបរួមគ្នាជាអង្គតែមួយជាមួយព្រះគ្រីស្ត។

លោកបូជាចារ្យបញ្ជាក់ទៀតថា លោកអភិបាល ឆ្មារ សាឡាស់ លោកឆ្មារ សាឡឹម លោក ទ្រឿង សំរើន ជាគំរូនៃបុព្វបុរសនៃជំនឿរបស់យើងនៅប្រទេសកម្ពុជា។ ពេលនឹកដល់ពួកគាត់ គឺយើងជាប់នឹងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា និងព្រះសហគមន៍សកល។

លោកលើកអំពីគំរូអស់លោក ដែលបានខិតខំអស់ពីសមត្ថភាពដើម្បីពង្រឹងជំនឿរបស់ខ្លួន និងគ្រីស្តបរិស័ទឯទៀតៗ ទោះបីអស់លោកអាចរត់គេចពីការបៀតបៀនក៏ដោយ។

លោកបន្តថា៖ «អស់លោកមានឱកាសចាកចេញពីប្រទេសកម្ពុជា ប៉ុន្តែអស់លោកបានសុខចិត្តរស់នៅក្នុងប្រទេសនេះ ដោយរួមស្លាប់ជាមួយហ្វូងចៀមរបស់ព្រះជាម្ចាស់ ហើយបានបូជាជីវិតមែន។ អស់លោកព្យាយាមស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងព្យាយាមថ្វាយអភិបូជា ដែលមានគ្រែនេះជាទីសម្គាល់ និងជាសាក្សីសម្រាប់យើង សម្រាប់បន្តជំនឿឱ្យយើង និងពង្រឹងជំនឿយើង»។

«ខ្ញុំគិតថា នេះជាគំរូមួយពិសេសដើម្បីឱ្យយើងជាគ្រីស្តបរិស័ទនៅប្រទេសកម្ពុជាដែលយើងមានការលំបាក ឱ្យយើងព្យាយាមតទៅមុខទៀត ចូលរួមព្យាយាមអធិដ្ឋាន ស្តាប់ព្រះបន្ទូល ចូលរួមអភិបូជាពីចម្ងាយ ដើម្បីឱ្យជីវិតរបស់យើងបានជាប់ជាមួយព្រះជាម្ចាស់ ដើម្បីឱ្យយើងបង្កើតផលផ្លែ»។

យើងក៏មានគំរូមួយទៀតគឺការបន្តប្រគល់ខ្សែកឈើឆ្កាងរបស់លោកអភិបាលពីមួយជំនាន់ទៅមួយជំនាន់ រហូតមកដល់ពេលនេះ ជាប្រវត្តិសាស្ត្រ និងជាការបង្ហាញឯកភាពរបស់ព្រះសហគមន៍របស់យើង។ «សូមឱ្យយើងក្នុងកាលៈទេសៈពិបាក ឱ្យជាប់ជាមួយព្រះសហគមន៍ ជាប់ជាមួយអ្នកដឹកនាំព្រះសហគមន៍ យើងសង្ឃឹមថា យើងអាចបង្កើតផលផ្លែ។ ហើយផលផ្លែរបស់យើងគឺការអធិដ្ឋាន ការសម្តែងព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ដែលយើងជួបសព្វថ្ងៃជាពិសេសក្នុងពេលកូវីដ១៩ [...] ដើម្បីឱ្យមនុស្សលោកលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់»។



*រូបភាព៖ ព្រះសហគមន៍កាតូលិក*

មុនបញ្ចប់ពិធីថ្វាយអភិបូជា លោកអភិបាលអូលីវីយេ បានរំលឹកអំពីសក្ខីភាពមួយចំនួនរបស់ព្រះនាងម៉ារីនៅទីក្រុងហ្វាទីម៉ា ទាក់ទងនឹងសម្តេចប៉ាបយ៉ូហានប៉ូលទី២ ដែលត្រូវបានគេធ្វើឃាតនៅថ្ងៃបុណ្យរំលឹកនេះ តែមិនប៉ះពាល់ដល់ជីវិត និងសក្ខីកម្មមួយទៀតពីលោកបូជា សួន ហង្សលី ផ្ទាល់ដែលមានគ្រោះថ្នាក់ចរាចរណ៍តែ មិនមានអ្វីកើតឡើង ដោយសារលោកបានដឹករូបសំណាកព្រះនាងម៉ារីនៅហ្វាទីម៉ារួមដំណើរជាមួយ ហើយរូបសំណាកនោះត្រូវបានដាក់បណ្តោះអាសន្ននៅតាមព្រះសហគមន៍ជាច្រើនរហូតមកដល់ពេលនេះ គឺនៅព្រះសហគមន៍តាំងគោក តម្កល់លើឡគ្រែ ដែលជាអសនៈរបស់លោកអភិបាល ឆ្មារ សាឡាញ់រួមនឹងសហការីថ្វាយអភិបូជាចុងក្រោយ។

លោកមានប្រសាសន៍ទៀតថា «ខ្ញុំសូមអញ្ជើញបងប្អូនរួមជាមួយព្រះនាងម៉ារីនៃទីក្រុងហ្វាទីម៉ា គឺ ត្រូវយកព្រះកាយជាអាទិភាពក្នុងជីវិតរបស់យើង ត្រូវតាំងព្រះកាយព្រះគ្រីស្ត ដើម្បីបូជាជីវិតរបស់យើងរួមជាមួយព្រះជាម្ចាស់។ យកពេលធ្វើជីវិតទាំងស្រុងទៅលើព្រះបេះដូងព្រះនាងព្រហ្មចារីម៉ារី និងឱ្យយើងទៅជាសាក្សីនៃធម៌មេត្តាករុណាព្រះជាម្ចាស់»។

ក្នុងពេលនេះ លោកអភិបាលអូលីវីយេ ថ្វាយពាក្យអង្វរទៅព្រះនាងម៉ារី សម្រាប់ពិភពលោក សម្រាប់ប្រទេសកម្ពុជា សម្រាប់ប្រជាជន អ្នកជំងឺ និងគ្រូពេទ្យទាំងអស់ក្នុងបរិបទ នៃកូវីដ១៩នេះ៕

# សម្តេចប៉ាបអធិដ្ឋានសូមឲ្យបញ្ចប់ការរីករាលដាលនៃមេរោគវីរុសកូវីដ១៩




សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ សូមឱ្យទាំងអស់គ្នាអធិដ្ឋានបួងសួងឱ្យខែឧសភាជាថ្ងៃបញ្ចប់ការរីករាលដាលនៃមេរោគកូវីដ១៩។ នេះបើតាមសេចក្តីរាយការណ៍របស់វ៉ាទីកង់ញូវ។

ប្រភពដដែលបានរាយការណ៍ថា សម្តេចប៉ាបបានស្នើសុំជាថ្មីម្តងទៀត ឱ្យប្រជាពលរដ្ឋគ្រប់ជំនឿ រួបរួមគ្នាអធិដ្ឋាន និងបួងសួង ក៏ដូចជាខិតខំធ្វើការតាមជំនាញ សូម្បីតែការងារមនុស្សធម៌ ធ្វើយ៉ាងណាឱ្យខែឧសភានេះ ជាថ្ងៃដែលលែងមានការឆ្លងកូវីដ១៩។

ប្រភពដដែលបានឱ្យដឹងថា នេះគឺជាការអំពាវនាវរបស់សម្តេចប៉ាប នៅក្នុងពេលបង្ហាញវត្តមាន នៅក្នុងសាវនាការប្រចាំសប្តាហ៍មួយ ដែលនៅក្នុងអំឡុងពេលនោះ គណៈកម្មការជាន់ខ្ពស់ទទួលបន្ទុកភាតរភាពមនុស្សជាតិ បានប្រកាសថា ថ្ងៃទី១៤ ខែឧសភា ក៏ជាថ្ងៃនៃទិវាអធិដ្ឋានផងដែរ។

សម្តេចប៉ាបបានថ្លែងថា៖ « ការអធិដ្ឋានគឺជាមធ្យោបាយមួយដើម្បីទំនាក់ទំនងនិងស្តាប់ការណែនាំពីព្រះជាម្ចាស់។ តាមស្មារតីនេះ ខ្ញុំសូមស្វាគមន៍នូវរាល់ការអញ្ជើញរបស់គណៈកម្មាធិការជាន់ខ្ពស់ទទួលបន្ទុកភាតរភាពមនុស្សជាតិ ប្រកាសយកថ្ងៃថ្ងៃទី១៤ ខែឧសភា ជាថ្ងៃអធិដ្ឋានជំរុញការងារ និងលើកកម្ពស់ការងារមនុស្សធម៌»។

សម្តេចប៉ាបបានអញ្ជើញ និងលើកទឹកចិត្តឱ្យគ្រប់គ្នា ចូលរួមព្រឹត្តិការណ៍នេះ។ សូមឱ្យយើងទាំងអស់គ្នារួបរួមគ្នា ជាបងប្រុសបងស្រី ដើម្បីសូមឱ្យព្រះជាម្ចាស់ជួយសង្គ្រោះមនុស្សជាតិពីការឆ្លងរីករាលដាលនៃជំងឺ ដើម្បីបំភ្លឺផ្លូវអ្នកវិទ្យាសាស្ត្រនិង ដើម្បីព្យាបាលអ្នកជំងឺ។ សូមឱ្យព្រះជាម្ចាស់ប្រទាននូវទឹកព្រះពរសម្រាប់យើងម្នាក់ៗ ហើយនឹងការពារយើងពីបណ្តាសារទាំងឡាយ៕




# ព្រះសហគមន៍កាតូលិកនៅអ៊ីតាលីថ្វាយអភិបូជាវិញចាប់ពីខែឧសភាតទៅ

ព្រះសហគមន៍កាតូលិកនៅក្នុងប្រទេសអ៊ីតាលីបានអនុញ្ញាតឱ្យរៀបចំពិធីថ្វាយអភិបូជាឡើងវិញ ចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ តទៅ។ នេះបើយើងតាមការផ្សព្វផ្សាយរបស់បណ្តាញព័ត៌មាន វ៉ាទីកង់ញូវ ។

ប្រភពដដែលបានឱ្យដឹងថា ក្រៅពីពិធីថ្វាយអភិបូជាត្រូវបានឱ្យធ្វើវិញនោះ ប្រជាពលរដ្ឋក៏អាចនឹងរៀបចំពិធីផ្សេងៗ បានរួមទាំងពិធីរៀបអាពាហ៍ពិពាហ៍ ពិធីជ្រមុជទឹក និងពិធីបុណ្យសព។

ប្រភពដដែលបានបន្តថា ពិធីទាំងអស់នេះអាចរៀបចំឡើងបាន ប៉ុន្តែត្រូវតែធានា គន្លាតសង្គម និងវិធានការសុវត្ថិភាពអនាម័យត្រូវតែប្រកាន់ដោយតឹងតែងបំផុត។

ការប្រកាសបែបនេះ គឺបានកើតឡើងក្រោយពេលដែលពិធីសារមួយត្រូវបានចុះហត្ថលេខាដោយលោកកាឌីណាល់ ហ្គាល់ត្បៀរ៉ូ ប្រធានក្រុមគណៈអភិបាលនៃព្រះសហគមន៍អ៊ីតាលី នាយករដ្ឋមន្ត្រីអ៊ីតាលី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនៃប្រទេសនេះ កាលពីថ្ងៃទី០៧ ខែឧសភា កន្លងទៅថ្មីៗនេះ។

ក្រោយពេលដែលប្រទេសអ៊ីតាលីបានរងគ្រោះនឹងមហាវិបត្តិនៃការរីករាលដាលនៃមេរោគកូវីដ១៩ ព្រះសហគមន៍កាតូលិកនៅក្នុងប្រទេសអ៊ីតាលី បានរៀបចំនូវពិធីថ្វាយអភិបូជាតាមអនឡាញ និងការអធិដ្ឋានដោយឯកជននៅតាមផ្ទះមកអស់រយៈពេល២ខែមកហើយ។

នៅក្នុងអំឡុងពេលនៃការរីករាលដាលនោះ មេរោគវាបានសម្លាប់ជីវិតមនុស្សប្រមាណជា ៣០.០០០ នាក់ នៅក្នុងប្រទេសអ៊ីតាលី ហើយគ្រប់សកម្មភាពសាសនាទាំងអស់រួមទាំងពិធីថ្វាយអភិបូជា រៀបការ និងបុណ្យសព ព្រមទាំងពិធីជ្រមុជទឹកត្រូវបានហាមឃាត់ផងដែរ៕

# សម្តេចប៉ាបផ្តល់កិត្តិយសដល់គិលានុបដ្ឋាយិកា និងពេទ្យឆ្មប

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា គិលានុបដ្ឋាយិកានិងគ្រូពេទ្យឆ្មបទាំងអស់គួរតែជាសន្តបុគ្គលដែលនៅជិតអ្នកត្រូវការបំផុត។ នេះបើតាមសេចក្តីរាយការណ៍របស់វិទ្យុវ៉ាទីកង់ញូវ(?)/វិទ្យុវេរីតាសអាស៊ី។

សម្តេចប៉ាបបានផ្តល់កិត្តិយសដល់គិលានុបដ្ឋាយិកានិងឆ្មបដោយហៅពួកគេថាជា "អាណាព្យាបាលនៃជីវិត" និង" សន្តបុគ្គលដែលនៅជិតនឹងអ្នកដែលត្រូវការបំផុត" នៅពេលដែលពួកគេបានយកជីវិតរបស់ពួកគេដាក់នៅចំកណ្តាលនៃការឆ្លងរាលដាលនៃវីរុសកូវីដ១៩។

នៅក្នុងសាររបស់សម្តេចប៉ាបសម្រាប់ទិវាគិលានុបដ្ឋាកអន្តរជាតិនៅថ្ងៃទី ១២ ខែឧសភា សម្តេចប៉ាបបានសង្កត់ធ្ងន់ថា" គិលានុបដ្ឋាយិកាគឺជារូបសំណាកនៃព្រះវិហារ ជាមន្ទីរពេទ្យនៅទីវាលនៃសេចក្តីត្រូវការ ដែលកំពុងបន្តបំពេញបេសកកម្មរបស់ព្រះយេស៊ូ"។

សម្តេចប៉ាបក៏បានលើកឡើងពីសារៈសំខាន់ជាមូលដ្ឋាននៃតួនាទីរបស់គិលានុបដ្ឋាយិកា និងឆ្មប ដោយសង្កត់ធ្ងន់នឹងលើកទឹកចិត្តថា ការធ្វើជាគិលានុបដ្ឋាយិកាគឺមិនត្រឹមតែជាការបំពេញការងារដើម្បីតែអាជីពប៉ុណ្ណោះទេ។

សម្តេចប៉ាបបាននិយាយថា ការថែទាំអ្នកជំងឺគឺគេអាច ហៅថាជាការបម្រើកិច្ចការមួយប្រកប ដោយវីរភាព ដែលអាចនឹងលះបង់សូម្បីតែដល់អាយុជីវិតក៏ដោយ៕

សូមចុចនៅទីនេះ

# ការីតាសកម្ពុជាផ្តល់សម្ភារបរិក្ខាពេទ្យជូនសាសនានានា

នាព្រឹកមិញនេះព្រះសហគមន៍កាតូលិក ដែលមានតំណាងអង្គការការីតាសកម្ពុជា បាននាំយកសម្ភារពេទ្យត្រៀមបង្ការ និងទប់ទល់មេរោគកូវីដ១៩ ទៅថ្វាយ សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួ គ្រី ជាសម្តេចព្រះមហាសង្ឃរាជគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា និងប្រគេនចំពោះព្រះសកលវិទ្យាធិការ នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ព្រមទាំងជូនដល់គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា។

កម្មវិធីនេះដឹកនាំដោយលោកបូជាចារ្យកាតូលិក សួន ហង្សលី រួមជាមួយបុគ្គលិករបស់អង្គការការីតាសកម្ពុជា។

លោកបូជាចារ្យសួន ហង្សលី ជាតំណាងពេញសិទ្ធិលោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញមានប្រសាសន៍ថា ការថ្វាយ ប្រគេន និងចែកជូនបរិក្ខាអនាម័យទាំងនេះ គឺដើម្បីបង្ហាញសាមគ្គីភាពរវាងសាសនា និងសាសនានៅក្នុងប្រទេសកម្ពុជា និង«ចូលរួមជាមួយរដ្ឋាភិបាល ដើម្បីទប់ស្កាត់មេរោគក្លូវីណា ឆ្លងរីករាលដាលនៅក្នុងប្រទេសកម្ពុជា ហើយយើងកំពុងភ័យខ្លាចនឹងអាចកើតរលកទី២ដែលនាំឱ្យមានគ្រោះថ្នាក់ច្រើនជាងទៀត»។

លោកបូជាចារ្យបន្តថា៖ «ខ្ញុំគិតថា សម្ភារនេះអាចជួយដល់ប្រជាពលរដ្ឋនៅក្នុងប្រទេសយើងខ្លះៗ មានផ្ទាំងស្នើ (ផ្ទាំងខិត្តបណ្ណ) ផ្សព្វផ្សាយពីវិធីការពារ អាល់កុលលាង ជាសម្ភារតិចតួច តែយើងចូលរួមជាមួយគ្នា»។

សម្ភារបរិក្ខាពេទ្យទាំងនោះរួមមានម៉ាស់ចំនួន១០០ប្រអប់ ទឹកអាល់កុល ៨០លីត្រ សាប៊ូដុំ ២០១៦ដុំ និងខិត្តបណ្ណផ្សព្វផ្សាយ ៤០០ផ្ទាំង ត្រូវបានប្រគេន និងចែកជូននូវចំនួនទាំងនេះស្មើៗគ្នានៅតាមកន្លែងនីមួយៗ។

នេះជាកម្មវិធីលើកទី៣ហើយ ដែលការីតាសកម្ពុជាក្នុងនាមជាព្រះសហគមន៍កាតូលិកបានចែកនូវសម្ភារទាំងនេះ មិនត្រឹមតែក្នុងទីក្រុងប៉ុណ្ណោះទេ គឺមានតាមបណ្តាខេត្តក្រុងមួយចំនួនថែមទៀត ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃមេរោគកូវីដ១៩នេះនៅក្នុងប្រទេស៕








# តើអ្នកមានអារម្មណ៍យ៉ាងណាពេលគ្មានអភិបូជា?

**លោកបូជាចារ្យ ឆាល លិធិប៉ាន**
**នៅទីរួមខេត្តតាកែវ**

តាំងពីមានជំងឺកូវីដ១៩ ខ្ញុំមានអារម្មណ៍ថា អត់សប្បាយទេ។ ខ្ញុំនៅផ្ទះ បងប្អូនអត់សូវមកអភិបូជា ហើយនាំឱ្យលោកពុកអត់សប្បាយ។ ហើយណាមួយទៀត។ សព្វថ្ងៃលោកពុកទៅ សួរសុខទុក្ខបងប្អូនតាមព្រះសហគមន៍នីមួយៗ ថ្វាយអភិបូជាសម្រាប់ពីរបីនាក់ ហើយទៅចែកចាយព្រះកាយព្រះគ្រីស្តសម្រាប់បងប្អូនដែលមានជំងឺផ្សេងៗ ចែកអំណោយដែរឱ្យគេ។ អានេះ បានរំលឹកថា ខ្ញុំត្រូវទៅសួរសុខទុក្ខបងប្អូនជាជាងឱ្យបងប្អូនមកកន្លែងខ្ញុំវិញ។ សព្វថ្ងៃលោកពុកបានយកចិត្តទុកដាក់អធិដ្ឋានជាច្រើនឱ្យបងប្អូនជាពិសេសដែលជួបជំងឺហ្នឹង ទោះបីនៅកម្ពុជា ឬនៅក្រៅប្រទេស។





**លោក ជីវ សុខនឿន គ្រីស្តបរិស័ទនៅកំពង់ចាមក្រុង**

អត់មានអភិបូជា ដូចជាដាច់អាហារម្យ៉ាង បាត់ភាពជិតស្និទ្ធនៅក្នុងព្រះសហគមន៍ ហើយដូចព្រះសហគមន៍បែកគ្នាម្យ៉ាង ដែលយើងធ្លាប់ស្វាគមន៍គ្នា ដែលនាំ ឱ្យអារម្មណ៍ដូចជាឯកោ។ បញ្ហាដែលកើតមាននេះ ធ្វើឱ្យខ្ញុំដូចជាមានកម្លាំងម្យ៉ាងនៅក្នុងក្រុមគ្រួសារ មានឱកាសអធិដ្ឋានរួមគ្នាចូលរួមអភិបូជាតាមរយៈការLive វិដេអូ ពេលខ្លះជាមួយសម្តេចប៉ាប។ ខ្ញុំព្យាយាមផ្សារភ្ជាប់ជីវិតខ្លួនឯងនឹងព្រះសហគមន៍និងព្រះយេស៊ូ តាមរយៈទង្វើផ្សេងៗប្រចាំថ្ងៃ៕



**លោកអភិបាលអន់តូនីសាមី ស៊ូសៃរាជ្យ**
**នៅកោះរការ –កំពង់ចាម**

ការបិទព្រះសហគមន៍ទូទៅជាងមួយខែមកហើយដោយសារកូវីដ១៩ យើងទាំងអស់គ្នានៅស្ងៀមស្ងាត់នៅកន្លែងរៀងៗខ្លួន។ ពេលខ្ញុំអធិដ្ឋានផ្តាំមួយ ខ្ញុំមានអារម្មណ៍ថា ខ្ញុំមិនឯកោទេ។ ទាំងសម្តេចប៉ាបនៅទីក្រុងរ៉ូម ទាំងលោកប្រ៊ុយណូនៅក្រុងកំពង់ចាម ទាំងព្រះសហគមន៍តូចរបស់យើងគ្រប់ទីកន្លែង គ្រាន់តែយើងចូលរួមដោយម្នាក់ឯង ប៉ុន្តែរួមជាមួយគ្នាជាព្រះសហគមន៍។

ខ្ញុំថ្វាយអភិបូជានៅក្នុងបន្ទប់ខ្ញុំ នៅខាងលើជាមួយយុវជនយុវនារី និងអ្នកដែលធ្វើការសួនច្បារ សរុបទាំងអស់ប្រហែល១០នាក់អភិបូជាដូចធម្មតា។ ខ្ញុំចាប់អារម្មណ៍ពិសេស ខ្ញុំមានពេលទំនេរច្រើន អានព័ត៌មានតាមអ៊ីនធឺណេត។

ខ្ញុំមានពេលស្រាវជ្រាវ សម្រាប់ពន្យល់ព្រះគម្ពីរក្រោយមកខ្ញុំសួរគេ គេចែកយោបល់ខ្លះៗ។ នេះជាឱកាសពិសេសឱ្យយើងចូលរួមសកម្មតាមរបៀបរៀងៗខ្លួន នាំឱ្យយើងមិននៅឯកោទេ។ ក្នុងពេលមួយយើងទៅសួរសុខទុក្ខ និងធ្វើផ្ទះតូចមួយសម្រាប់គ្រួសារក្រីក្រ។ រយៈពេលពីរថ្ងៃ ក្រុមយុវជនរបស់យើងបានធ្វើពលកម្មសាងសង់ផ្ទះ។ ហើយយើងបានកែសម្រួលពាក្យក្នុងសៀវភៅអភិបូជាពណ៌ក្រហមរបស់យើងរួចរាល់ហើយ។



**បងស្រី អេង សារិន ដូនជីសាលេស៊ានដុនបូស្កូ នៅភ្នំពេញ**

ដំបូងយើងមានអារម្មណ៍ថាពិបាកដែរ ធ្វើអភិបូជាផ្ទាល់ជាមួយលោកពុក ហើយឥឡូវនេះ ចាប់ផ្តើមអត់មាន ធ្វើឱ្យយើងមានអារម្មណ៍ថា អភិបូជារបស់យើងវាស្ងួត (តាមអនឡាញ) ប៉ុន្តែយើងក៏សុខចិត្តទទួល ហើយយើងក៏ព្យាយាមពង្រឹងផ្លូវវិញ្ញាណរបស់យើងដោយទំនាក់ទំនងជាមួយព្រះយេស៊ូទោះបីមិនបានទទួលព្រះកាយនិងព្រះលោហិត។ ជារៀងរាល់ថ្ងៃជីវិតក្នុងក្រុមអ្នកបួសរស់ច្រើនជាមួយកូនសិស្ស ប៉ុន្តែពេលនេះយើងអត់មាន យើងមានពេលវេលាអធិដ្ឋានច្រើន យើងតាំងព្រះកាយព្រះគ្រីស្តអធិដ្ឋានតាមព្រះហឫទ័យមេត្តាករុណារបស់ព្រះយេស៊ូសម្រាប់អស់អ្នកជំងឺ អ្នកស្លាប់ រងទុក្ខលំបាក ឈឺចាប់ក្នុងពេលវេលាហ្នឹង យើងក៏ថ្វាយទៅព្រះជាម្ចាស់។



**លោកបូជាចារ្យហ្សេរណាន់ដូ អារ៉ាំងហ្គោ នៅទីរួមខេត្តតាកែវ**

ក្នុងរយៈពេលជាងមួយខែកន្លងមកនេះ ខ្ញុំមានអារម្មណ៍ពិបាកចិត្ត។ ខ្ញុំមានអារម្មណ៍ថា ព្រះសហគមន៍ក៏ដូចជាបងប្អូន កំពុងតែណែនាំឱ្យយើងមានបទពិសោធន៍សារជាថ្មីទៀត ឱ្យយើងគិតសារជាថ្មី ក្នុងការបន្តបម្រើព្រះសហគមន៍ កាន់តែល្អប្រសើរជាង។ នៅពេលខ្ញុំថ្វាយអភិបូជាតែម្នាក់ឯងក្នុងព្រះវិហារ ខ្ញុំមានអារម្មណ៍ថា ខ្ញុំចង់បានវត្តមានរបស់បងប្អូន ហើយបងប្អូនក៏ចង់មកដូចគ្នាដែរ ក៏ប៉ុន្តែដោយសារច្បាប់នៃក្រសួងសុខាភិបាល មិនអនុញ្ញាតឱ្យយើងជួបជុំគ្នាជាក្រុមបានទេ អីចឹងយើងដឹងថា ទាំងសងខាងក៏ពិបាកចិត្តមែនទែន។ ប៉ុន្តែបងប្អូនជាទីស្រឡាញ់ យើងសង្ឃឹមនិងបន្តអធិដ្ឋានរវាងគ្នានឹងគ្នា និងថែរក្សាព្រះសហគមន៍និងជំនឿកាន់តែច្បាស់។

**បងស្រី ស្រី សុជាតិ ដូនជីស្រឡាញ់ឈើឆ្កាងព្រះយេស៊ូ**
**នៅផ្ទះណូវីស –កំពង់ចាម**

ដំបូងដូចជាស្ងួត ស្រែកឃ្លានយើងខ្វះខាតអភិបូជា។ សម្រាប់ខ្ញុំផ្ទាល់ខ្ញុំមានសំណាងច្រើន ដោយសារព្រះវិហារកំពង់ចាម យើងមានវត្តមានរបស់លោកអភិបាលប្រ៊ុយណូ ដូច្នេះយើងមានអភិបូជាស្ទើរតែរាល់ថ្ងៃ។ ខ្ញុំបានចូលរួមផ្ញើសារលើកទឹកចិត្តតាម FB Messenger ដល់បងប្អូនឱ្យយកចិត្តទុកដាក់រកពេលវេលាអធិដ្ឋានខ្លួនឯង ហើយនិងអានព្រះបន្ទូល ដើម្បីជួយពង្រឹងជំនឿ កុំឱ្យយើងធ្លាក់ទឹកចិត្តដោយសារការគ្មានអភិបូជា។ ក្នុងរយៈពេលដែលព្រះសហគមន៍គ្មានសកម្មភាព ខ្ញុំបង្កើនការអានព្រះគម្ពីរ និងជួយដល់ណែនាំកម្មវិធីបង្រៀនជាមួយបងប្អូន (យុវនារីរៀនបួស)។ យើងមានឱកាសរស់នៅជាមួយគ្នាកាន់តែជិតស្និទ្ធ និងមានពេលទំនាក់ទំនងជាមួយព្រះជាម្ចាស់កាន់តែច្រើន ជាពិសេសយើងរួមជាមួយបងប្អូនឯទៀតៗតាមផ្លូវវិញ្ញាណ។



# សូមចូលរួមប្រយុទ្ធប្រឆាំង
# មេរោគកូវីដ១៩

សូមបងប្អូនបន្តគោរព
គោលការណ៍ណែនាំរបស់
ក្រសួងសុខាភិបាល




គម្លាតសុវត្ថិភាព៖ កាត់បន្ថយការជួបជុំ
មនុស្សច្រើនឬយ៉ាងតិច១,៨ម៉ែត្រពីគ្នា



អនាម័យ៖ ឧស្សាហ៍លាងដៃ
ជាមួយសាប៊ូ អាល់កុល ឬជែល



នៅក្នុងផ្ទះ៖ មិនចេញក្រៅផ្ទះ
បើមិនចាំចាច់



ក្អកឬកណ្តាស់៖ ខ្ទប់មាត់នៅពេលក្អក
ឬកណ្តាស់ ដោយប្រើកន្សែងឬកែងដៃ



ពាក់ម៉ាស់៖ នៅពេលអ្នកឈឺឬចេញទៅ
ខាងក្រៅ និងមិនត្រូវប៉ះមុខ មាត់ ភ្នែក ច្រមុះ



សំលាប់មេរោគ៖ ឧស្សាហ៍លាងនិង
ជូតសំអាតដោយអាល់កុលឬជែល

CSC
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ព័ត៌មានបន្ថែមសូមទាក់ទងលេខ ១១៥

ក្នុងអំឡុងពេលការរាតត្បាតនៃជំងឺកូវីដ១៩ យើងមិនអាចជួបជុំគ្នា ដើម្បីថ្វាយអភិបូជា ឬអធិដ្ឋានបានទេ។
ដូច្នេះ ដើម្បីថែរក្សាជំនឿ សូមបងប្អូនអធិដ្ឋានតាមផ្ទះរៀងៗខ្លួន។ នៅក្នុងព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ
យើងនឹងមានកម្មវិធីផ្សាយផ្ទាល់ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមដូចជា៖
www.facebook.com/CatholicPhnomPenh
www.facebook.com/CatholicCambodia និង www.facebook.com/RVAKhmer
www.youtube.com/catholicphnompenh ឬ www.youtube.com/RVAKhmer

**អភិបូជា** ថ្ងៃអាទិត្យម៉ោង ៩ព្រឹក និង **អធិដ្ឋានសូត្រផ្គុំ** ប្រចាំថ្ងៃម៉ោង ៦:៣០ល្ងាច
ដូច្នេះសូមបងប្អូនចូលរួមទាំងអស់គ្នា។

ទស្សនាវីដេអូទីនេះ

**សូមព្រះជាម្ចាស់នៅជាមួយបងប្អូន!**